# ទស្សនសង្គម
# តាមបែបព្រះពុទ្ធសាសនា



ផ្សាយចេញពីសមាគមអ្នកនិពន្ធ

រៀបរៀងដោយ ភិក្ខុ ធម្មបាលោ គន ធឿន

រក្សាសិទ្ធិ

លេខ ISBN : 978-99963-560-0-1

ព.ស. ២៥៥៤ គ.ស. ២០១០

4.3
ឞ
២

294.3

# ទស្សនសង្គមតាមបែបព្រះពុទ្ធសាសនា



HUN SEN LIBRARY
R.U.P.P.
20502

រៀបរៀងដោយ
ភិក្ខុ ធម្មបាលោ ភន ធឿន

សម្រាប់ជាធម្មទាន

បោះនៅ រោងពុម្ព ម៉េងហាង
អាស័យដ្ឋាន : ផ្ទះលេខ៨១, ផ្លូវ១៧២, សង្កាត់ជ័យជំនះ, ខណ្ឌដូនពេញ, ភ្នំពេញ (ខាងលិច វត្តឧណ្ណាលោម ប្រហែល ១៥០ ម៉ែត្រ)
ទូរស័ព្ទទំនាក់ទំនង : ០១២ ៧១២ ៧១៥ / ០១២ ៨២៦ ៩២០
០១២ ៧៧៩ ១០០ / ០៧៧ ២៧៧ ១០០

# ឆាយាលោកគ្រូ និងអ្នកមានគុណ



ព្រះគ្រូឋិរវិទូ នង ពន្លក
ព្រះគ្រូអនុគណ ស្រុកព្រៃឈរ
ខេត្តកំពង់ចាម



ព្រះគ្រូសុវណ្ណប្បជោត កង ណាម៉ានី
ព្រះគ្រូចៅអធិការ វត្តសំពៅមាស
ក្រុងភ្នំពេញ



ញោមប្រុស គង ញោមស្រី យ៉ាន



សាស្ត្រាចារ្យបណ្ឌិត ខៀវ កុសល

[illegible]

[illegible]

[illegible]

[illegible] ໑໗ [illegible] ໒໐໐໐

[illegible]

[illegible] 125

[illegible]

[illegible]

# អារម្ភកថា

សៀវភៅ "ទស្សនសន្តិភាពតាមបែបព្រះពុទ្ធសាសនា" នេះជាវណ្ណកម្មដំបូងស្រទាប់របស់ខ្ញុំបន្ទាប់ពីខ្ញុំបានអានស្នាដៃអ្នកនិពន្ធជាច្រើន និងព្រះត្រៃបិដក (សុត្តន្តបិដក) ខ្ញុំមានការចាប់អារម្មណ៍លើទស្សនៈការអប់រំទាំងនោះ នឹងយល់ឃើញថាមានប្រយោជន៍ដល់សង្គមគ្រប់យ៉ាង ដូចជាសង្គមរស់នៅរបស់ មនុស្ស សត្វ រុក្ខជាតិ យ៉ាងច្រើន ដើម្បីយកមកប្រៀបធៀបក្នុងសង្គមរស់នៅរបស់មនុស្សលោកពិត១ ។ អត្ថបទទាំងមូលមានន័យខ្លឹមសារអប់រំចំពោះសង្គមមនុស្សឱ្យចេះសង្កេតពិនិត្យ ប្រៀបធៀបដកពិសោធន៍ តស៊ូ ព្យាយាម ប្រឹងប្រែង ខ្នះខ្នែងក្នុងទិសដៅរួមគ្នាដើម្បីសុភមង្គល និងសន្តិភាព ។ ហេតុ នេះហើយ ទើបខ្ញុំដកស្រង់ត្រង់ចំណុចនិយាយ អំពីសន្តិភាព, សេដ្ឋកិច្ចនិងមនុស្ស និងចូឡកុក្កុដសូត្រ មករៀបរៀងជាសៀវភៅនេះឡើង។

ខ្ញុំរង់ចាំការរិះគន់ស្ថាបនា អំពីសម្នាក់អស់លោកអ្នកប្រាជ្ញ កវី បណ្ឌិត គោរិទវិទូ វិញ្ញូជន អ្នកនិពន្ធទាំងឡាយដោយក្ដីសោមនស្ស ។ ធម្មតាការរៀបរៀងតែងតែមានការភ្លេចភ្លាំង ភ្លាត់ខុសមិនខានឡើយ ដូចសុភាសិតខ្មែរបុរាណថា *"សត្វជើងបួនគង់មានភ្លាត់, អ្នកប្រាជ្ញចេះស្ទាត់ គង់មានភ្លេច"* មានតែអ្នកនៅស្ងៀមឥតធ្វើអីសោះនោះទេ ទើបគ្មានការទាស់ខុសឡើយ។

សូមសុខសន្តិភាពកើតមានដល់សព្វសត្វទាំងឡាយរហូតតទៅ ។

ភ្នំពេញថ្ងៃទី២៥ ខែឧសភា ព.ស ២៥៥៤ គ.ស ២០១០

**ភិក្ខុ ធម្មធរោ គន ឡៀន (ហៅ ពន្លក)**

# សេចក្តីថ្លែងអំណរគុណ

ជាដំបូង ខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះលោកឪពុកនាម **ឃ្លីស គន** និងអ្នកម្តាយនាម **អ៊ុច យ៉ាន** ដែលបានបង្កើត និងចិញ្ចឹមខ្ញុំតាំងពីតូចដល់ធំធម្រើនវ័យឡើង ព្រមទាំងតាមជួយឧបត្ថម្ភគ្រប់បែបយ៉ាងមកលើរូបកូនៗមិនមានឱ្យខ្វះកន្លះអ្វីឡើយ បើទោះបីជាលោកទាំងទ្វេកំពុងស្ថិតក្នុងសភាពបែបណាក៏ដោយចុះ ក៏លោកពុំដែលតម្អូញតម្អែរដែរ ។ ទាំងនេះសុទ្ធសឹងតែផុសចេញពីទឹកចិត្តព្រហ្មវិហារធម៌រកអ្វីមកឧបមាស្មើគ្មាន ដែលលោកបានដើរតួនាទីជាបុព្វទេវាចំពោះរូបខ្ញុំជាកូនពិតៗនេះ ។

ទីពីរ. សូមថ្លែងអំណរព្រះគុណ ព្រះគ្រូឧបជ្ឈាយ៍ និងលោកអាចារ្យបង្រៀនផ្នែកខាងព្រះពុទ្ធសាសនា ឱ្យខ្ញុំបានចេះដឹងរហូតមកដល់សព្វថ្ងៃនេះ ជាពិសេសព្រះគ្រូទិស្សយាចារ្យ **គង់ ណារ៉ាន់** ចៅអធិការវត្តសំមាស ព្រះគ្រូឧបសម្បទាចារ្យ **នង ពន្លក** ព្រះគ្រូអនុគណស្រុកព្រៃឈរ និងលោកសាស្ត្រាចារ្យបណ្ឌិត **ខៀវ កុសល** ព្រមទាំងលោកគ្រូ-អ្នកគ្រូសាស្ត្រាចារ្យដទៃទៀត ដែលបានបង្រៀនខ្ញុំផ្នែកវិជ្ជាខាងផ្លូវលោក ឱ្យបានចេះដឹងចេះវិភាគក្នុងសង្គមជីវិតផ្លូវលោក លទ្ធផលថ្ងៃនេះក៏ដោយសារទឹកចិត្តករុណារបស់លោកដ៏ឧដុង្គឧត្តម ក្រៃលែងរកអ្វីប្រៀបពុំបានឡើយ ។

ទីបី.សូមថ្លែងអំណរគុណយ៉ាងស្មោះស ចំពោះញាតិញោមជាពុទ្ធសាសនិក ដែលឧបត្ថម្ភជាចង្ហាន់ឱ្យអាត្មាភាពបានឆាន់ មានកំលាំងរៀនសូត្រ

បានចេះដឹង នេះក៏ដោយសារទឹកចិត្តសទ្ធាជ្រះថ្លារបស់ញាតិញោមដែលបានយល់ដឹងច្បាស់លាស់ពីគោលបំណងនៃជីវិតក្នុងខ្លឹមសារព្រះពុទ្ធឱវាទ ។

ទីបួន. សូមថ្លែងអំណរគុណចំពោះអ្នកមានឧបការគុណក្នុងការជួយពិនិត្យអក្ខរាវិរុទ្ធ ព្រះមហា នន្ទ សាប្ធុទ្ធិ, ភិក្ខុ គន សារ៉ាត, ព្រះមហា ផុន សុភី, ព្រះមហា ហ៊ុំ សុទ្ធា ព្រះមហា ដេម ថាឌី និងមិត្តភក្តិជាច្រើនទៀត ដែលបានជួយផ្តល់ជាយោបល់ ឱ្យខ្ញុំដោយទឹកចិត្តសប្បុរសក្នុងនាមជាអ្នកស្រឡាញ់ជាតិ និងព្រះពុទ្ធសាសនា ។

នៅទីបញ្ចប់នេះ ខ្ញុំសូមឧទ្ទិសកុសលដល់បុព្វការីជនរបស់ខ្ញុំ ព្រមទាំងបុព្វការីជន របស់លោកគ្រូសាស្ត្រាចារ្យ បុព្វការីរបស់ញាតិញោមដែលបានជួយឧបត្ថម្ភក៏ជាបច្ច័យបួន ជាពិសេសញាតិញោមវត្តសំពៅមាសតែម្តង និងមិត្តភក្តិរៀនជាមួយគ្នានិងមិត្តផ្សេងៗទៀតជាច្រើន សូមជួបតែសេចក្តីសុខ សេចក្តីចម្រើនតរៀងទៅ ។ ជាពិសេសជួបនូវសម្បត្តិបីគឺ មនុស្ស ទេវតា និងព្រះនិព្វាន បើនៅក្នុងវដ្តសង្សារនេះទេ សូមឱ្យមានតែបញ្ញាជាសម្មាទិដ្ឋិរាល់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញថ្ងៃទី២៥ ខែឧសភា ព.ស ២៥៥៤ គ.ស ២០១០

# មាតិកា

អារម្ភកថា ---------------------------------------- ក
សេចក្តីថ្លែងអំណរគុណ ---------------------------------------- ខ

## ទស្សនសង្គមតាមបែបព្រះពុទ្ធសាសនា

## ជំពូកទី១

អំពីសង្គម ---------------------------------------- ១
១) អំពីសង្គមរុក្ខជាតិ ---------------------------------------- ២
២) សង្គមសត្វតិរច្ឆាន ---------------------------------------- ១០
៣) សង្គមមនុស្ស ---------------------------------------- ២០
សង្គមជាប្រភពនៃលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិ ---------------------------------------- ២០
សង្គមជាប្រភពនៃសេដ្ឋកិច្ចទ្រព្យសម្បត្តិមាសប្រាក់ ---------------------------------------- ២៤
សង្គមជាប្រភពនៃសុជីវធម៌វឌ្ឍនធម៌ វប្បធម៌ សីលធម៌និងអារ្យធម៌ ---------------------------------------- ២៦
សង្គមជាប្រភពនៃចំណីអាហារ ---------------------------------------- ២៨
សង្គមជាចំណីអាហាររបស់សង្គម ---------------------------------------- ៣១

## ជំពូកទី២

សេដ្ឋកិច្ចនឹងមនុស្ស ---------------------------------------- ៣៨

# ជំពូកទី៣


ចូឡធុក្ខក្ខន្ធសូត្រ ---------- ៨៨

ការកំណត់នូវវេទនា ---------- ៨៩

តម្រេករបស់កាម ---------- ៩១

ទោសនៃកាមទាំងឡាយ ---------- ៩២

ការឈរចើយនៃពួកនិគ្រន្ថ ---------- ៩៩

ការទ្រទំសាកសួរពួកនិគ្រន្ថ ---------- ១០១

ពោលអំពីការនៅជាសុខដ៏សើសលុប ---------- ១០៣

ចំណោទ៨យ៉ាង ---------- ១០៧

ឯកសារពិគ្រោះ ---------- ១០៩

ពិនិត្យ ផ្ទៀងផ្ទាត់: ឯកឧត្តម ស៊ឹម ចណ្ណា

បណ្ឌិត ខៀវ គុសល

កែសម្រួលអក្ខរាវិរុទ្ធ: ព្រះមហា នន្ទ សាឫទ្ធិ

ព្រះមហា ផុន សុភី

និស្សិត ទឹម សុហ្វាយ

កញ្ញា ហ្វូ ទិតម៉ារីណា

ជួយវាយអក្សរ: សាមណេរ ឈុន ចិន័យ

សាមណេរ ញិន សុជាតិ

ជួយផ្តល់ជាមតិ: ព្រះមហា ហ៊ុ សុទ្ធា

ព្រះមហា ដេម ថាវី

ភិក្ខុ មៅ សុខុម

# ទស្សនសង្គមតាមបែបព្រះពុទ្ធសាសនា

## ជំពូកទី១

## អំពីសង្គម

ហេតុអ្វីមនុស្សសត្វ និងរុក្ខជាតិចូលចិត្តរស់នៅផ្តុំគ្នាក្នុងលោកនេះ? បើស្រាវជ្រាវរកឫសគល់ដើមបំផុតដែលបណ្តាលឱ្យកើតជាសង្គមឡើង ឃើញថាកើតមកពីអវិជ្ជានិងសង្ខារដែរព្រោះអវិជ្ជានិងសង្ខារនេះហើយ ដែលប្រមូលផ្តុំផ្សំផ្គុំធាតុ ដី ទឹក ភ្លើង ខ្យល់ អាកាស ឱ្យរួបរួមគ្នាជាពួក ជាក្រុមជាសង្គមកកើតបន្ត១តាំងពីតិណជាតិ រុក្ខជាតិ មកជាសត្វល្អិត ពីសត្វល្អិតមកសត្វធំ ពីសត្វធំមកជាមនុស្ស។

ដូច្នេះឃើញថាសង្គមក្នុងពិភពលោកនេះមានបីគឺ:

១-សង្គមរុក្ខជាតិ

២-សង្គមសត្វតិរច្ឆាន

៣-សង្គមមនុស្ស។

អាស្រ័យពូជដើម របស់ពិភពលោកមាននិស្ស័យបែបនេះទើបវត្ថុធាតុទាំងអស់ក្នុងលោកចម្រើនលូតលាស់បានដោយសារតែសង្គម គឺការផ្តុំផ្សំផ្គុំ សាមគ្គីរួបរួមគ្នា ព្រោះមានការចាំបាច់ត្រូវពឹងពាក់គ្នាដើម្បីរស់

រៀងៗខ្លួន ។ កុំនិយាយឡើយដល់ទៅវត្ថុមានចិត្តវិញ្ញាណដូច មនុស្ស ជាដើម សូម្បីវត្ថុគ្មានចិត្តវិញ្ញាណ ដូចតិណជាតិ រុក្ខជាតិជាដើម នេះក៏ត្រូវការសង្គមជាចាំបាច់ដែរ ដើម្បីជីវិតវា។

## ១) អំពីសង្គមរុក្ខជាតិ

ពួកស្មៅឈើវល្លិ មិនដែលដុះនៅទីវាលស្រឡះតែម្នាក់ឯងឡើយ ព្រោះខុសពូជនិស្ស័យរបស់វា រស់នៅមិនកើត. វាចូលចិត្តដុះរស់នៅជ្រៀតជ្រែកជិតៗគ្នា ជាពួកជាក្រុម ជាសង្គម ។

សង្គមរុក្ខជាតិនេះមានសកម្មភាពយ៉ាងសំខាន់គួរឱ្យចាប់អារម្មណ៍ យកចិត្តទុកដាក់ត្រិះរិះពិចារណាណាស់ដែរព្រោះសង្គមរុក្ខជាតិជាសង្គមដើមទីមួយ របស់សង្គមមនុស្សសត្វ។

សព្វថ្ងៃ ទីណាដែលវាលស្រឡះ គ្មានស្មៅឈើវល្លិដុះសោះនោះគេបង្កើតសង្គមរុក្ខជាតិឡើងគឺយកពូជស្មៅឈើវល្លិទៅដាំនិងក្លាយទៅ ជាព្រៃធំ ព្រោះពូជស្មៅឈើវល្លិដទៃៗទៀត ដែលគេមិនបានដាំសោះក៏ចេះតែកើតមានដុះលូតលាស់ឡើងព្រោងព្រាត ដោយអំណាចដីជាតិនិងធាតុអាកាសដែលកើតមាន អំពីសង្គមរុក្ខជាតិ ដែលគេបានបង្កើតឡើងនោះ។

សូមមិត្តអ្នកអានពិចារណាមើល!ស្មៅឈើវល្លិតូចៗត្រូវការពឹងពាក់ស្រូបជញ្ជក់យកជីជាតិ និងធាតុទឹកត្រជាក់ ពីស្មៅឈើវល្លិធំៗ ដែលដុះមុន ព្រោះឫស ដើមមែក ស្លឹក ស្មៅ វល្លិធំៗនោះស្រូបយកជីជាតិ និងធាតុទឹកពីអាកាសពីចំហាយព្រះអាទិត្យ នឹងពីផែនដីមកធ្វើជាចំណី អាហារនឹងញ៉ាំងបរិយាកាសក្នុងព្រៃនោះ ឱ្យមានសីតុណ្ហភាពងាយស្រួលដល់ការដុះលូតលាស់. លុះឫសដើមបែកស្លឹកស្មៅធំៗនោះចាស់បាក់ច្រុះទៅរលួយកើតជាជីធ្វើឱ្យផែនដីក្នុងព្រៃនោះធូរងាយស្រួលដល់ឫស ឈើ ស្មៅ វល្លិ ធ្វើដំណើរចាក់រុកតត្រុកវារលូនទៅគ្រប់ទិសទីដើម្បីស្វែងរកចំណីអាហារចិញ្ចឹមជីវិត ។

ឯស្មៅឈើវល្លិនោះវាមានជីវិត មានការស្រេកឃ្លានមានការស្វែងរកចំណីអាហារមានញីមានឈ្មោលមានម៉ែឪមានកូនចៅមានការងារធ្វើដើម្បីចិញ្ចឹមជីវិតវារាល់ពេលវេលាវាមិនខ្ជិលច្រអូសវាគ្មានពេលឈប់សម្រាកដូចមនុស្សសត្វឡើយ វាខំធ្វើការជានិច្ចគ្រប់នាទី ដើម្បីរស់នៅផ្ដល់ផលប្រយោជន៍ឱ្យសង្គមរបស់វា និងសង្គមមនុស្ស សត្វក្នុងលោកនេះ ។

ក្នុងក្បួនវិទ្យាសាស្ត្រ ផ្នែករូបសាស្ត្រនៃរុក្ខជាតិថា ស្មៅ ឈើ វល្លិ វាស៊ីចំណីអាហារអំពីផែនដីតាម ឫសវាស្រូបយកចំណីអាហារអំពីអាកាសតាមស្លឹក ។ ឫសវាដូចជាដៃជើងមនុស្សសត្វមានជីវិត ចេះរុកលូនវាររវើករសិបទៅក្នុងផែនដី,ទីណាមានជីជាតិ មានធាតុទឹកសើម វារុកតត្រុកលូនឧបស័គ្គ ដូចជាដុំថ្មឬដីរឹងខ្លាំង ឬទឹកច្រើនពេក ឬក៏ដីមានជាតិប្រៃជូរហួសជាដើម ឫសវាគេចវាងចេញពីទីនោះមិនលូនវារទៅជិតឡើយហាក់ដូចជាមានចិត្តវិញ្ញាណស្គាល់ខុសត្រូវដែរ ។

ឯចំណីអាហាររបស់ឈើវល្លិនោះគឺវត្ថុធាតុទាំងឡាយដែលមាននៅក្នុងផែនដី និងក្នុងអាកាស ដូចជាធាតុ អុកស៊ីសែនអាកាសធាតុធ្យូងអាហ្សូត ហ្វុលហ្វាត ប៉ូតាល និងវត្ថុធាតុផ្សេងៗ ស៊ូដ ប័រ និងម៉ង់កាណែស ។ល។ វត្ថុធាតុទាំងអស់នេះសុទ្ធតែជាទ្រព្យសម្បត្តិមាសប្រាក់ជាវត្ថុបំណងរបស់ស្មៅ ឈើ វល្លិទាំងឡាយដែលវាខំធ្វើការរុកតត្រុកលូនវារគ្រប់នាទីឥតឈប់ឈរ ដូចជាមនុស្សខំធ្វើការរកស៊ីដើម្បីបានមាសប្រាក់ដូច្នោះដែរ ។

ដើម្បីស្វែងរកបាននូវត្ថុធាតុដើម ទាំងអស់នេះ អាស្រ័យសង្គមទើបស្មៅឈើវល្លិទាំងឡាយត្រូវការសង្គមជាចាំបាច់ បើគ្មានសង្គមទេ

ស្មៅឈើវល្លិទាំងឡាយក៏គ្មានដែរ ដូចបាននិយាយខាងដើមហើយថា សង្គមរុក្ខជាតិនាំឱ្យផែនដីមានជីជាតិ មានធាតុអាកាសល្អ មានភ្លៀងច្រើន គឺនាំឱ្យកើតមានវត្ថុធាតុទាំងឡាយ មានអុកស៊ីសែនជាដើមដែលរុក្ខជាតិត្រូវការនោះឯង ។ ស្មៅឈើវល្លិធំៗ មិនគ្រាន់តែវត្ថុធាតុឱ្យឈើវល្លិតូចៗនោះរួចផុតពីឧបស័គ្គផ្សេងៗមានខ្យល់ព្យុះ និងកម្ដៅព្រះអាទិត្យជាដើមទៀត ។ ដូចមនុស្សជួយការពារសង្គមគ្រួសាររបស់ខ្លួនដូច្នោះដែរ ។

ពេលមានខ្យល់ព្យុះសង្ឃរា ខ្លាំងម្ដងៗ ស្មៅឈើវល្លិធំៗ ចេញមុនទទួលឧបស័គ្គនោះភ្លាម សុខចិត្តទប់ទល់ យកខ្លួនប៉ះទង្គិចប្រវាយប្រតប់វីវក់ ជាមួយសង្ឃរានោះ ទោះបីព្យុះសង្ឃរា បោកត្រូវទ្រេតទ្រោត របួសបាក់មែកជ្រុះស្លឹកយ៉ាងណាក៏ស្មៅឈើវល្លិធំៗនោះ មិនរត់ចោលឡើយសុខចិត្តចាញ់តស៊ូការពារស្មៅឈើវល្លិតូចៗ ដរាបដល់រយៈបែកបាក់ដើម រលំដួលស្លាប់នៅនឹងកន្លែង ។ ចំពោះការតស៊ូនឹងកម្ដៅព្រះអាទិត្យវិញ ក៏សុខចិត្តទ្រាំក្ដៅធ្វើប្រងើយគ្រប់នាទី ដរាបដល់ស្វិត ស្រពោនជ្រុះស្លឹកស្ងួតដើមស្លាប់ឥតថ្ងូរឡើយ ដើម្បីស្មៅឈើវល្លិតូចបាន ម្លប់ត្រជាក់ ដុះលូតលាស់បានស្រួល ។

ឯស្មៅឈើវល្លិធំៗវិញក៏ត្រូវពឹងពាក់ស្រូបជញ្ជក់យកជីជាតិ. និងកិច្ចការពារឧបស័គ្គអំពីស្មៅ ឈើ វល្លិ តូចៗ ជាការចាំបាច់ដែរ គឺត្រូវការចំពោះសង្គមដូចគ្នា បើគ្មានសង្គមទេស្មៅឈើវល្លិធំៗនោះលូតលាស់ធំឡើងមិនកើតនឹងត្រូវខ្យល់ព្យុះ ឬកម្ដៅព្រះអាទិត្យបោកបក់ឱ្យ រលំធ្វើឱ្យក្រៀមស្លាប់មិនខាន ។ សូម្បីស្មៅ ឈើ វល្លិដែលកំពុងដុះលូតលាស់ល្អ ក្នុងសង្គមរុក្ខជាតិ មាឌុធំមាំខ្ពស់យ៉ាងណាហើយក៏ដោយ បើគេកាច់ស្មៅឈើវល្លិតូចៗជុំវិញអស់រលីងហើយ ស្មៅឈើវល្លិធំនោះក៏មិនអាចមានជីជាតិរស់នៅយូរឡើយ នឹងរលំបាក់ស្វិតស្លាប់មិនខាន ព្រោះ ស្មៅឈើវល្លិតូចៗ ដែលដុះចោមរោមជុំវិញនោះ ដូចជារនាំង ឬ ដំបូលក្របបិទបាំងផែនដីឱ្យ ស្មៅ ឈើ វល្លិ បានត្រជាក់គល់មិនឱ្យ ត្រូវកម្ដៅព្រះអាទិត្យខ្លាំង រក្សាទឹកទុកឱ្យដីសើមបានយូរ និងទប់ទុកនូវកំទេចជីជាតិមិនឱ្យហូរទៅតាមទឹកឬប៉ើងទៅតាមខ្យល់បាននិងជារនាំងជួយការពារព្យុះសង្ឃរាមិនឱ្យបោកបក់ត្រូវខ្លាំង។

ដោយអានុភាពសង្គមរុក្ខជាតិ ដែលចេះជួយការពារគ្នាជួយផ្ដល់ប្រយោជន៍សុខចម្រើនឱ្យគ្នា គឺពួកស្មៅវល្លិធំៗជួយការពារសង្គ្រោះឃិតយោងស្មៅឈើវល្លិតូចៗ. ពួកស្មៅឈើវល្លិតូចៗ ជួយការពារ

ផ្តល់ប្រយោជន៍ឱ្យសៅ្ទឈើវល្លិធំនេះឯង នាំឱ្យពួកតិណជាតិ រុក្ខជាតិ ធញ្ញជាតិទាំងឡាយចោមរោមដុះលូតលាស់កាន់តែច្រើន. ឯពួកទេវតា មនុស្សសត្វក៏មានចិត្តរីករាយចូលទៅរកសង្គមរុក្ខជាតិនោះ ដើម្បី អាស្រ័យនៅនិងចិញ្ចឹមជីវិតដោយផលព្រៃឈើនេះ ។ សូម្បីមហាមេឃ ក៏ចោលចាញ់អានុភាពសង្គមរុក្ខជាតិដែរត្រូវសង្គមរុក្ខជាតិដែលគ្មានចិត្ត វិញ្ញាណនេះស្រូបយកពពក យកទឹកភ្លៀង មកបម្រើសង្គមខ្លួនបាន ដោយងាយ គួរមនុស្សលោកយកតម្រាប់តាមសង្គមរុក្ខជាតិដែលមាន លក្ខណៈគុណសម្បត្តិល្អបែបនេះកុំខាន ។

ឯគុណវិបត្តិក្នុងសង្គមរុក្ខជាតិនេះ មានសាមគ្គីស្រុះស្រួលស្មោះត្រង់ នឹងគ្នាណាស់ គ្មានការក្បត់ គ្មានអំពើអកុសលជិះជាន់សង្កត់សង្កិន លួចប្លន់ដណ្តើម ទឹក ដី យសស័ក្តិ ស៊ីសំណូក ប្រកាន់បក្សពួកសម្លាប់ ជីវិតគ្នា.ប៉ុន្តែបើពិនិត្យសង្កេតឱ្យល្អិតល្អន់ ឃើញថាមានអំពើអកុសល ពុករលួយ ដូចសង្គមមនុស្សសត្វដែរ គ្រាន់តែមិនសូវជាក់ស្តែងប៉ុណ្ណោះ ព្រោះរុក្ខជាតិគ្មានចិត្តគ្មានរូបកាយថេះនិយាយស្តី ។

អំពីការជិះជាន់សង្កត់សង្កិនដណ្តើមឋានៈ យសស័ក្តិ ក្នុងសង្គម រុក្ខជាតិ= ពួកសៅ្ទឈើវល្លិជាច្រើន ដែលមានលក្ខណៈ អាក្រក់ខិលខូច

ដូចមនុស្សសត្វដែរមានដើម ជ្រៃបញ្ញើក្អែក និងពួកវល្លិខ្លះទៀត. ពួកឈើនេះមិនចង់ដុះនៅទីថោកទាបផ្ទាល់ នឹងដីដូចឈើដទៃទៀតឡើយ ចង់តែដុះនៅទីខ្ពង់ខ្ពស់ជិះជាន់សង្កត់សង្កិន លើសិទ្ធិឈើដទៃដូចជាដើមជ្រៃទៅដណ្តើមដុះលើឈើដែលមានឋានៈធំខ្ពង់ខ្ពស់ស្រាប់ មានដើមត្នោតជាដើម កាលបានដុះលើគេហើយ ខំរួបរឹតបឺតជញ្ជក់យករសជាតិគេមកចិញ្ចឹមជីវិតខ្លួន ឱ្យបានធំធាត់រស់នៅក្នុងទីខ្ពង់ខ្ពស់ ដែលគេខំរស់មកជាយូរឆ្នាំហើយនោះ. ដល់ខ្លួនបានធាត់ធំក៏សម្លាប់គេចោលទៅ គឺជិះជាន់បឺតជញ្ជក់យករសជាតិគេ និងដណ្តើមយកឋានៈធំខ្ពង់ខ្ពស់របស់គេហើយសម្លាប់ម្ចាស់គេចោលទៀត ។

ឯដើមបញ្ញើក្អែកក៏ដូច្នេះដែរខ្លួនជាពូជឈើតូចទាបគ្មានយសស័ក្តិធំខ្ពង់ខ្ពង់ថ្កុំថ្កើង ដូចឈើដទៃខំទៅដុះចន្លើតលើចុងកំពូលគេដើម្បីបានថ្កើនយសស័ក្តិខ្ពង់ខ្ពស់ដូចពូជឈើធំៗ.លុះទំជាប់ស៊ប់លើចុងកំពូលហើយក៏ខំស្រូបជញ្ជក់យករសជាតិគេចិញ្ចឹមជីវិតខ្លួន សម្លាប់គេចោលទៅ ។ នេះជាអំពើអកុសលអយុត្តិធម៌មួយ ក្នុងសង្គមរុក្ខជាតិ ។

អំពីការរុករានទន្រ្ទានទីរួចបួនសម្លាប់ដណ្តើមយកទឹកដី ក្នុងសង្គមរុក្ខជាតិ= ពួកយើងជាច្រើន ដែលជាលក្ខណៈចក្រពត្តិអាក្រក់បែបនេះ

មានទន្រ្ទានខេត្ត ស្កា ស្សូវ កំប្លោក ត្រីបជាដើម. ពួកឈើនេះ បើដុះនៅទីណា ហើយតែងរាតត្បាតលួចប្លន់សម្លាប់ដណ្ដើមយកទឹកដីនៅទីនោះធ្វើឱ្យឈើ ដែលដុះក្នុងទីនោះមុន វិនាសអន្តរាយរត់ចោលស្រុកភូមិអស់.ដូចដើមស្កា ស្សូវ ទន្រ្ទានខេត្តជាដើម បើវាដុះនៅទីណាហើយពួកឈើ ស្មៅវល្លិ ក្នុងទីនោះ ត្រូវវិនាសអន្តរាយអស់ ទីដីនោះត្រូវបានជាកម្មសិទ្ធិរបស់វា ។ ឯកំប្លោកត្រីបជាដើមដែលដុះក្នុងបឹងត្រពាំងដូច្នេះដែរ បើដុះក្នុងត្រពាំងណាហើយ វាតែងរាតត្បាតរុករានទន្រ្ទានទីនោះ ជិះជាន់ពួកជលជាតិទាំងឡាយ មានឈូកព្រលឹតជាដើម ដែលដុះក្នុងទីនោះមុនឱ្យវិនាសអន្តរធានអស់.ទឹកក្នុងបឹងត្រពាំងនោះ ត្រូវបានជាកម្មសិទ្ធិរបស់វា ។នេះជាអំពើអយុត្តិធម៌អាក្រក់មួយក្នុងសង្គមរុក្ខជាតិ ។

អំពីការស៊ីសំណូកលំអៀងប្រកាន់ប័ក្សពួកក្នុងសង្គមរុក្ខជាតិ= ស្មៅឈើវល្លិទាំងឡាយ ពិតមែនតែគ្មានចិត្ត វិញ្ញាណ ដូចមនុស្សសត្វប៉ុន្តែចេះស៊ីសំណូកចេះលំអៀងប្រកាន់ប័ក្សពួកដែរ ដូចជាស្មៅគ្រប់ប្រភេទនិងឈើទាំងឡាយពួកខ្លះ ដែលដុះក្នុងស្រែចម្ការក្នុងសួនផ្កាជាដើម ពួកស្មៅឈើវល្លិទាំងនេះវាសុខចិត្តឱ្យដុះលូតលាស់មានជីវិតធាត់

ធំបាន តែស្មៅឈើវល្លិណាជាបក្សពួកវាដែលមានកម្លាំងជាតិពូជប៉ិន ស្រួបជញ្ជក់យកសំណូក គឺជីជាតិមកផ្តល់ចែកឱ្យវាផង ទុករស់នៅខ្លួនឯងបានផង ឯរុក្ខជាតិដទៃដូចដើមពោត សណ្តែក ស្រូវ កប្បាសជាដើម ដែលមានកម្លាំងខ្សោយ មិនអាចចែកសំណូកគីជីជាតិឱ្យវាបាននោះ វាសង្កត់ជិះជាន់ មិនឱ្យដុះលូតលាស់ធាត់ធំបានឡើយ ព្រោះមិនមែនបក្សពួកវា ។ នេះជាអំពើអយុត្តិធម៌ពុករលួយមួយក្នុងសង្គមរុក្ខជាតិ ។

ពួកស្មៅឈើវល្លិណាដែលខិលខូច ប្រព្រឹត្តអំពើអកុសលពុករលួយក្នុងសង្គមរុក្ខជាតិ ដូចខាងលើនេះ ត្រូវមានទោសជាទម្ងន់ដល់ប្រហារជីវិត ដូចដើមជ្រៃបញ្ញើក្អែក ស្បូវ ស្គា ស្មៅជាដើម ត្រូវមនុស្សស្អប់ខ្ពើម កាប់គាស់បំផ្លាញសម្លាប់ចោលឥតត្រាប្រណីឡើយព្រោះវាជាអ្នកក្បត់សង្គមរុក្ខជាតិ។ មនុស្សលោកទាំងឡាយមិនត្រូវយកតម្រាប់តាមពួកឈើខិលខូចនេះឡើយ ។

## ២) សង្គមសត្វតិរច្ឆាន

ពួកសត្វតិរច្ឆានទាំងឡាយដែលរស់នៅលើគោកនិងក្នុងទឹកមាន គោក្របីដំរីសេះឆ្កែឆ្មារ ស្រមោច ស្រមើល ត្រី បង្កងជាដើមមិនដែលរស់នៅទីស្ងាត់តែម្នាក់ឯងឡើយចូលចិត្តរស់នៅរួមគ្នា ជាពួកជាក្រុម ជា

សង្គម ដើម្បីជីវិតវា ព្រោះជីវិតសត្វតិរច្ឆាន ត្រូវការសង្គមជាចាំបាច់ ជាងជីវិតរុក្ខជាតិទៅទៀត ។

ពួកស្មៅឈើវល្លិទាំងឡាយ ត្រូវការចំណីអាហារតែមួយបែបដូចគ្នា គឺដី ទឹកជីវជាតិ និងធាតុអាកាស ។ ឯពួកសត្វតិរច្ឆាន ត្រូវការចំណីអាហារច្រើនបែបផ្សេងៗគ្នា សត្វខ្លះស៊ីស្មៅឈើវល្លិជាចំណីអាហារសត្វខ្លះស៊ីដីជាចំណីអាហារ សត្វខ្លះស៊ីសាច់ជាចំណីអាហារសត្វខ្លះទៀតស៊ីបាយជាចំណី ដូចពួកមនុស្សដែរ ចំណីអាហារទាំងអស់នេះកើតមានតែក្នុងសង្គមទើបសត្វតិរច្ឆានត្រូវការសង្គមជាចាំបាច់ខានមិនបាន ។

សង្គមតិរច្ឆាននេះអនាធិបតេយ្យ ឥតច្បាប់ទម្លាប់ គ្មានធម្មនុញ្ញការពារសិទ្ធិសេរីភាពសត្វក្នុងសង្គមឡើយ មានតែកម្លាំងដៃជើងកម្លាំងស្នែងនិងចង្កូមជាគ្រឿងការពារសិទ្ធិសេរីភាពរៀងៗខ្លួន ។សត្វណាមានកម្លាំងច្រើនមានស្នែងស្រួចមានចង្កូមមុតមានពិស សត្វនោះមានសិទ្ធិសេរីភាពច្រើន មានចំណីអាហារគ្រប់គ្រាន់ មានគេគោរពកោតខ្លាចច្រើន សត្វណាខ្សោយគ្មានស្នែងគ្មានចង្កូមខ្វះការតស៊ូសត្វនោះត្រូវតែបៀតបៀនជិះជាន់សម្លាប់ចោលនិងត្រូវជាចំណីគេ ។

សូមពិចារណាមើលចុះ សត្វធំស៊ីសត្វតូចសត្វមានអានុភាពដូចត្រីធំ

ស៊ីត្រីតូច ត្រីតូចស៊ីសត្វល្អិតតូចៗ ដូចដង្កូវទឹក បង្គារកំពិសជាដើមតទៅទៀត ក្រពើក្រពា ស៊ីត្រីទាំងតូចទាំងធំ សត្វស្ពាសំពោចស៊ីមាន់ទា មាន់ទាស៊ីសត្វតូចៗ ដូចដង្កូវជន្លេន កណ្ដូប ចង្រិតជាដើម សត្វខ្លាស៊ីគោ ក្របី ដ្ំរី សេះ ក្ដាន់ រមាំង ឈ្លូស ប្រើស ចៀម ពពែ ជាដើមសត្វខ្លាធំៗដែល មានអានុភាព ស៊ីខ្លា ដែលទន់ខ្សោយនោះទៀត ។ ឃើញច្បាស់ថាសត្វតិរច្ឆានត្រូវការសង្គមជាចាំបាច់ខ្លាំងណាស់ព្រោះសង្គមចំណើអាហាររបស់វា ៗមានជីវិតរស់នៅបានអាស្រ័យសាច់ឈាមរសជាតិ របស់សង្គមដូចសត្វខ្លា បើវាកើតឡើងក្រៅសង្គមគឺកើតក្នុងទីស្ងាត់តែម្នាក់ឯងគ្មានសត្វអ្វីនៅជិតវាសោះនោះ វាពិតជាស្លាប់មិនខាន ។

ក្នុងសង្គមសត្វតិរច្ឆាននេះបើ មិនបានជាពិនិត្យឱ្យហ្មត់ចត់ឃើញថាសង្គមពុករលួយអាក្រក់ពេកណាស់ ប៉ុន្តែបើពិនិត្យឱ្យជិតដល់ទៅឃើញថា ក្នុងសង្គមនេះ មានសេចក្ដីល្អខ្លះដែរ ដូចពួកសត្វខ្លះ វាមានចរិយាល្អជាងពួកមនុស្សទៅទៀត ។

ពួកសត្វស្រមោចកណ្ដៀរវាមានសាមគ្គីធម៌ចេះស្ដាប់បង្គាប់តាមមេបាវា មានសេចក្ដីព្យាយាម ចេះប្រមូលសន្សំ សំចៃទុកទ្រព្យសម្បត្តិ

ជាងពួកមនុស្សភាគច្រើនឆ្ងាយណាស់ ។

ដូចធ្លាប់ឃើញស្រាប់ពួកកណ្ដៀរ វាស្រុះស្រួលចិត្តគ្នាចេះស្ដាប់បង្គាប់តាមមេវា ចេះធ្វើការហត្ថកម្ម ជញ្ជូនដី ម្នាក់ៗជញ្ជូនម្ដងបានតែបន្តិចប៉ុនចុងម្ជុល យកទៅគរពូនធ្វើវិមានប្រាសាទច្រើនជាន់ ច្រើនថ្នាក់មានល្វែងបន្ទប់ រាប់មិនអស់សម្រាប់គ្រួសារវាជ្រកនៅយូរៗកើតជាដំបូកយ៉ាងធំប៉ុនកូនភ្នំ ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះ ដែលគិតតែស៊ីចាយហ៊ឺហា រកដំបូលផ្ទះរបស់ខ្លួនជ្រកនៅគ្មាន ។

ពួកសត្វស្រមោចក៏ដូច្នោះដែរ រដូវរាំងស្ងួតវាចេះរួមសាមគ្គីតាមមេបាវា ខំប្រមូលជញ្ជូនចំណីអាហារ មានគ្រាប់ស្រូវអង្ករជាដើមដើរហូរហែរ យកទៅគរទុកក្នុងឃ្លាំងរបស់វា ដល់ពេលមានភ្លៀងរលឹមសើមដី មិនអាចរកចំណីអាហារបានវានាំគ្នាចិញ្ចឹមជីវិតដោយស្បៀងដែលបានសន្សំសំចៃទុកនោះដោយស្រួលឃើញថា មានគំនិតមារយាទប្រសើរខ្ពង់ខ្ពស់ ជាងមនុស្សពួកខ្លះដែលខ្ជិលច្រអូសស៊ីចាយខ្ជះខ្ជាយមិនចេះសន្សំទុក ដល់ពេលឃ្លាន ហើយអត់ ធ្វើឬកថោកទាបបំផុតទៅសុំទានគេ ឬខ្ចីបុលស្រូវអង្ករអំបិលប្រហុកគេ យកមកបន្តជីវិត ។មនុស្សបែបនេះអន់ជាងសត្វស្រមោចទៅទៀត ។

ពួកសត្វអក ក៏មានចិត្តគំនិតស្មោះត្រង់ តស៊ូចំពោះគ្រួសារវាណាស់ដែរ វាមានសេចក្ដីស្នេហាស្រឡាញ់កូន និងញី ឈ្មោលវាស្មោះស្ម័គ្រស្មើជីវិត បើកូនវាស្លាប់ ឬញីឈ្មោល វាស្លាប់ឬព្រាត់ប្រាសគ្នាដោយហេតុណាមួយ វាស្រែកយំ វាមិនស៊ីចំណីអាហារហើយហើរយ៉ាងខ្ពស់ទម្លាក់បោកខ្លួនសម្លាប់ឱ្យស្លាប់តាមដែរ ។ ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះ ដែលមានចិត្តវៀចផិតក្បត់ ស្វាមីភរិយាខ្លួន មានស្រីជាមនុស្សសាវ៉ា មានប្ដីសហាយទៀតនឹងគ្រាន់បើជាងម៉ែឪខ្លះដែលមិនចេះថែរក្សាកូនបង្កើតហើយធ្វើបាបវាយតប់ដូចខ្ញុំកំដរ យកកូនទៅលក់ឱ្យគេឬយកកូនទៅបោះចោល ក្នុងគំនរសម្រាមជាដើម ។ មនុស្សបែបនេះ អន់ជាងសត្វអកទៅទៀត ។

ពួកសត្វកេងកងញី ក៏មានសេចក្ដីស្នេហាស្រឡាញ់ស្មោះស្ម័គ្រចំពោះឈ្មោល និងកូនវាណាស់ដែរកាលបើវាមានកូនខ្ចីហើយវាមិនឱ្យឈ្មោលវាចេញទៅរកស៊ីឡើយ វាខ្លាចមានសហាយឱ្យឈ្មោលវានៅក្រុងកូនក្នុងរូងឈើហើយវាពាំដី ស្អិតយកមកបិទជិតទុកតែរន្ធ បញ្ចុកចំណីគឺវាសុខចិត្តតស៊ូនឿយ លំបាករកចំណីចិញ្ចឹមឈ្មោលវាផង កូនផងដរាបដល់ធំដុះស្លាបហើរបានទើបវាចឹកបំបែកដីឱ្យហើរចេញ ទាំងកូន

ទាំងឪមក ។ ឃើញថាគ្រាន់បើជាងស្ត្រីខ្លះ ដែលកាចកាឡកណ្ណី ឥតចេះស្រឡាញ់ប្ដីនិងកូនសោះ គិតតែពីប្រមាថជេរវាយតប់ឈ្លោះរករឿងហើយប្រើប្ដីនិងកូនឱ្យបម្រើខ្លួនដូចទាសកម្មករស្ត្រីបែបនេះអាន់ជាងសត្វកេងកងញីឆ្ងាយណាស់ ។ ពួកសត្វប្រឡាំងកាសញីក៏មានសេចក្ដីស្នេហាស្រឡាញ់បម្រើផ្គាប់ចិត្តថ្នាក់ថ្នមឈ្មោលវាណាស់ដែរ វាមិនឱ្យឈ្មោលវាទៅ រកស៊ីឃ្លាតឆ្ងាយពីខ្លួនឡើយ គឺវាសុខចិត្តបញ្ជិះឈ្មោលវាលើខ្នង ដើរទៅរកស៊ីជាមួយគ្នា កាលរកបានចំណីហើយបញ្ចុកឈ្មោលឱ្យស៊ីមុន ទើបវាស៊ីក្រោយ ។ ឃើញថាគ្រាន់បើមែនទែនជាងស្ត្រីពួកខ្លះដែលខ្ជិលគិតតែតុបតែងខ្លួន និងស៊ីចាយហ៊ឺហាជិះជាន់កប្ដីបន្ថិចទារអាវសម្លៀកបំពាក់ថ្មី បន្តិចទារមាសពេជ្របន្តិចទារឡានបន្តិចទារលុយស៊ីចាយមើលកុន ល្ខោន ធ្វើបាបប្ដីឱ្យខំស៊ីសំណូក ឱ្យខំធ្វើការរហាម នឿយហត់រកពេលឈប់សម្រាកគ្មានបើទារប្ដីមិនបានដូចចិត្តរករឿង លែងលះគ្នាទៅរកប្ដីថ្មីទៀត ។ ស្ត្រីបែបនេះអន់បំផុតជាងសត្វប្រឡាំងកាសញីទៅទៀត ។

ពួកសត្វមាន់ក៏មានចរិយាល្អណាស់ដែរ ចេះគោរពពេលវេលាទៀងទាត់ មិនខ្ជិលដេកទម្រន់ឱ្យឡើយ គឺបើដល់ពេលជិតភ្លឺហើយវាខំស្រែក

រងារដាស់មិត្រភ័ក្តិវា និងម្ចាស់វា ឱ្យក្រោកឡើង ធ្វើការងារ ។ឃើញថា គ្រាន់ បើជាងមនុស្សពួកខ្លះ ជាអ្នកដេកនិយមល្មោភដេកច្រើន យកមុងកន្ទេលខ្មើយធ្វើពួកម៉ាកថ្ងៃរះពាក់កណ្តាលមេឃហើយក៏នៅតែបើកភ្នែកមិនរួច ទន់ជ្រាយសាច់ឆ្អឹងសរសៃអស់ ក្រោកមិនបានបណ្តោយឱ្យពេលវេលាដែលសុទ្ធតែមាសប្រាក់នោះ ធ្វើដំណើរទៅចោលអស់ ។ មនុស្សបែបនេះ អន់ជាងសត្វមាន់ទៅទៀត ។

ពួកសត្វព្រាប ក៏មានគំនិតមារយាទល្អខ្លះដែរបើវារស់នៅក្នុងទីកន្លែងណាវាស្រឡាញ់ទីកន្លែងនោះ វាចាំទិសចាំផ្លូវទៅទីកន្លែងនោះច្បាស់ពិតប្រាកដមិនវង្វេងភ្លេច ទោះបីគេចាប់វាយកទៅលែងចោលនៅទីឆ្ងាយក៏ដោយវាអាចហើរមករកទីកន្លែងវាបានមិនភ័ន្តច្រឡំឡើយ ឃើញថា គ្រាន់ជាងមនុស្សពួកខ្លះដែលរកទីកន្លែងផ្ទះសំបែង នៅពិតប្រាកដ មិនបានចេះតែដើរអាវ៉ាសែគ្មានអាស័យដ្ឋាន ពិតប្រាកដ ម្តងចង់នៅភូមិស្រុកនេះម្តង ចង់នៅភូមិស្រុកនោះ ចេះតែដើរទេរសាត់អណ្តែត តាំងពីក្មេងដល់ចាស់រកទីភូមិឋានស្រេចម្ការច្បារដំណាំគ្មាន ។

ពួកសត្វត្រដេវ៉ិចជាសត្វមានចរិយាល្អ ២ យ៉ាងគឺ ១-វាមានការប្រុងប្រយ័ត្ន ជានិច្ច សូម្បីវាដេក ក៏យកជើងឡើងក្រែងមេឃធ្លាក់

សង្កត់វា២-ជាសត្វចេះប្រុងប្រយ័ត្នថែរក្សាស៊ុត (ពង) របស់វាជាងសត្វបក្សីទាំងអស់ ។ ឃើញថាគ្រាន់ជាងមនុស្សពួកខ្លះ ដែលគ្មានការប្រុងប្រយ័ត្នសោះ ធ្វើការអ្វីនិយាយស្តីអ្វីចេះតែ រមាំងរមោកខ្ញោកខ្ញាកធ្វើឱ្យរួចតែពីដៃ និយាយឱ្យរួចតែពីមាត់ នាំឱ្យមានការខុសឆ្គង ភ្លាំងភ្លាត់ខកខូចខាតប្រយោជន៍អ្នកដទៃ។ មនុស្សបែបនេះអន់ជាងសត្វត្រដេវ៉ុចទៅទៀត ។

ពួកសត្វចាមរី ជាសត្វចតុប្បាទមាឌធំ ចូលចិត្តនៅទីត្រជាក់ជិតភ្នំហិមាល័យ វាមានចរិយាល្អណាស់ដែរ ជាសត្វចេះថែរក្សារោមកន្ទុយរបស់វា មិនឱ្យប្រឡាក់សៅហ្មងដោយធូលីអ្វីឡើយទីណាដែលមានភក់ជ្រាំក្រខ្វក់ សូម្បីស្រែកទឹកឃ្លានចំណីយ៉ាងណា ក៏វាមិនចូលទៅទីនោះដែរ ។ឃើញថាគ្រាន់បើជាងមនុស្សភាគច្រើន ដែលបណ្តោយកាយវាចាចិត្តឱ្យ ប្រឡាក់សៅហ្មងដោយអំពើទុច្ចរិតអបាយមុខមានលួចប្លន់ស៊ីសំណូកកេងកិបនិងលេងល្បែងភ្នាល់ជាដើម ព្រោះតែសេចក្តីលោភស្រេកឃ្លាន ចង់មានទ្រព្យសម្បត្តិយសសក្តិ ចង់សប្បាយ ។មនុស្សបែបនេះ អន់ជាងសត្វចាមរីឆ្ងាយណាស់ ។

ពួកសត្វជីងចក់ ក៏ជាគំរូមួយយ៉ាងល្អវាចេះផ្លាស់ពណ៌សម្បុរទៅតាម



បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P.

ទីកន្លែង បើវានៅក្នុងផ្ទះឈើផ្ទះស្លឹក ឬទីដែលមានពណ៌ខ្មៅខ្លួនវាប្រែពណ៌សជាសត្វទាន់សម័យ ចេះផ្លាស់ប្តូររូបកាយ តាមកាលៈទេសៈបាន ។ ឃើញថា គ្រាន់បើជាងមនុស្សពួកខ្លះ ដែលមានកាយវាចាចិត្តឆ្គងឈ្លើយមិនទាន់សម័យឬជាអ្នកទាន់សម័យហួសហេតុពីក្នុងកាលៈទេសៈ ឬក្នុងទីប្រជុំ ដែលត្រូវស្លៀកពាក់និយាយស្តីឈរអង្គុយបែបនេះខ្លួនធ្វើបែបនោះខុសប្លែកពីគេនាំឱ្យគេសើចគេតិះដៀល ។ម្យ៉ាងទៀតដូចអ្នកចូលទៅសេពគប់និងមនុស្សល្អត្រឹមត្រូវហើយខ្លួននៅតែធ្វើអំពើអាក្រក់ផ្តេសផ្តាសមិនផ្លាស់ចិត្តគំនិតតាមគេស្មោះ ។ មនុស្សបែបនេះ អន់ជាងសត្វជីងចក់ទៅទៀត ។

ពួកសត្វឆ្កែ ឆ្មា ក៏វាមានចិត្តស្មោះត្រង់ដឹងគុណណាស់ដែរ អ្នកណាដែលស្រឡាញ់វាចិញ្ចឹមវាឱ្យបាយវាស៊ី ថ្នាក់ថ្នមវាគ្រាន់តែឃើញមុខអ្នកនោះ វាចេះគួរសមបក់កន្ទុយ បន្ទាបខ្លួន បន្ទន់ស្លឹកត្រចៀកថ្លែងសេចក្តីគោរព ស្រឡាញ់ ស្មោះស្ម័គ្រអស់ពីដួងចិត្ត វាជួយឈឺឆ្អាលយកចិត្តទុកដាក់ ជួយធ្វើការថែរក្សាផ្ទះភូមិឋាន ចាប់កណ្តុរការពារសត្រូវ មិនឱ្យបៀតបៀនបាន មិនបាច់ស្តីប្រដៅបង្ខំចិត្តប្រើឱ្យវាជួយឡើយ ។ ឃើញថាគ្រាន់បើជាងមនុស្សពួកខ្លះជាអកតញ្ញូ ដែលប្រមាថ

ប្រទូសព្យាបាទស្អប់ខ្ពើម មិនចង់ជួបមុខ អ្នកមានឧបការៈគុណរបស់ខ្លួន ដោយយកលេសផ្សេងៗ មកលុប បំបាត់គុណគេចោល ។ មនុស្សបែបនេះ អន់ជាងសត្វឆ្កែឆ្មាទៅទៀត ។

ពួកសត្វស្លាបខ្លះដូចស្មោញប្រវឹកជាដើមវាមានសណ្ដាប់ធ្នាប់ប្រសើរណាស់ ក្នុងពេលវាហោះហើរឰដ៏អាកាសមានរបៀបរបបសណ្ដាប់ធ្នាប់ ជាជួរត្រឹមត្រង់ឥតខ្ចោះ គឺវាហើររៀងរាយគ្នាតាមលំដាប់ មេកោយមុនក្រោយ បណ្ដោយបន្ទបន្ទាប់គ្នា មើលទៅត្រង់ភ្លឹង ដូចបន្ទាត់គ្មានរប៉ាត់រប៉ាយ រឃឹករឃាកព្រោងព្រាត ច្របូកច្របល់ឡើយ ។ឃើញថាគ្រាន់ បើជាងមនុស្សពួកខ្លះ ដែលឥតសណ្ដាប់ធ្នាប់គ្មានសុជីវធម៌ ក្នុងការដើរនឹងអង្គុយមិនត្រឹមត្រង់ជួរគ្នាដែរ ចេះតែអង្គុយ ផ្ដេសផ្ដាសដើរទទឹសទទាសពាសពេញផ្លូវ គ្មានចេះគោរពច្បាប់ចរាចរ កន្លែងគេឱ្យដើរខ្លួនឈប់ផ្លូវគេ ឱ្យដើរទៅខ្លួនដើរមកផ្លូវគេឱ្យដើរមកខ្លួនដើរទៅ ។ល។ មនុស្សបែបនេះអន់ជាងសត្វស្មោញប្រវឹកជាដើម នោះទៅទៀត ។

ដូចនិយាយមកខាងលើនេះបញ្ជាក់ឱ្យឃើញច្បាស់ថាក្នុងសង្គមសត្វតិរច្ឆានដែលជាសង្គមអនាធិបតេយ្យ ឥតច្បាប់ទម្លាប់សោះនោះក៏មានឧត្ដមគតិ មានសេចក្ដីល្អខ្លះដែរ ដូចសង្គមសត្វស្រមោចកណ្ដៀរជាដើម

ជាសង្គមមាន សាមគ្គី និងសេចក្ដីព្យាយាមល្អប្រសើរ ជាងសង្គមមនុស្សខ្លះនោះដែរ ។

៣) សង្គមមនុស្ស

ការជួបជុំគ្នា ការរួបរួមគ្នា ការរស់នៅជាមួយគ្នាតាំងពីពីរនាក់ឡើងទៅហៅថាសង្គម ។ សង្គមមនុស្សជាសង្គមធំប្រសើរវិសេសជាង សង្គមរុក្ខជាតិ និងសង្គមសត្វតិរច្ឆាន ព្រោះមនុស្សមានសតិបញ្ញា មានការចេះដឹងស្គាល់ខុសត្រូវច្រើនបំផុត ជាងសត្វតិរច្ឆាននិងរុក្ខជាតិជាសង្គមមានច្បាប់ទម្លាប់មានអង្គការ មានបញ្ហាច្រើន ។

ពួកមនុស្សទាំងឡាយ ត្រូវការសង្គមជាចាំបាច់ជាងពួករុក្ខជាតិ និងពួកសត្វតិរច្ឆានទៅទៀតព្រោះលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្ដិសេដ្ឋកិច្ចទ្រព្យសម្បត្តិមាសប្រាក់វឌ្ឍនធម៌ សុជីវធម៌វប្បធម៌សីលធម៌ អារ្យធម៌ និងចំណីអាហារកើតមានមកពីសង្គមនេះឯង បើគ្មានសង្គមទេ លាភសក្ការៈជាដើមនោះ ក៏គ្មានក្នុងលោកនេះដែរ ។

## សង្គមជាប្រភពនៃលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិ

មនុស្សណាដែលមានចរិយាមារយាទល្អថ្លៃថ្នូរត្រឹមត្រូវមានមេត្តាករុណាជួយទុក្ខធុរៈរាប់អានមិត្រមនុស្ស ដែលនៅរួមក្នុងគ្រួសារក្នុងស្រុកភូមិ

ក្នុងប្រទេសឬក្រៅប្រទេស អ្នកដែលបានទទួលជំនួយ ទទួលការរាប់អានទាំងអស់នោះ តែងមានចិត្តស្រឡាញ់រាប់អានចែកជូនបូជា ដោយលាភសក្ការៈផ្សេងៗមានគ្រឿងឧបភោគបរិភោគបាយទឹកនំចំណីជាដើមចំពោះមនុស្សនោះវិញ ហើយតែងនិយាយអួតសរសើរកេរ្តិ៍ឈ្មោះគឺគុណនៃសេចក្តីល្អរបស់មនុស្សនោះឱ្យល្បីសុះសាយទូទៅ តែងគោរពកោតក្រែងលើកតម្កើង យសសក្តិ មនុស្សនោះឱ្យបានជាធំជាមេបាជាមិត្រទុកជាទីគោរពរៀងខ្លួន ។

បើមនុស្សនោះកើតក្រៅសង្គមនៅក្នុងទីស្ងាត់ តែម្នាក់ឯងគ្មាននរណានៅជិតទេ លាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិក៏គ្មានដែរ បើទុកជាមនុស្សនោះកើតមក បម្រុងនឹងមានលាភសក្ការៈកេរ្តិ៍ឈ្មោះយសសក្តិធំប៉ុណ្ណា ក៏ជាមនុស្សទទេព្រោះគ្មាននរណាផ្តល់លាភសក្ការៈឱ្យគ្មាននរណាគោរពកោតខ្លាច លើកតម្កើងឋានាគុណភាព យសសក្តិនោះ ។ សូម្បីមនុស្សដែលកើតនៅក្នុងសង្គមហើយ ប៉ុន្តែជាអត្តទត្ថបុគ្គល មានគំនិតចរិយាមារយាទ ក្រៅសង្គម គិតត្រឹមតែប្រយោជន៍ខ្លួនម្នាក់ឯងនោះក៏មិនអាចទទួលលាភសក្ការៈ កេរ្តិ៍ឈ្មោះ យសសក្តិឡើយ បែរជាបានទទួលការនិន្ទាតិះដៀលប្រមាថមើលងាយ អំពីពួកមនុស្សទៅវិញ ។

ដូច្នេះពួកមនុស្សកើតក្នុងសង្គម ដែលមានសេចក្ដីត្រូវការសង្គមជាចាំបាច់នោះត្រូវមានចិត្តគំនិតចរិយាមារយាទជាអ្នកសង្គមផងស្រឡាញ់សង្គម ជួយលើកតម្កើងសង្គមជាចាំបាច់ថែមទៀត គឺយើងត្រូវជួយសង្គមផង ទើបសង្គមជួយ យើងបាន ។

តើត្រូវជួយសង្គមបែបណា?សង្គមជួយយើងវិញបែបណា? ការជួយគ្នាទៅវិញទៅមកនោះយ៉ាងនេះ ។

ក-សង្គមគ្រួសារ ជាសង្គមថ្នាក់តូចបិតានិងបុត្រធីតាបើមាតាបិតាមិនបង្កើតបុត្រធីតា ឬមិនថែរក្សា មិនជួយទំនុកបម្រុងចិញ្ចឹមបុត្រធីតាឱ្យមានជីវិតរស់នៅទេ បុត្រធីតាពិតជាគ្មានបើគ្មានបុត្រធីតាហើយឋានៈមាតាបិតានោះក៏គ្មានដែរ ។ លុះតែយើងជួយឱ្យកើតជាកូនឡើងទើបកូនជួយយើងឱ្យកើតជាម៉ែ ឪ ដែរ បើមានកូន នឹងមានឋានៈជាម៉ែឪហើយប៉ុន្តែម៉ែឪនោះមិនជួយលើកតម្កើងកូន ឱ្យមានកេរ្តិ៍ឈ្មោះ យសសក្តិគឺមិនទំនុកបម្រុងឱ្យរៀនសូត្របានចេះដឹងមានឋានៈជាសេដ្ឋីគហបតីជានាម៉ឺនទេ កូននោះក៏មិនអាចជួយលើកតម្កើងម៉ែឪឱ្យថ្កើងមានឋានៈកេរ្តិ៍ឈ្មោះយសសក្តិ ជាម៉ែឪសេដ្ឋីគហបតីជាម៉ែឪឯកឧត្តមដែរ ។នេះជាការជួយសង្គមជួយយើងមួយបែប ។

ខ- សង្គមគ្រូនិងសិស្សជាសង្គមថ្នាក់កណ្ដាលក្នុងសង្គមនេះមានអ្នកបង្រៀនគឺគ្រូអាចារ្យ និងអ្នករៀនគឺសិស្ស និស្សិត ។ អ្នកដែលមានចំណេះវិជ្ជា អាចធ្វើជាគ្រូអាចារ្យបាននោះ បើមិនជួយបង្ហាត់បង្រៀនដោយយកចិត្តទុកដាក់ទំនុក បម្រុងល្មមឱ្យគេរៀនពីខ្លួនកើតទេ សិស្សនិស្សិតក៏គ្មានដែរ ។ ចំណែកសិស្សនិស្សិតវិញ បើមិនជួយគ្រូអាចារ្យគឺមិនយកចិត្តទុកដាក់ប្រតិបត្តិតាមដំបូន្មាន និងចំណេះវិជ្ជា ដែលគ្រូអាចារ្យបង្ហាត់បង្រៀននោះទេឋានៈសិស្ស និស្សិត ក៏គ្មានដែរ ។ រួមឱ្យខ្លីថា បើមានតែអ្នកបង្រៀនគ្មានអ្នករៀន ឬមានតែអ្នករៀនគ្មានអ្នកបង្រៀននោះ សង្គមគ្រូនិងសិស្សក៏គ្មានដែរ ។ នេះជាការជួយសង្គមសង្គមជួយយើងមួយបែប ។

គ- សង្គមជាតិ ជាសង្គមធំក្នុងសង្គមនេះមានរាស្ត្រមានអ្នករាជការ ឬអ្នករដ្ឋការ ។ អ្នករាជការ ឬអ្នករដ្ឋការ ត្រូវមានសេចក្ដីស្មោះត្រង់សុចរិតយុត្តិធម៌ ប្រព្រឹត្តឱ្យបានត្រឹមត្រូវតាមច្បាប់ទម្លាប់ ជួយរក្សាការពាររាស្ត្រតាមដំណើរ ច្បាប់ទើបរាស្ត្រមិនក្ដៅក្រហាយស្អប់ខ្ពើម មិនដកដេញចេញពីដំណែងឬក៏មិនឱ្យកើតអនាធិបតេយ្យ ខូចសង្គមជាតិ ។ឯពួករាស្ត្រក៏ត្រូវអ្នកជួយរាជការ ឬអ្នករដ្ឋការវិញគឺត្រូវមានចិត្តស្មោះ

ត្រង់បង់ពន្ធអាករ តាមច្បាប់ទម្លាប់ជួយរក្សា ការពារសម្បត្តិជាតិ មិនចូលជើង ដៃនិងសត្រូវរបស់សង្គមជាតិ ។ ការជួយគ្នាទៅវិញ ទៅមកយ៉ាងនេះឈ្មោះថាយើងជួយសង្គម សង្គមជួយយើងវិញ ។ បើគ្មានការជួយគ្នានេះទេគឺផ្អែកខាងរាស្ត្រគិតតែបំផ្លាញអ្នករាជការ ឬអ្នករដ្ឋការមានការស៊ុមក្រលុំយកសំណូកទៅសូក ឬលួចរត់ពន្ធគយជាដើម ។ ឯអ្នករាជការឬអ្នករដ្ឋការវិញ បែរជាឆ្មើងឆ្មៃមិនចង់មើលមុខនិយាយគួរសមចំពោះរាស្ត្រដែលគ្នាមិនបានមើលងាយ ជិះជាន់សង្កត់សង្កិនធ្វើបាបរាស្ត្រនោះដូចជាខ្ញុំកញ្ជះខ្ញុំនខំយកតម្រាប់តាមសម័យអាណានិគមមកប្រើក្នុងសង្គមជាតិខ្លួនដោយយកអំណាចច្បាប់ដែលមហាក្សត្រ ឬប្រមុខរដ្ឋបានប្រគល់ឱ្យធ្វើជាខែលបាំងមុខនោះ ឈ្មោះថានាំគ្នាបំផ្លាញសង្គមជាតិទៅវិញ និងឈ្មោះថាយើងកំពុងជីកឫសគល់របស់ខ្លួនបំផ្លាញខ្លួនយើងផងដែរ ព្រោះបើយើងមិនជួយសង្គមហើយ សង្គមក៏ជួយយើងមិនកើតដែរ ។

## សង្គមជាប្រភពនៃសេដ្ឋកិច្ច ទ្រព្យសម្បត្តិ មាសប្រាក់

ការងារមុខរបរទាំងឡាយមានកសិកម្ម ឧស្សាហកម្មពាណិជ្ជកម្មជាដើមសម្រាប់យកផលធ្វើជំនួញជួញដូរ លក់ទិញយកចំណេញគំនរទ្រព្យ

សម្បត្តិមាសប្រាក់ជាមុខសេដ្ឋកិច្ចនោះធ្វើម្នាក់ឯងមិនកើតឡើយ ព្រោះគ្មានអ្នកប្រើប្រាស់ បរិភោគ គ្មានអ្នកទិញគ្មានអ្នកលក់គ្មានអ្នកធានាគុណភាពធានាតម្លៃមានតែសង្គមនេះឯង ដែលអាចញ៉ាំងសេដ្ឋកិច្ចទ្រព្យសម្បត្តិមាសប្រាក់ឱ្យកើតឡើងបាន ដូចជាអ្នកលក់គ្រឿងឧបភោគបរិភោគ បើគ្មានសង្គមមនុស្សដែលជាអ្នកត្រូវការបរិភោគប្រើប្រាស់ទេគ្រឿងឧបភោគបរិភោគទាំងនោះដូចជាដុំដី ឬ ភក់ជ្រាំ គ្មានតម្លៃឡើយ ឱ្យគេទទេឥតយកថ្លៃក៏គ្មាន នរណាត្រូវការដែរ។ បើគ្មានអ្នកដទៃត្រូវការហើយកសិកម្ម ឧស្សាហកម្មពាណិជ្ជកម្មជាដើម ដែលជាមុខសេដ្ឋកិច្ចនោះ ក៏គ្មានដែរ គឺគ្មានរហូតដល់ទៅស្រែចម្ការចម្បារដំណាំគ្មានរោងឧស្សាហកម្ម គ្មានទីក្រុង គ្មានផ្សារ គ្មានកំពង់ផែ គ្មានផ្លូវគមនាគមន៍ គ្មានសម្ភារៈដឹកនាំទាំងឡាយមានរថយន្តជាដើម និងគ្មានសង្កាត់ភូមិស្រុកខេត្តឡើយ គឺអ្វីៗសូន្យទាំងអស់ មកអំពីគ្មានសង្គមមនុស្សនេះឯង ។

ម្យ៉ាងទៀតទ្រព្យសម្បត្តិ មាសពេជ្រប្រាក់រាប់កោដិ របស់ពួកមហាសេដ្ឋី បើគ្មានសង្គមអ្នកក្រជួយធានាគុណភាព ធានាតម្លៃទេគឺមានតែសេដ្ឋីម្នាក់ឯងកើតឡើងក្នុងលោកនោះ គំនរទ្រព្យសម្បត្តិ

មាសពេជ្រប្រាក់រាប់លានកោដិនោះ ដូចជាដុំដីព្រោះគ្មាននរណាត្រូវការចាយវាយប្រើប្រាស់ទេ ។

ដូច្នេះឃើញសភាវៈពិតច្បាស់ហើយថា ទ្រព្យសម្បត្តិ មាស ពេជ្រ ប្រាក់ទាំងអស់ក្នុងលោកនេះទោះជារបស់សេដ្ឋីគហបតីក្តីរបស់ធនាគារជាតិ ក្នុងរដ្ឋនានាក្តីដែលមានតម្លៃប្រើប្រាស់កើតអាស្រ័យសង្គមមនុស្ស ត្រូវការកើតមានឡើងដោយសង្គមមនុស្ស មានតែសង្គមមនុស្សទេ ជាម្ចាស់របស់ទ្រព្យសម្បត្តិទាំងនោះ និងជាអ្នកបង្កើតសេដ្ឋីគហបតីទាំងឡាយ ក្នុងលោក ជាពិសេសសង្គមអ្នកក្រ ជាមាតាបិតារបស់សេដ្ឋីគហបតីទាំងឡាយ ព្រោះអ្នកមានកើតពីអ្នកក្រ ។រួមសេចក្តីឱ្យខ្លីងាយយល់ជាពួកសេដ្ឋីគហបតី អ្នកមានទ្រព្យសម្បត្តិទាំងឡាយ ជាកម្មកររបស់សង្គមអ្នកក្រសម្រាប់ការប្រមែប្រមូល ទ្រព្យសម្បត្តិទុកកុំឱ្យរាត់រាយ ឯតម្លៃនិងគុណភាពទ្រព្យសម្បត្តិទាំងអស់នោះ នៅក្នុងកណ្តាប់ដៃសង្គមអ្នកក្រ អ្នកត្រូវការប្រើប្រាស់ ។

**សង្គមជាប្រភពនៃសុជីវធម៌ ខន្តីធម៌ ខប្បធម៌ សីលធម៌ និងអារ្យធម៌**

ដូចបាននិយាយខាងដើមហើយថា សង្គមមនុស្ស ជាសង្គមធំ មានច្បាប់ទម្លាប់ មានអង្គការ មានបញ្ហាច្រើនព្រោះមនុស្សម្នាក់ៗមាន

ចិត្តគំនិត មានចរិយាមារយាទផ្សេងៗគ្នាខ្លះល្អត្រឹមត្រូវខ្លះអាក្រក់ខិលខូច ។អ្នកធំមានយសសក្តិ អ្នកមានទ្រព្យសម្បត្តិ នៅជិតអ្នកតូចទ័លក្រឥតយសសក្តិឥតទ្រព្យសម្បត្តិ ឥតអំណាចនាំឱ្យមានការប៉ះទង្គិច សង្កត់សង្កិនជិះជាន់បៀវបៀនឆរបោក លួចប្លន់ កាប់សម្លាប់ បំផ្លិចបំផ្លាញគ្នា ដែលជាហេតុនាំឱ្យកើតសេចក្តីទុក្ខភ័យព្រួយវិនាសអន្តរាយមិនបានសុខក្នុងសង្គមមនុស្ស ។

អាស្រ័យហេតុ ដែលមនុស្សខ្លាចសេចក្តីទុក្ខព្រួយវិនាសអន្តរាយនេះហើយ ទើបនាំគ្នាបង្កើតច្បាប់ទម្លាប់ ឱ្យមានជាអង្គការ គឺ សុជីវធម៌ វឌ្ឍនធម៌ វប្បធម៌ សីលធម៌ និងអារ្យធម៌នេះឡើង ដើម្បីដោះស្រាយបញ្ហាសង្គមមនុស្ស ឱ្យរួចផុតពីការប៉ះទង្គិចជិះជាន់សង្កត់សង្កិនបៀតបៀនគ្នារវាងមនុស្សនិងមនុស្ស ។

ក) ដើម្បីបំបាត់នូវសេចក្តីទុក្ខព្រួយធុញទ្រាន់រំខានចិត្ត ដែលកើតអំពីការឥតសណ្តាប់ធ្នាប់ ឥតរបៀតរបប គ្មានការសមរម្យនោះគេបង្កើតឱ្យមានសុជីវធម៌ឡើង សម្រាប់ទូន្មានមនុស្សឱ្យស្គាល់ហេតុផលគួរមិនគួរស្គាល់ខ្លួននិងអ្នកដទៃស្គាល់ប្រមាណជីវភាពស្គាល់កាលសម័យស្គាល់ប្រជុំជននិងទីប្រជុំ និងស្គាល់មិត្រសម្លាញ់ ។ ផ្ទុយទៅវិញបើគ្មាន

សង្គមទេគឺក្នុងលោកនេះមានតែម្នាក់ឯងនោះសុជីវធម៌ក៏គ្មានដែរព្រោះគ្មានការចាំបាច់ ចំពោះសុជីវធម៌ឡើយ ។

ខ) ដើម្បីបំបាត់ចោលនូវហាយនភាពគឺដំណើរវិនាសអន្តរាយឬសេចក្តីសាបសូន្យថយចុះសេចក្តីសុខចម្រើនក្នុងសង្គម ដែលជាហេតុនាំឱ្យពួកមនុស្ស បានជួបប្រទះនូវសេចក្តីទុក្ខភ័យព្រួយក្រខ្សត់នោះគេបង្កើតឱ្យមានវឌ្ឍនធម៌ឡើងគឺនាំគ្នាខំបង្កើនចំនួនបង្កើនគុណភាព វត្ថុធាតុគ្រប់យ៉ាងដែលមនុស្សត្រូវការឱ្យចម្រើន ជឿនលឿនទាន់ចំនួនមនុស្សទាន់សេចក្តីត្រូវការ ដូចជាខាងគ្រឿងឧបភោគបរិភោគ ចំណេះដឹងចរិយាមារយាទជាដើម នាំគ្នាបង្កើនចំនួនបង្កើនគុណភាព បង្កើនកម្រិតឱ្យរីកសាយភាយបានច្រើន បានធំទូលាយ បានល្អខ្ពស់ប្រសើរឡើង ។ បើក្នុងលោកនេះ មានតែម្នាក់ ឯងគ្មានសង្គមមនុស្សទេ វឌ្ឍនធម៌ ក៏គ្មានដែរ ព្រោះគ្មានការចាំបាច់ចំពោះវឌ្ឍនធម៌ ។

## សង្គមជាប្រភពនៃចំណីអាហារ

ដូចបាននិយាយខាងដើមហើយថា ពួករុក្ខជាតិ ពួកសត្វតិរច្ឆាន និងពួកមនុស្សដែលចូលចិត្តរស់នៅជុំគ្នា ជាពួក ជាក្រុម ជាសង្គមនោះ គឺដើម្បីងាយរកចំណីអាហារចិញ្ចឹមជីវិតនេះឯង ។ បើក្នុងពិភពលោក

នេះមានមនុស្សតែម្នាក់ ឬមានសត្វតិរច្ឆានតែមួយ ឬក៏មានរុក្ខជាតិ តែមួយដើមនោះមនុស្សសត្វនោះ រុក្ខជាតិនោះ មិនអាចរស់នៅបានឡើយ មុខជាដាច់ពោះស្លាប់ឬងាប់ដោយគ្មានចំណីអាហារជាមិនខាន ។

ក) ពួករុក្ខជាតិជាចំណីអាហាររបស់រុក្ខជាតិ គឺពួកស្មៅឈើ វល្លិធំៗ ជាចំណីអាហាររបស់ពួកស្មៅឈើវល្លិតូចៗកាលបើពួកស្មៅឈើវល្លិធំៗ នោះស្រូបធាតុជីជាតិ ធាតុទឹកពីក្នុងដី ពីអាកាសមកបង្កើត ជាដើម មែក ស្លឹក ផ្កា ផ្លែហើយ វាជម្រុះសំបក មែក ស្លឹក ផ្កាផ្លែនោះទៅលើផែនដី រលួយកើតជាជីជាចំណីអាហាររបស់ស្មៅឈើវល្លិតូចៗផងជាម្លប់បាំងផែនដីឱ្យមានធាតុត្រជាក់សើមផងការពារខ្យល់ព្យុះសង្ឃរាផង រួមកម្លាំងគ្នាស្រូបធាតុទឹកពពក ពីអាកាសឱ្យកើតជា ភ្លៀងផង ។ ឯស្មៅឈើវល្លិតូចៗក៏ជាចំណីអាហាររបស់ស្មៅឈើវល្លិធំៗវិញមាន លំនាំដូចគ្នាដែរ ។

ខ) ពួកសត្វតិរច្ឆាន ក៏ជាចំណីអាហារគ្នានឹងគ្នាដែរ គឺសត្វតូចៗ ជាចំណីអាហារសត្វធំៗ ដូចយ៉ាងត្រីតូចជាចំណី អាហារត្រីធំជាដើម ឯសត្វធំៗក៏ជាចំណីអាហាររបស់សត្វតូចៗដែរ ដូចយ៉ាងដីរក្របី គោជាចំណីអាហាររបស់របោម រុយ មូស សុចជាដើម ។ បើមូសសុចនោះកើត

តែម្នាក់ឯងក្រៅសង្គមពិតជាដាច់ពោះស្លាប់ ។

គ) ពួកមនុស្សចាំចំណីអាហាររបស់មនុស្ស ពិតមែនតែក្នុងពិភពលោកនេះ មិនសូវមានមនុស្ស ស៊ីសាច់មនុស្ស ក៏មែនហើយ ប៉ុន្តែពួកមនុស្សមានករណីយកិច្ចចាំបាច់បំផុត ខាងការបង្កើតចំណីអាហារសម្រាប់មនុស្ស ។ សូមពិចារណា មើលចុះ មនុស្សគ្រប់ឋានៈទាំងអស់ក្នុងលោកនេះ មួយថ្ងៃៗមានការខ្វល់ខ្វាយតែអំពីរឿងចំណីអាហារនេះឯងព្រោះក្នុងមួយថ្ងៃមនុស្សត្រូវការបរិភោគចំណីអាហារ យ៉ាងមធ្យមបីដង ដូចជាក្នុងពិធីបុណ្យមួយៗទោះបុណ្យក្នុងសាសនាក្តីក្រៅសាសនាក្តី ដែលមានការរវល់ខ្វល់ខ្វាយធំបំផុតនោះ គឺរៀបចំធ្វើចំណីអាហារលៀងភ្ញៀវឬប្រគេនព្រះសង្ឃនេះផង ។ដើម្បីផ្គត់ផ្គង់ចំណីអាហារឱ្យបានគ្រប់គ្រាន់តាមសេចក្តីត្រូវការពួកមនុស្ស ខំនាំគ្នាធ្វើស្រែ ចម្ការច្បារដំណាំ ធ្វើ នេសាទ ចិញ្ចឹមសត្វធ្វើឧស្សាហកម្មពាណិជ្ជកម្មនិងធ្វើការបម្រើរដ្ឋ ដែលហៅថា ធ្វើការរដ្ឋគ្រប់ៗគ្នាដើម្បីប្តូរផលគ្នាទៅវិញ ទៅមកយកចំណីអាហារចិញ្ចឹមជីវិតរៀងៗខ្លួនគឺអ្នក ធ្វើស្រែចម្ការច្បារដំណាំ អ្នកនេសាទ និងអ្នកចិញ្ចឹមសត្វ យកផលឱ្យ អ្នកធ្វើឧស្សាហកម្មពាណិជ្ជកម្ម និងអ្នកធ្វើការរដ្ឋការៗយកផលប្តូរយកចំណីអាហារអំពីអ្នក

ធ្វើស្រែចម្ការ ជាដើមនោះ ។ បើគ្មានសង្គមទេ ចំណីអាហារក៏គ្មាន ព្រោះគ្មានអ្នកត្រូវការចំណីអាហារគ្មានអ្នកបង្កើតចំណីអាហារ ។

## សង្គមជាចំណីអាហាររបស់សង្គម

សម្លម្ជូរត្រកួនមួយឆ្នាំងកើតមក ពីសង្គមបីគឺ ម្ជូរ នឹងត្រកួនយកមកពីសង្គមរុក្ខជាតិ ត្រីនិងប្រហុកយកមកពីសង្គមសត្វតិរច្ឆានអ្នកបច្ចេកទេសខាងការផ្សំឱ្យកើតជាសម្ល យកមកពីសង្គមមនុស្សបើខ្វះសង្គមណាមួយ សម្លម្ជូរត្រកួនមួយឆ្នាំងនោះកើតឡើងមិនបានឡើយ ។

សម្លម្ជូរត្រកួននេះ ក៏ជាចំណីអាហាររបស់សង្គមទាំងបីដែរគឺដំបូងជាចំណីអាហាររបស់មនុស្ស សល់ពីមនុស្ស បានជាចំណីអាហាររបស់សត្វតិរច្ឆាន មានឆ្កែឆ្មាជ្រូកជាដើម សំណល់ឬលាមករបស់មនុស្សសត្វនោះ ឬក៏រូបកាយរបស់មនុស្ស សត្វ ដែលស៊ីសម្លម្ជូរនោះស្លាប់ទៅរលួយកើតជាជី បានជាចំណីអាហាររបស់រុក្ខជាតិ ដល់រុក្ខជាតិលូតលាស់ល្អឡើង មនុស្ស សត្វយកមកធ្វើជាចំណីអាហារទៀតចេះតែវិល កើតជាចំណីអាហារផ្តល់ឱ្យសង្គមត១គ្នាដូចកង់រទេះរកចុងដើមមិនឃើញ នឹងថាសង្គមរុក្ខជាតិជាចំណីអាហារ របស់សង្គមមនុស្សសត្វតិរច្ឆានក៏ថាមិនត្រូវនឹងថាសង្គមសត្វតិរច្ឆាន ជាចំណីអាហារ របស់សង្គមមនុស្ស និង



បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P.

សង្គមរុក្ខជាតិក៏ថា មិនត្រូវនឹងថាសង្គមមនុស្សជាចំណីអាហាររបស់សង្គមសត្វតិរច្ឆាន និងសង្គម រុក្ខជាតិក៏ថាមិនត្រូវដែរ ព្រោះជាចំណីអាហារទាំងអស់គ្នា ជាអ្នកស៊ីចំណីអាហារនោះទាំងអស់គ្នា ។ដើម្បីថាឱ្យត្រូវមានតែពាក្យមួយម៉ាត់ថា សង្គមជាចំណីអាហាររបស់សង្គម ឬថាសង្គមស៊ីសង្គម ហេតុអ្វី បានជាសង្គមជាចំណីអាហាររបស់សង្គម? សង្គមស៊ីសង្គមដូចម្តេច?

ដូចបាននិយាយខាងដើមហើយថា សង្គមទាំងបី កើតមកពីអវិជ្ជា និងសង្ខារដែលប្រមូលផ្តុំផ្សំផ្គុំធាតុ ដី ទឹក ភ្លើងខ្យល់អាកាសជាធាតុរាយ ជាធាតុសុទ្ធឱ្យរួមចូលគ្នា ជាពួក ជាក្រុមជាសង្គមនេះឯង ។

ឯធាតុដី ទឹក ភ្លើងខ្យល់អាកាសនោះមានការវិលទាក់ទងប្រាស្រ័យគ្នា ជាចំណីអាហារគ្នានិងគ្នាក្នុងសង្គមទោះបីដែលកើតឡើង អំពីធាតុដីទឹកភ្លើងខ្យល់អាកាសនោះក៏មានលំនាំវិលទាក់ទងប្រាស្រ័យគ្នា ជាចំណីអាហារគ្នានគ្នា និងគ្នាយ៉ាងនោះដែរគឺមានការកើតចាស់ឈឺស្លាប់ដូចគ្នា មានជីវិតដូចគ្នា ត្រូវការចំណីអាហារដូចគ្នា មានញីមានឈ្មោលដូចគ្នា ។ល។

សូមពិចារណាមើលចុះ! ពួកធាតុដីទឹកភ្លើង ខ្យល់អាកាសនោះមាន

ការកើតចាស់ ឈឺ ស្លាប់ មានជីវិត ត្រូវការ ចំណីអាហារ ជាចំណីអាហារ គ្នានិងគ្នា មានញីឈ្មោល ។ល។ ជាធម្មតារបស់ខ្លួនស្រាប់ដូចជាធាតុដី មានដីចាស់ គឺដីដែលកើតយូរហើយ ដីថ្មីគឺដីទើបនឹងកើត ដីឈឺ ដីស្លាប់ គឺដីដល់ខ្សោះក្រៀមរីងអស់ជីជាតិនឹងដី ដែលពុកផុយហុយ ប៉ើងអស់ទៅ ដីមានជីវិតគឺដីដែលចេះតែដុះចម្រើនឡើង ដីត្រូវការ ចំណីអាហារ គឺដីដែលត្រូវការជីជាតិ ធាតុទឹក ដី ជាចំណីអាហារគ្នា និងគ្នា គឺដីជីជាចំណីអាហាររបស់ដី ឥតជីជាតិ ដីខ្ពស់ ជាចំណីអាហារ របស់ដីទាបអាស្រ័យហេតុធាតុដីចេះស៊ីចំណីអាហារដូច្នេះទើបមានពាក្យ ចាស់ថា ចំណីដី អាចម៍ដី ដីញី ដីឈ្មោលគឺដីដែលមានធាតុញី ឈ្មោល អាស្រ័យនៅ ។ ចំណែកខាងធាតុទឹក ភ្លើង ខ្យល់អាកាសទៀតក៏មាន ការកើត ចាស់ ឈឺ ស្លាប់ ជាដើម ទំនងដូចធាតុដីដែរ ។

កាលបើអវិជ្ជាសង្ខារ ផ្សំផ្គុំធាតុទឹកភ្លើងខ្យល់អាកាសនេះបង្កើត ជាសង្គមហើយការកើតចាស់ឈឺស្លាប់ជាដើមនោះក៏មានសភាពកាន់តែ ច្បាស់ឡើងៗជាលំដាប់ ដូចជាសង្គមរុក្ខជាតិមានឈើកើត គឺឈើទើប នឹងដុះ ឈើចាស់គឺឈើដែលដុះយូរហើយឈើឈឺគឺឈើដែលមានមេ ស៊ី មានដង្កូវចៃរូបរីកជញ្ជក់ស្រូបរសជាតិធ្វើឱ្យអស់ជិតក្រៀម ដុះលូត

លាស់មិនបានល្អ ឈើស្លាប់គឺឈើងាប់លែងដុះលូតលាស់តទៅទៀត ឈើមានជីវិត គឺឈើកំពុងរស់នៅ នឹងមានមេ ឈើពូជឈើ កូនឈើ ឈើញីឈើឈ្មោល ។ល។ ឯការស្រេកឃ្លានចំណីអាហាររបស់ឈើ ក៏កាន់តែច្បាស់ឡើង ជាងធាតុ នៅរាត់រាយ ដែលជាតួទឹកដីភ្លើងខ្យល់ អាកាសសុទ្ធៗនោះ ។លុះដល់រុក្ខជាតិចម្រើនមកជាសង្គមសត្តិរច្ឆានជា សង្គមមនុស្ស ហើយការកើតចាស់ឈើស្លាប់ការស្រេកឃ្លាន ភេទញី ឈ្មោលជាដើមនោះ កាន់តែច្បាស់ទាំងសកម្មភាព ។ បើគេបញ្ជាក់ចង់ ដឹងថែមទៀត ថាហេតុអ្វីបានជាមនុស្សសត្វនឹងរុក្ខជាតិមានការកើត ចាស់ឈឺស្លាប់? មានជីវិត? មានការស្រេកឃ្លាន? មានសេចក្ដីត្រូវការ ស៊ីជាចំណីអាហារ? នឹងមានញីមានឈ្មោលនោះ? គេអាចដឹងបានយ៉ាង ងាយថារូបរាងកាយចិត្តវិញ្ញាណរបស់និងរុក្ខជាតិនោះ គឺធាតុទឹកដីភ្លើង ខ្យល់អាកាសនោះឯង បែកគ្នាត្រង់ដីទឹកភ្លើងខ្យល់អាកាសជាធាតុសុទ្ធ (Corps simple) មនុស្សសត្វនិងរុក្ខជាតិជាធាតុផ្សំ (Corpscompose) ដែលសង្ខារគឺចលនានៃធាតុបានផ្សំឡើងប៉ុណ្ណោះ ។ ហេតុដែលនាំឱ្យ មនុស្សសត្វ និងរុក្ខជាតិមានការកើតចាស់ឈឺស្លាប់ព្រោះធាតុសុទ្ធ ដែល ជាវត្ថុធាតុដើម (Maliere lire) នោះ មានការកើតចាស់ឈឺស្លាប់ដែរ

។ហេតុដែលនាំឱ្យមនុស្សសត្វរុក្ខជាតិមានជីវិតមានការស្រេកឃ្លានមានសេចក្ដីត្រូវការស៊ីផ្ការជាចំណីអាហារនិងមានញីឈ្មោលនោះព្រោះធាតុសុទ្ធ ដែលជាវត្ថុដើម មានជីវិតមានការស្រេកឃ្លាន មានការស៊ីផ្ការជាចំណីអាហារ និងមានញីឈ្មោលដែរ ។

អាស្រ័យសភាវៈពិតបែបនេះទើបព្រះអរហន្តសម្មាសម្ពុទ្ធជាអគ្គមហាទស្សនវិទូ ព្រះអង្គបានធ្វើសន្និសីទប្រកាសសភាវៈពិតនេះ ក្នុងចំណោមមនុស្សលោកនិងទេវតាជាច្រើនផង ដូចក្នុងព្រះសូត្រទាំងឡាយមានសតិបដ្ឋានសូត្រជាដើម ជាពិសេសក្នុងធាតុប្បច្ចវេក្ខណវិធី ដែលជាវិធីមួយរបស់អ្នកបួសក្នុងព្រះពុទ្ធសាសនា ត្រូវពិចារណារាល់ពេលទទួលបរិភោគប្រើប្រាស់នូវបច្ច័យទាំង ៤ ដូចក្នុងពេលទទួលចង្ហាន់ជាដើម ឱ្យពិចារណាថា"**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ** " សេចក្ដីថា ចង្ហាន់បិណ្ឌបាត គឺចំណីអាហារនេះ ជាធាតុដីទឹកភ្លើងខ្យល់អាកាសពិត គ្រាន់តែប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យឯរូបអាត្មាអញ ដែលទទួលបរិភោគនូវចង្ហាន់នេះក៏ជាធាតុដែរមិនមែនមនុស្សសត្វមិនមែនខ្លួនប្រាណ តែងតែសោះសូន្យបាត់បង់ទៅដូចគ្នា ។

ក្នុងអត្ថបទនេះ មានន័យច្បាស់លាស់ថា មនុស្សសត្វ រុក្ខជាតិ និង ដីទឹកភ្លើងខ្យល់អាកាសជាធាតុដូចគ្នា មិនមែន មនុស្សសត្វ មិនមែនខ្លួនប្រាណឡើយ ។

បើគេចង់ដឹងថាមនុស្សជាធាតុដីទឹកភ្លើងខ្យល់ អាកាសមែន ឬ មិនមែននោះគេយករូបមនុស្សម្នាក់មកពិនិត្យ រាវរកឃើញយ៉ាងងាយ គឺត្រង់ឆ្អឹងរឹងៗជាធាតុដី បើគេចង់ឃើញច្បាស់ភ្លាមៗ គ្រាន់តែយកដៃដុសលើស្បែកបន្តិច និងឃើញដីពិតៗដែលធ្លាប់ហៅថាក្អែលឯទឹកមាត់ ទឹកសំបោរជាដើមក្នុងខ្លួនមនុស្សនោះ ជាធាតុទឹកកម្តៅក្នុងខ្លួនមនុស្ស ដែលគេស្ទាបទៅក្តៅៗនោះជាធាតុភ្លើង ខ្យល់ដង្ហើមចេញចូល ជាធាតុខ្យល់ទីស្រឡះក្នុងរន្ធត្រចៀកច្រមុះមាត់ជាដើមនោះ ជាធាតុអាកាស កាលបើរូបកាយមនុស្សនោះស្លាប់ទៅរលួយរលាយកើត ជាដី ទឹកភ្លើង ខ្យល់អាកាស ដែលជាធាតុសុទ្ធដូចដើមវិញ។ ត្រង់ពាក្យថា មនុស្សសត្វ រុក្ខជាតិគ្រាន់តែសន្មតហៅតាមភ្នែកឃើញកុំច្រឡំគ្នានិងដីទឹកភ្លើង ខ្យល់អាកាស ដែលជាធាតុសុទ្ធប៉ុណ្ណោះ ។ ដូចជាគេយកដីមកសូនធ្វើរូបមនុស្សសត្វ និងថាមនុស្សសត្វពិតៗក៏ថាមិនត្រូវ ព្រោះវាជាដី និងថាដីពិតៗក៏ថាមិនត្រូវ ព្រោះជារូបមនុស្សសត្វ ។

ត្រង់ចំណុចនេះហើយ ដែលមានន័យសំខាន់បំផុតក្នុងទ្រឹស្តីព្រះពុទ្ធសាសនាសម្រាប់មនុស្សលោក បើមនុស្សលោកបានដឹងយល់ច្បាស់លាស់ថា មនុស្ស សត្វ ជាធាតុដីទឹក ភ្លើង ខ្យល់ អាកាសពិតៗមិនមែនមនុស្សសត្វ មិនមែនខ្លួនប្រាណហើយអស្មិមានៈគឺសេចក្តីប្រកាន់ថាអញថាយើងថាគេនោះក៏គ្មានដែរលោភៈទោសៈមោហៈដែលហៅថាប្រភពនៃអំពើអាក្រក់គ្រប់យ៉ាង មានការស៊ីសំណូក លួចប្លន់កេងកិបឈ្លោះប្រកែកកាប់ចាក់ធ្វើសង្គ្រាមសង្កត់សង្កិនជិះជាន់គ្នាទៅវិញ ទៅមកនិងសេចក្តីស្នេហាស្រឡាញ់ស្អប់ក៏គ្មានដែរ ព្រោះដឹងស្គាល់យល់ឃើញ ពួកមនុស្សសត្វទាំងអស់សុទ្ធតែជាធាតុ ដីទឹកភ្លើងខ្យល់អាកាសពិតៗទៅហើយ ។ អ្នកដែលមានគំនិតយល់ឃើញច្បាស់តាមសភាវៈពិតដូច្នេះ ជាអ្នកមានប្រាជ្ញាខ្ពង់ខ្ពស់ អាចបំបាត់ចោលនូវការឈឺចាស់កើត ស្លាប់ ក្នុងលោកធាតុនេះ ទៅនៅក្នុងឋានព្រះនិព្វាន ដែលជាទីគ្មានការកើត ចាស់ ឈឺ ស្លាប់បាន ព្រោះឋានព្រះនិព្វាននោះជាអលោកធាតុគ្មានទាក់ទងចំពោះធាតុ ដី ទឹក ភ្លើង ខ្យល់អាកាសជាតួអវិជ្ជា សង្ខារឡើយ ។

# ជំពូកទី២

## សេដ្ឋកិច្ចនិងមនុស្ស

"ព្រះពុទ្ធសាសនា ជាសាសនាមួយដែលបង្រៀនឱ្យស្រាយបញ្ហាសាបសូន្យតម្លៃសីលធម៌, តែក៏ពុំបានមើលហួស ឬរំលងបញ្ហាសេដ្ឋកិច្ច ។បង្រៀនឱ្យស្រាយសេចក្តីអាក្រក់ដោយសេចក្តីល្អ ។ព្រមគ្នានេះបង្រៀនឱ្យស្រាយបញ្ហាដែលមានចោទលើខ្លួនជាមុន កុំរស់នៅក្នុងគំនិតឃឹតគំនិតបណ្តែតបណ្តោយ ទុកពេលឱ្យ មនុស្ស ក្នុងពិភពលោកគេធ្វើសេចក្តីល្អទាំងអស់មុនខ្លួនហើយខ្លួនសម្រេចចិត្តធ្វើទង្វើល្អជាចុងក្រោយបំផុត ។សូម្បីបង្រៀនឱ្យមានមេត្តាចិត្តក៏ឱ្យហ្វឹកហាត់ ផ្សាយមេត្តាដល់ខ្លួនឯងមុន ដើម្បីបានជាសក្ខីភាពថាអាត្មាអញស្រឡាញ់សុខស្អប់ទុក្ខយ៉ាងណា ជនដទៃ ក៏គេស្រឡាញ់សុខស្អប់ទុក្ខយ៉ាងនោះដែរ" ។

ដើម្បីងាយស្រួលដល់ការពិចារណា របស់អ្នកអានក្នុងរឿងនេះខ្ញុំសូមញែកសេចក្តីក្នុងបទនេះចេញជា ៣ ចំណុចគឺ :

**១**- បង្រៀនមិនឱ្យមើលហួសឬរំលងបញ្ហាសេដ្ឋកិច្ច

**២**- ស្រាយចំណងអាក្រក់ដោយចំណងល្អ

**៣**-កុំមើលហួស ឬរំលងខ្លួនឯងក្នុងការដោះស្រាយបញ្ហាសីល

ធម៌នេះជាគោលការណ៍សំខាន់ក្នុងបទនេះសម្រាប់ជនស្រាយបញ្ហាជីវិត ដែលពុទ្ធសាសនារបស់យើងបានផ្ដល់គំនិតនឹងគម្រោងឱ្យបុគ្គលអ្នកមានចិត្តចង់ធ្វើចង់អនុវត្តន៍ បានជួបប្រទះនូវភាពងាយស្រួល បើតិចក៏ច្រើនតាមកម្ពស់នឹងទំនាបនៃគំនិតឧបនិស្ស័យរបស់ខ្លួននៃមនុស្សម្នាក់ៗដែលអ្នកស្រាវជ្រាវផ្នែកនេះមានគំហើញថា ព្រះពុទ្ធបរមគ្រូពិតជាមានព្រះមហាករុណាទិគុណ ដល់សត្វលោកគ្មានអ្នកណាអាចបដិសេធបានឡើយ ។ បង្រៀនមិនឱ្យមើលហួសបញ្ហាសេដ្ឋកិច្ច ក្នុងបណ្ដាបញ្ហាទាំងឡាយដែលមានចោទដល់ជីវិតមនុស្ស ។ បញ្ហាសេដ្ឋកិច្ចគឺជាបញ្ហាចោទមុន, ចោទរឿយៗចោទខ្លាំងៗហើយជាបញ្ហាសំខាន់ជាងបញ្ហាដទៃទៀតផង ។ ព្រោះអ្វី? ព្រោះមនុស្សយើងទាំងអស់គ្នា ត្រូវចោទដោយបញ្ហានេះមិនត្រឹមតែក្នុងពេលសម្រាល ចាកផ្ទៃម្ដាយហើយទេ ។ ការរស់នៅក្នុងពោះម្ដាយក៏ត្រូវចោទដោយបញ្ហានេះ ដែលយើងមិនទាន់ចេះដឹងមិនទាន់ចេះដោះស្រាយ អ្នកមានគុណរបស់យើង លោកដោះស្រាយជំនួស ។ចំណោទទាំងឡាយមានភាពរស់, ភាពលំបាក, លំនៅឋាន, ស្បៀងអាហារ, គ្រឿងស្លៀកពាក់, គ្រឿងឱសថ, គ្រឿងឧបករណ៍នៃការងាររបស់កណ្ដាលគឺមាសប្រាក់កែវកង សម្រាប់ចាយវាយសម្រាប់ប្រដាប់

តុបតែងខ្លួនប្រាណសម្រាប់បំពេញសេចក្តីត្រូវការបំបាត់កង្វះខាត ។ល។

បើអ្នកអានបានមើលតម្រាសេដ្ឋកិច្ច របស់អ្នកប្រាជ្ញ ផ្នែកសេដ្ឋកិច្ចក្នុងបស្ចឹមប្រទេសច្រើន ៗ អ្នកអាននឹងមានមនោសញ្ចេតនាត្រូវក្នុងចំណុចមួយថា វត្ថុបំណងរបស់សេដ្ឋកិច្ចនោះបានដល់កំហិតបាត់ ឬ ស្នងសេចក្តីត្រូវការរបស់មនុស្ស(To try, satisfy human wants) .ពុទ្ធសាសនា បានស្នើគំនោលសីលធម៌ជាប់ទាក់ទងដល់គំនោលសេដ្ឋកិច្ច មានពីរស្ថានគឺ: ជាន់ទាបជាគំនោលស្នង (To satisfy ) ។ ជាន់ខ្ពស់ជាគោល(Tosubdue) ។គំនោលស្នងដៅដល់ការបង្រៀនមនុស្ស ឱ្យគេខំប្រឹងតាំងខ្លួនពង្រឹងជំហរ ឱ្យមាំមួនរឹងពឹងក្នុងឋានៈសេដ្ឋកិច្ច ព្យាយាមលើកឋានៈរបស់ខ្លួន ឱ្យរស់នៅក្នុងកម្រិតខ្ពស់ ប្រកបដោយកំហឹងនឹងសំនួរយ៉ាងមោះមុត ជាមួយនឹងកម្មវិធីដទៃៗទៀត ។ចំណែកគំនោលបំបាត់នោះដៅដល់ឱ្យការ កំចាត់បង់ឬបន្ថយសេចក្តីត្រូវការ ដែលមានកម្លាំងខ្លាំងពេកដែលអាចក្លាយទៅជាតណ្ហាទូលំទូលាយគ្មានកំណត់ព្រំដែន ត្រឡប់ផ្តល់ឱ្យនូវសេចក្តីទុក្ខទៅវិញគឺថា បើមនុស្សយើងចេះតែពុលចេះតែស្រវឹងសេចក្តីសប្បាយ ហើយខំស៊ុះស្វាស្វែងរករបស់ស្នង របស់ត្រូវការយកមកបម្រើចំណង់របស់ខ្លួនម្នាក់ៗ ដោយគ្មានខ្ចី

រវល់ដល់សេចក្ដីទុក្ខព្រួយខ្វះខាតរបស់អ្នកដទៃគ្មានគំនិតព្រហ្មវិហារធម៌ គ្មានសម្បជញ្ញៈនៃមនុស្សជាតិនោះ ។ ចំណង់របស់គេវារឹតតែគ្មានចេះចប់ គ្មានចេះល្មមទីបំផុតអ្នកបម្រើសេចក្ដីសប្បាយ (តណ្ហា) របស់ខ្លួន វាមិនត្រឹមតែសប្បាយខ្លួនឯង ភ្លេចទុក្ខព្រួយ របស់អ្នកដទៃប៉ុននឹងទេ គឺវាបញ្ជាឱ្យប្រព្រឹត្តនូវទង្វើជិះជាន់បៀតបៀន អ្នកដទៃ ដើម្បីសេចក្ដីសប្បាយរបស់ខ្លួន ។ លោកឱ្យន័យថាតណ្ហាបើគេកាន់តែធ្វើខ្ញុំវាកាន់តែច្រើន វាក៏កាន់តែមានកម្លាំងខ្លាំងឡើងៗដូចគ្នានឹងភ្លើងបើគេចេះតែបន្ថែមអុសបន្ថែមប្រេងគ្មានឈប់វាក៏ចេះតែឆេះខ្លាំងឡើងៗ គ្មានពេលរលត់សោះឡើយ ។ ឬពុំនោះសោត ក៏ដូចគ្នានឹង មហាសមុទ្រដែលគ្មានទឹកពេញប្រៀបឡើងច្រាំងដោយចំណាក់នៃទឹកស្ទឹងទន្លេ ឬ ចំណាក់នៃទឹកភ្លៀងដែលមានជាប្រក្រតី ខួបប្រាំងខួបវស្សា ។ ព្រោះហេតុនេះទើបត្រូវមានគំនោលលុបបំបាត់បន្តិចម្ដងៗឬបន្ធូរបន្ថយតណ្ហាខ្លះ កុំចេះតែបណ្ដោយឱ្យទៅគ្មានទំនប់គ្មានកំណត់ព្រំដែនដែលអាចដួចសុខទៅជាទុក្ខ ពេលណាមួយមិនខានឡើយ ។

-បង្រៀនអំពីគំនោលសេដ្ឋកិច្ចជាន់ទាប គំនោល ឬគំរោងបង្រៀន នៃពុទ្ធសាសនាដែលគេបានឃើញថាមានការទាក់ទងជាមួយ

និងសេដ្ឋកិច្ចផ្ទាល់ ខ្លួនរបស់មនុស្សម្នាក់ ៗ ឬគ្រួសារជាទូទៅគឺ:

**១-ទិដ្ឋធម្មិកត្ថ: (ប្រយោជន៍បច្ចុប្បន្ន) បានដល់ការបង្រៀនឱ្យគាំទខ្លួននៅក្នុងឋាន:ម៉ាំងាំតាមផ្លូវសេដ្ឋកិច្ចប្រកបដោយអង្គ ៤ ប្រការគឺ:**

ក-ការសំភីសង្វាតស្វែងរកទ្រព្យគ្រប់ប្រភេទទាំងមានរូប ទាំងគ្មានរូប.....

ខ-ការចេះស្គាល់របៀបទុកដាក់ទ្រព្យសម្បត្តិឬចេះសន្សំចេះសំចៃ..

គ-ការចេះសេពគប់នឹងមិត្តសម្លាញ់មានចរិយាថ្លៃថ្នូរ ឬ ចេះច្នៃមិត្តអាក្រក់ឱ្យបានជាមិត្តល្អ..

ឃ-ការចេះចាយវាយឱ្យសមល្មមដល់ឋាន: នៃទ្រព្យសម្បត្តិឬ ចេះរៀនរស់ក្នុងភាពសន្តោសឬភាពល្មមគ្រប់គ្រាន់ជានិច្ច. ។

**២- ការវៀរចាកអបាយមុខ (ហេតុនាំឱ្យសូន្យទ្រព្យ) ៤ប្រការគឺ:**

ក- ជាអ្នកប្រព្រឹត្តល្បែងបុរស ស្ត្រី.

ខ- ជាអ្នកប្រព្រឹត្តល្បែងផឹកសុរា.

គ- ជាអ្នកប្រព្រឹត្តល្បែងស៊ីសង.

ឃ-ជាអ្នកគប់មិត្តអាក្រក់ ដោយគ្មានកែគ្មានច្នៃឱ្យល្អសិនជាមិត្ត ។

អ្នកអានគប្បីធ្វើការកត់សម្គាល់ថា អបាយមុខដែលគេគួរវៀរ

ចាកទាំង៤ប្រការនេះ លោកសម្តៅយក ពាក្យលេង ឬ មានលក្ខណៈលេងជាធំ គឺអ្នកប្រព្រឹត្តមានគំនិតជាលេង រហូតដល់មានទម្លាប់ប្រកបកម្មនោះរឿយៗ ជានិច្ចជាប្រក្រតីលុះត្រាញៀនលែងមិនរួច.ឈប់មិនកើត ។ ក្នុងទីបំផុតត្រូវគេឱ្យឈ្មោះថា អ្នកស្រីនាងប្រុស អ្នកប្របឹកអ្នកបាំងផ្អិត អ្នកពូកម៉ាក ។

**៣-សុខរបស់គ្រហស្ថ៤ប្រការគឺ:**

ក-សុខកើតអំពីការមានទ្រព្យ(ដោយធ្វើការរបស់ខ្លួន)

ខ- សុខកើតអំពីបានចាយវាយទ្រព្យសម្បត្តិផ្ទាល់ខ្លួន

គ-សុខកើតអំពីការគ្មានជំពាក់បំណុលគេ

ឃ-សុខកើតអំពីប្រកបអាជីវកម្មដែលគ្មានទោស ។

ក្នុងចំណុចនេះ.បញ្ជាក់ឱ្យឃើញនូវសេចក្តីសំខាន់នៃធាតុសេដ្ឋកិច្ចត្រង់ថា មានទ្រព្យដោយកម្លាំងខ្លួនចាយវាយទ្រព្យសម្បត្តិផ្ទាល់ខ្លួនគ្មានជំពាក់បំណុលគេធ្វើការអាជីវកម្មត្រឹមតាមក្បួនសេដ្ឋកិច្ចគ្មានល្មើសច្បាប់រដ្ឋ គ្មានជិះជាន់កម្លាំងអ្នកដទៃ ។

**៤-ត្រកូលស្តុកស្តម្ភមាំមួននឹងតាំងនៅយូរមិនបានព្រោះហេតុ ៤ ប្រការគឺ:**

ក-របស់ណាបាត់ទៅ មិនរកមកវិញ

ខ- របស់ណាទ្រុឌទ្រោមដាច់ដាច មិនជួសជុលជាថ្មី.

គ-គ្មានចេះដឹងស្គាល់ប្រមាណក្នុងការប្រើប្រាស់ទ្រព្យ.

ឃ- ប្រគល់មុខងារធំដុំក្នុងគ្រួសារឱ្យស្ត្រី ឬបុរសគ្មានសីល គ្មានវិន័យ.... ទុកដាក់ទ្រព្យ ។

គំនោលនេះបញ្ជាក់ឱ្យឃើញថា ត្រកូលមួយ ៗទោះជាមានភាពស្តុកស្តម្ភមាំមួន នៅក្នុងកម្រិតខ្ពង់ខ្ពស់យ៉ាងណា ក៏ដោយបើខ្វះចំណេះខ្វះដំណឹងក្នុងគំនោលនៃសេដ្ឋកិច្ច នឹងសីលធម៌ដែលគេត្រូវស្គាល់ត្រូវប្រព្រឹត្តប្រតិបត្តិឬអនុវត្តដូចធ្លាប់មានមកក្នុងលោកនេះហើយក៏ស្ទុះមិនរួចពីធ្លាក់ដុនដាបក្នុងទីបំផុតឡើយ ។

ខ្ញុំសូមបញ្ជាក់ថា គំនោលនៃប្រយោជន៍ក្នុងបច្ចុប្បន្ន របស់ពុទ្ធសាសនាទី១គឺកំហិតក្នុងការប្រកបអាជីវកម្ម ឱ្យកើតឱ្យមានទ្រព្យសម្បត្តិនោះត្រូវគ្នានឹងគំនោលសេដ្ឋកិច្ចជាបឋមគឺProduction(ផលិតកម្ម)ដូចបានណាត់បាននិយាយគ្នាទុកជាមុនព្រោះវិជ្ជាសេដ្ឋកិច្ច ទើបតែនឹងកើតខាងក្រោយពុទ្ធសាសនា តាមស្មានប្រហែលជាងមួយពាន់ឆ្នាំ ។

ចំណែកគំនោលទី២គឺការចេះដឹងស្គាល់របៀបទុកទ្រព្យសម្បត្តិដែលគេរកបានមកហើយត្រូវគ្នានឹងគំនោលសន្សំ ឬសំចៃទ្រព្យសម្បត្តិ

(Saving) ។ គំនោលទី៣ គឺការចេះគប់មិត្តមានចិត្តស្មោះត្រង់ មានសេចក្តីវៃឆ្លាត មានគំនិតជួយគ្នាទៅវិញទៅមក ។ គំនោលនេះប្រៀបបាននឹងអង្គការសមាគម ឬ បរិស័ទឬសហករណ៍ដែលមានការចាំបាច់ត្រូវជ្រើសរើសរកបុគ្គលដែលមានឧត្តមគតិខ្ពស់នៅ ក្នុងចំណោមបុគ្គលជាសមាជិកដើម្បីចាត់ការឬដឹកនាំសមាគម.............ក្នុងឋានៈជាក្រុមអភិបាលឬគណៈកម្មការនាយក នៅក្នុងក្របខ័ណ្ឌនៃកាអភិវឌ្ឍជីវភាពរបស់សមាជិក ដោយប្រកាន់យកប្រយោជន៍រួមជាធំ ។ចំណែកគំនោលចុងក្រោយបង្អស់គឺការប្រើប្រាសចាយវាយទ្រព្យសម្បត្តិ នៅក្នុងកម្រិតរស់ឋានៈរបស់ខ្លួន ឬរស់នៅត្រឹមតែរស់នោះ ក្នុងភាសាសេដ្ឋកិច្ចគេប្រើពាក្យ ះៀសរ ហ្សលដ្បុងងតេ ប្រែថា ថវិកាប្រចាំគ្រួសារនេះជាផ្លូវឯកជន ។ បើជាផ្លូវរដ្ឋគេ ហៅថា The nation economie budget ប្រែថា ថវិកាសេដ្ឋកិច្ចនៃជាតិ ។និយាយខ្លី.បានដល់ការពិនិត្យត្បិតត្បៀតចំណូលចំណាយឱ្យមានតុល្យភាពស្មើគ្នា ត្រូវពាក្យពុទ្ធសាសាថា <u>សមជីវិតា</u> ដែលមានចែងក្នុងទិដ្ឋ ធម្មិកត្ថៈ ( ប្រយោជន៍ក្នុងបច្ចុប្បន្នហ្នឹងឯង) ។

ចំណែកខាងគំនោលបង្រៀនដទៃៗទៀត ដូចជាវៀរចាកភាពខាតបង់ទ្រព្យសម្បត្តិ ( អបាយមុខ) គ្រប់ប្រភេទការស្គាល់ថា អ្វីជា

សេចក្ដីសុខរបស់គ្រហស្ថ ការធ្វើឱ្យត្រកូលមានស្ថេរភាពអស់រយៈការយូរអង្វែង ទាំងអស់នេះជាសេដ្ឋកិច្ចមួយទៀត ដែលត្រូវជាគូជាមួយនឹងសីលធម៌ ។ ក្នុងចំណុចនេះបញ្ជាក់ឱ្យដឹងថាពុទ្ធសាសនាបានមើលឃើញយ៉ាងច្បាស់ហើយសីលធម៌របស់មនុស្សលំបាក នឹងមានណាស់បើសេដ្ឋកិច្ចផ្ទាល់ខ្លួន នៃមនុស្សម្នាក់ៗពុំមានវឌ្ឍភាពឬពុំបានប្រព្រឹត្តទៅក្នុងភាពល្អថ្លៃថ្នូរ ។ ដោយអាស្រ័យហេតុនេះ ទើបព្រះសម្មាសម្ពុទ្ធបង្រៀនសង្កត់ធ្ងន់ទៅលើសេដ្ឋកិច្ចរដ្ឋ នឹងសេដ្ឋកិច្ចគ្រួសារ នៅក្នុងក្របខ័ណ្ឌសាងជំហរ គឺធ្វើយ៉ាងណាឱ្យរដ្ឋនិងឯកជនមានសេដ្ឋកិច្ចស្ថិតនៅក្នុងកម្រិតខ្ពស់ឬមធ្យម តាមដែលអាចធ្វើទៅកើត ។

ដើម្បីឆាប់យល់អ្នកអានគប្បីពិនិត្យមើលឡើងវិញនូវរឿងមួយមានមកក្នុងគម្ពីរពុទ្ធសាសនារបស់យើងដែលមានដំណាល ថាថ្ងៃមួយព្រះសម្មាសម្ពុទ្ធព្រះអង្គបានណែនាំកូដទន្តព្រាហ្មណ៍ ដែលគាត់បានធ្វើសំនួរចំពោះព្រះអង្គអំពីបញ្ហាបូជាយញ្ញ ព្រះសម្មាសម្ពុទ្ធពុំបានឱ្យចម្លើយចំណុចនៃបញ្ហានេះទេ. តែព្រះអង្គបានឆ្លៀតឱកាសបំភ្លឺព្រាហ្មណ៍នោះក្បែរៗសំនួររបស់គាត់ថា ខ្លួនអ្នកជាបុគ្គលមានមុខងារគ្រប់គ្រងរក្សាពួកព្រាហ្មណ៍ក្នុងស្រុកមានភូមិមានសង្កាត់ច្រើន ។ អ្នកជាមនុស្សម្នាក់

ដែលព្រាហ្មណ៍ទាំងអស់ទទួលស្គាល់.ទទួលស្តាប់ឱវាទដំបូន្មាន ។អ្នកត្រូវចាត់ការសេដ្ឋកិច្ចក្នុងស្រុកនេះ ឱ្យបានត្រឹមត្រូវ មានវឌ្ឍនភាពខ្ពស់មានស្ថេរភាពនឹងន នៅក្នុងកម្រិតល្អប្រសើរមុនដែលខ្លួនអ្នកនឹងត្រូវធ្វើអ្វីៗទៀត ។ម្នាលព្រាហ្មណ៍!កម្មវិធីបំរាបចោរកម្មគេមិនត្រូវធ្វើដោយដាក់ទណ្ឌកម្មនានារហូតដល់កាប់សម្លាប់ទេ ព្រោះទង្វើអស់ទាំងនេះ.វាគ្មានប្រសិទ្ធិភាព គឺវាមិនអស់មនុស្សប្រព្រឹត្តទង្វើចោរកម្មទេ។ ព្រោះអ្វី? ព្រោះមានរូបមនុស្សទុច្ចរិតផ្សេងៗទៀត មកជំនួសមកប្រព្រឹត្តទង្វើចោរកម្មជាថ្មីទៀត។ តែបើបានចាត់ការសេដ្ឋកិច្ចល្អឱ្យមនុស្សមានការងារធ្វើតាមគួរដល់សមត្ថភាពដល់សេចក្តីចេះដឹងរបស់គេ ។ ជាមួយគ្នានេះ គេត្រូវមានផែនការជួយទំនុកបម្រុងកសិករពាណិជ្ជករភ្នាក់ងាររដ្ឋការ ឱ្យរស់នៅក្នុងករណីយ៍ក្នុងអាជីវកម្មរបស់ខ្លួន ឱ្យបានស្រួលនោះស្រុកប្រទេសរបស់អ្នក នឹងបានឋិតនៅក្នុងភាពសុខសាន្តចម្រុងចម្រើនជាមិនខានឡើយ ។ដោយអាស្រ័យល័ក្ខខណ្ឌ ដែលព្រះសម្មាសម្ពុទ្ធបានបង្ហាត់បង្រៀនទាក់ទងដល់សេដ្ឋកិច្ច នឹងសីលធម៌ដូចបានពោលមកនេះ ។យើងអាចឆ្លើយបញ្ហាដែលចោទថាព្រះពុទ្ធសាសនាបង្រៀនមនុស្សឱ្យខ្ជិល. ឱ្យរស់នៅដោយអាស្រ័យជំនួយទេវតាឱ្យដេកផ្សងព្រេង ។ល។

ដែលពុទ្ធសាសនាគ្មានបានបង្រៀនយ៉ាងនេះសូម្បីត្រឹមតែមួយមាត់ក៏គ្មានផង ។ក្រៅលែងជាងនេះទៀតក្នុងករណីយ៍ខ្លះព្រះពុទ្ធបរមគ្រូ ព្រះអង្គបានសម្តែងអំពីធម្មសម្បត្តិក្នុងការប្រកបអាជីវកម្មប្រភេទខ្លះ ដូចលក់ដូរដោយបានបញ្ជាក់យ៉ាងច្បាស់ថាអ្នកលក់ដូរប្រសិនបើខ្លួនគេ បានប្រកបដោយធម្មសម្បត្តិ៣ប្រការ គេមុខជានឹងមានកម្រៃយ៉ាងខ្ពស់ជាមិនខាន ។ ធម្មសម្បត្តិ ៣ គឺ :

១-គេជាបុគ្គលមានភ្នែកល្អ ឬ ភ្នែកភ្លឺដៅយកសេចក្តីចេះដឹងប៉ិនប្រសប់ក្នុងមុខរបរជំនាញ ស្គាល់ដើមទុន ស្គាល់កម្រៃ។ ជាពិសេសចេះក្បួនសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ។

២-គេជាបុគ្គលមានសេចក្តីព្យាយាមយ៉ាងមោះមុតដៅយក ការខិតខំយ៉ាងទូលំទូលាយ ចេះស្ទង់ចេះពិចារណាចេះពិនិត្យកាលៈទេសៈ ។មានគំនិតបច្ចេកទេស មានសេចក្តីវៃឆ្លាតក្រៅតម្រា ដឹងកិច្ចដឹងកលដូចជាដឹងថាទៅទិញរបស់នៅកន្លែងណាមានតម្លៃថោក.យកទៅលក់នៅផ្សារណាមានកម្រៃខ្ពស់ ។ ជាពិសេសបើបានចំណេញច្រើនគេមិនភ្លេចស្មារតីខាតដើមទុនគេមិនសុខចិត្តលះបង់ចោល ឬ រាងចាល ។

៣-គេជាបុគ្គលមានមនុស្សនិយមរាប់អានច្រើន សម្បូណ៌មិត្រសម្លាញ់

ស្គាល់របៀបធ្វើខ្លួនឱ្យមនុស្សគ្រប់ មជ្ឈដ្ឋានទូទៅចាប់ចិត្តនិយមមាន ជំនឿមានសេចក្តីទុកចិត្តទុកផ្ញើមរហូតដល់ស៊ូខាតស៊ូចំណេញជាមួយគ្នាផងទៀត ។

- គំនោលសេដ្ឋកិច្ចជាន់ខ្ពស់

កាលបើនិយាយដល់គោលគំនិតរបស់ពុទ្ធសាសនាដែលបង្រៀនឱ្យមនុស្សយកចិត្តទុកដាក់ធ្វើខ្លួនឱ្យមានវឌ្ឍនភាពក្នុងផ្លូវសេដ្ឋកិច្ច ថ្នាក់ទាប ដែលជាបុព្វហេតុសម្រាប់ធ្វើឱ្យងាយស្រួលដល់ការប្រតិបត្តិតាមសីលធម៌ ក៏គួរនិយាយដល់គំនោលសេដ្ឋកិច្ចជាន់ខ្ពស់ ដែលលោកឱ្យឈោងមួយបែបទៀតថាកម្ពស់ចិត្តក្នុងទីនេះផង ព្រោះពុទ្ធសាសនាមិនមែនមានបំណងត្រឹមតែដឹកនាំជីវិតមនុស្ស ឱ្យរស់នៅប្រកបដោយវឌ្ឍនភាពក្នុងលោកនេះនិងលោកដទៃទៀតប៉ុននឹងទេ. គឺត្រូវការឱ្យមនុស្សធ្វើជាម្ចាស់ នៃតណ្ហាតទៅទៀត ។ក្នុងន័យថា. ដំបូងមនុស្សត្រូវខំប្រឹងធ្វើការសេដ្ឋកិច្ចគ្រប់យ៉ាងឱ្យមានវឌ្ឍនភាព នៅក្នុងកម្រិតមធ្យមរហូតដល់កម្រិតខ្ពស់ដើម្បីផ្តល់សេចក្តីសុខស្រួលដល់ជីវិតរបស់ខ្លួន ។តែវឌ្ឍនភាពនៃជីវិតខាងសម្ភារៈ វាមិនមែនជាធាតុមានកម្ពស់ដល់ថ្នាក់ទីបំផុតទេ ។ព្រោះអ្វី?ព្រោះចិត្តរបស់មនុស្សយើង វាជាធាតុមួយ ដែល

គេមិនអាចបំបាត់ឬបំពេញសេចក្តីត្រូវការរបស់វាបានទេ ។ គឺវាចេះតែចង់កើតចង់បានចង់មានគ្មានអស់គ្មានហើយឡើយ. តួយ៉ាងដំបូងវាចង់បាននាឡិកា យើងរកនាឡិកាឱ្យវាបានឈ្មោះថា យើងបានបំបាត់ចំណង់ឬសេចក្តីត្រូវការរបស់វាបានមួយហើយ ។ តែកង្វះរបស់វានៅមានទៅទៀត បើមិននាឡិកាដដែលក៏អ្វីផ្សេងៗដទៃៗទៀតគ្មានចេះគ្រប់គ្រាន់ឡើយ ។តើមានបុគ្គលណាម្នាក់អាចបំពេញកង្វះនេះបានឬទេ?ចម្លើយគ្មាន!នេះហើយដែលព្រះសម្មាសម្ពុទ្ធទ្រង់បានមានព្រះពុទ្ធដីកាថាសត្វលោកមានកង្វះជានិច្ច.មានមិនចេះឆ្អែត.មិនស្កប់ស្កល់ជាប្រក្រតី.ជាមួយគ្នានេះ សត្វលោក ជាទាសៈនៃកង្វះ នៃចំណង់នៃសេចក្តីត្រូវការរបស់ខ្លួន( **ឩនោ លោកោ អតិត្តោ តណ្ហា ទាសោ**) ។ ពុទ្ធសាសនិកម្នាក់ៗ ត្រូវដឹងថារបស់ណាខ្លះដែលចាំបាច់ត្រូវមាននឹងរបស់ណាខ្លះទៀតដែលមានហើយ វាមានពលានុភាពដុតចិត្តវិញ្ញាណយើងឱ្យក្តៅក្រហាយរោលរាលប្រាសចាកសេចក្តីសុខស្ងប់ ប្រាសចាកគំនិតសន្តិភាព ។

ប្រសិនបើយើង . នាំគ្នាពិនិត្យមើលកម្មវិធីបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធក្នុងចំណុចនេះ យើងនឹងមានក្តីអស្ចារ្យស្ញើចក្នុងចិត្តចំពោះចំណោត់

ការ មួយអន្លើនិងបញ្ហាសេដ្ឋកិច្ចជាន់ខ្ពស់ ដែលព្រះអង្គ បានធ្វើប្រកប ដោយសេចក្ដីឆ្លៀវឆ្លាតញឹកល្អិតសឹងគ្មានបុគ្គលណាអាចមានសមត្ថភាព ធ្វើតាមបាន ។

ការប្រតិស្ឋានពុទ្ធសាសនាទុកក្នុងលោក ជាទង្វើធំក្រៃលែង បើប្រៀបធៀបទៅនិងចំណាត់ការផ្សេង ៗក្នុងលោក យើងអាចឃើញ បានថារហូតមកដល់ពេលនេះពុទ្ធសាសនាមានអាយុ ២៥៥៤ឆ្នាំមក ហើយ គង់ស្ថិតនៅក្នុងភាពមាំមួនមានរបៀបបែបផែនដដែល ។ចំណែក អង្គការទូទៅនៃពិភពលោកគេគ្មានឃើញអង្គការណាមួយ ស្ថិតនៅក្នុង ភាពមាំមួន រឹងពឹងដដែលដោយគ្មានកំណែ គ្មានចំណាត់ជាថ្មីឡើយ ។

វិធានការខាងផ្លូវលោកមួយណា ក៏ដូចជាមួយណាដែរ សុទ្ធតែ ចោទឡើងដោយបញ្ហាលុយកាក់ដូច ៗគ្នា ។ចំណោទនេះវាបានក្លាយជា ផ្នត់គំនិតលុះត្រាមនុស្សខ្លះ លាន់មាត់ថា បញ្ហាធំបំផុតនៃជីវិតមនុស្ស គឺលុយកាក់ ។ បញ្ហាសំខាន់ៗក្នុងមុខការធំៗត្រូវអាស្រ័យពឹងផ្អែកលើ លុយកាក់ទាំងអស់គ្មានលុយកាក់ធ្វើមិនចេញទេ ។ ប្រសិនបើចែកអង្គ ការជាពាគេនឹងឃើញថាក្នុងអង្គការមួយ ៗគ្មានចំណុចត្រង់ណា ដែល គ្មានទាក់ទងដល់លុយកាក់ឡើយគឺ ១-លុយ ២- លុយ ៣-លុយ អីចឹង

តែម្តង ។

ព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គឃើញថាគំរោងការរបស់មនុស្សលោក ត្រូវការយកប្រាក់ជាសរណៈ ជាទីពឹងជាធាតុចាំបាច់របស់គេដូចនេះហើយទើបព្រះអង្គចាត់វិធានការសេដ្ឋកិច្ចជាន់ខ្ពស់របស់ព្រះអង្គ ផ្ទុយពីគេវិញម្តង គឺក្នុងនេះន័យហើយ ដែលអ្នកស្រាវជ្រាវជាទូទៅ មានគំហើញស្របគ្នាថា វិធានការ ឬគំរោងសេដ្ឋកិច្ចរបស់ពុទ្ធសាសនា ថ្នាក់ទាប ថ្នាក់កណ្តាល មានលក្ខណៈ ត្រូវគ្នានឹងគំរោងការសេដ្ឋកិច្ច របស់អ្នកសេដ្ឋសាស្ត្រក្នុងពិភពលោក ។ តែគំរោងការសេដ្ឋកិច្ចជាន់ខ្ពស់របស់ ពុទ្ធសាសនាមានលក្ខណៈនិងកម្រិតនៃគុណភាពខ្ពស់ជាងសេដ្ឋកិច្ច នៃអ្នកសេដ្ឋសាស្ត្រទូទៅ ។ ព្រោះអ្វី? ព្រោះព្រះពុទ្ធសាសនាគ្មានប្រើប្រាក់ដូចគេ ហើយអ្នកអនុវត្តន៏នៅតែមានជីវិតប្រព្រឹត្តទៅបានដដែល ។

ក្នុងវិន័យ ព្រះសម្ពុទ្ធបានបញ្ញត្តិសិក្ខាបទហាមភិក្ខុចាប់កាន់ ឬទទួលមាសប្រាក់ ។ ជាមួយគ្នានេះតម្រូវឱ្យមានអាបត្តិដល់ភិក្ខុដែលបានប្រព្រឹត្តល្មើស ។ នេះគឺជាទង្វើមួយដែលពុទ្ធសាសនាបានបង្ហាញឱ្យពិភពលោកឃើញថា មិនប្រើមាស ប្រាក់ក៏អាចធ្វើការធំៗបានសម្រេចផល

ពិត១ ដូចអ្នកប្រើប្រាក់ដែរ។

គោលការដែលហៅថា សេដ្ឋកិច្ចជាន់ខ្ពស់ឬជាន់លើបំផុតរបស់ព្រះសម្មាសម្ពុទ្ធ គឺខំប្រឹងធ្វើខ្លួនឱ្យជាម្ចាស់នៃតណ្ហារស់នៅពីលើតណ្ហានៅក្នុងគំនិតសិក្សាថាធាតុអ្វីខ្លះមានប៉ុន្មាន ជារបស់ចាំបាច់ដល់ការរស់នៅមានប៉ុន្មាន ដែលហួសសេចក្តីត្រូវការរបស់ជីវិត។ អ្វីខ្លះមានប៉ុន្មានដែលធ្វើឱ្យជីវិតហ៊ុកហ៊ាក់ហ៊ឺហាលុះក្លាយខ្លួនជាទាសភាពនៃតណ្ហា។ព្រះបរមគ្រូយើង បានអនុញ្ញាតរបស់ចាំបាច់សម្រាប់ភិក្ខុរស់មាន ៤ ប្រការដែលយើងស្គាល់គ្រប់គ្នាថាបច្ច័យ៤ដែលត្រូវនឹងពាក្យអង់គ្លេសថាFourrequisites គឺសម្លត់ស្លៀកដណ្តប់ (ចីវរ) អាហារចិញ្ចឹមជីវិត (បិណ្ឌបាត) ទីស្នាក់អាស្រ័យ(សេនាសនៈ)នឹងឱសថសម្រាប់ព្យាបាលជំងឺ(គិលានភេសជ្ជៈ)។ គ្រឿងសម្រាប់រស់ទាំង ៤ ប្រការនេះព្រះអង្គបញ្ជាឱ្យភិក្ខុជាឧបជ្ឈាយ៍ឬឧបសម្បទាចារ្យ សូធ្យប្រកាសប្រាប់ភិក្ខុដែលទើបនឹងបួសថ្មីឱ្យបានដឹងភ្លាម១ ដើម្បីខំរស់ខំអនុវត្តសេដ្ឋកិច្ចនេះតាមពុទ្ធានុញ្ញាត។ ភិក្ខុគ្មានសម្លត់ល្អប្រើអនុញ្ញាតឱ្យរើសកំណាត់សម្លត់ដែលគេចោលទីនេះបន្តិចទីនោះបន្តិចយកមកប៉ះប៉ុន ដេរភ្ជាប់ជាចីវរសម្រាប់ប្រើប្រាស។ គ្មានអាហារល្អបរិភោគឱ្យអាស្រ័យអាហារបិណ្ឌបាត្រតាមតែគេឱ្យតិចក្តី

ច្រើនក្តីឆ្ងាញ់ក្តីមិនឆ្ងាញ់ក្តីទៅតាមរឿង។ គ្មានលំនៅឋានល្អ នៅឱ្យយកដើមឈើជាទីអាស្រ័យ។ គ្មានឱសថប្រកបដោយគុណភាពព្យាបាលជំងឺ ឱ្យត្រង់ទឹកមូត្រឱ្យស្អាតប្រើជំនួសលុះត្រាតែកើត។ ក្រៅពីនេះទៀតនៅមានបញ្ញត្តជាច្រើនប្រការដែលអ្នកអានគួរដឹងជាមួយគ្នានេះដែរដូចជាហាមមិនអោយប្រើគ្រឿងប្រដាប់ដែលគេធ្វើដោយមាស ប្រាក់ឬអ្វីទៅទៀត ដែលមានភាពប្រហាក់ប្រហែលនឹងមាសប្រាក់ឬរបស់ដែលគេសង្គ្រោះចូលក្នុងមាសប្រាក់ឬរបស់ដែលមានតម្លៃខ្ពស់ជាង មាសប្រាក់ហើយជារបស់សម្រាប់តុបតែងខ្លួនប្រាណ។ ហាមមិនអោយសុំរបស់ជនណាដែលគេមិនបានបវារណា ឬ អនុញ្ញាតទុកមុន។ បើគ្មានការចាំបាច់ជាពិសេសហាមមិនឱ្យប្រមូលសន្សំរបស់ស្តុកទុក ដើម្បីអួតមានអួតសម្បូណ៌។ តឹងរឹងជាងនេះទៀតអាហារសំណល់ហាមមិនអោយទុកដាក់ដើម្បីបរិភោគម្តងជាពីរដង ឬច្រើនជាងនេះក្នុងថ្ងៃខាងមុខ។

គោលការណ៍ធំ៧ ដែលព្រះសម្មាសម្ពុទ្ធបានធ្វើសេចក្តីបំភ្លឺមានដូចនេះ :

១-ចំណង់គ្មានព្រំដែន ជាហេតុអោយកើតទុក្ខរំលត់ចំណង់គ្មានព្រំដែនបានដោយគ្មានសេសសល់ សេចក្តីទុក្ខត្រូវបានរលត់ភ្លាម គ្មានចាំបាច់

សុំ សេចក្តីប្រោសប្រាណអំពីព្រះអាទិទេពណាឡើយ ។

២- ភិក្ខុទាំងឡាយណា ពុំបានធ្លាក់ខ្លួនជាទាសភាព របស់តណ្ហាដែលជាធាតុមានកម្លាំងប្រឆាំងប្រទាញតាមច្បាប់ធម្មជាតិ ភិក្ខុទាំងឡាយនោះឈ្មោះថាមានតម្លៃកម្រនឹងមានដល់មនុស្សជាតិ ក្នុងសកលលោក ។ គំនោលរបស់ខ្ញុំក្នុងខាងដើមថា គំនោលសេដ្ឋកិច្ចគឺការស្វែងសេចក្តីត្រូវការរបស់មនុស្ស ។ តែគំនោលសេដ្ឋកិច្ច ជាន់ខ្ពស់របស់ព្រះពុទ្ធសាសនាមិនមែនជាការស្វែងសេចក្តីត្រូវទេ គឺជាការបញ្ឈប់នូវសេចក្តីត្រូវការដែលមិនចាំបាច់ ។ ទន្ទឹមគ្នានេះ ខំប្រឹងធ្វើខ្លួនឱ្យបានជាចៅហ្វាយនាយលើសេចក្តីត្រូវការនោះ លុះត្រាតែបាន បើមិនបានកុំឈប់កុំថយឱ្យសោះ ប្រសិនបើចង់កំទេចសេចក្តីទុក្ខអស់ព្រោះគ្មានទង្វើណាដទៃទៀត ក្រៅទង្វើនេះទេ ក្នុងរឿងរំតល់រំសាយទុក្ខដែលយើងកំពុងជួបប្រទះក្នុងជីវិតសព្វថ្ងៃនេះ ។ នេះជាសេដ្ឋកិច្ចជាន់ខ្ពស់ឬជាន់លើ សម្រាប់ភិក្ខុឬគ្រហស្ថដែលមានកំពស់ចិត្តខ្លាំងក្លាមានកម្រិតអរិយសច្ចៈ ដែលពុទ្ធសាសនារបស់យើងអោយឈ្មោះថាបរមត្ថប្រយោជន៍ ។ប្រសិនបើនិយាយពីសេដ្ឋកិច្ចនៃពុទ្ធសាសនាលំដាប់តាមលេខរៀងនឹងមានដូចនេះគឺ:

១-ទិដ្ឋធម្មិកត្ថប្រយោជន៍ សេដ្ឋកិច្ចសម្រាប់ជីវិតបច្ចុប្បន្ន ។

២-សម្បរាយិកត្ថប្រយោជន៍ សេដ្ឋកិច្ចសម្រាប់ជីវិតថ្មី ។

៣-បរមត្ថប្រយោជន៍សេដ្ឋកិច្ចសម្រាប់ជីវិតបាននិញ្វន ។

អ្នកអានគប្បីដឹងថាសេដ្ឋកិច្ចទាំង៣ប្រភេទនេះបើស្តីអំពីលំដាប់ដែលគេត្រូវធ្វើត្រូវប្រកបណាមុន ណាបន្ទាប់ណាក្រោយធាតុនេះមានខ្ទង់លេខដូចសរសេរមកហើយនេះ។ តែបើស្តីអំពីគុណភាពពុទ្ធសាសនាយើងពុំបានទុកដាក់ឱ្យមានកំពស់ជាងគ្នាទេ ។ ពំនោលថាទិដ្ឋធម្មិកត្ថប្រយោជន៍ ទាបសម្បរាយិកត្ថប្រយោជន៍កណ្តាល បរមត្ថប្រយោជន៍ជាន់ខ្ពស់នោះវាមានលក្ខណៈ ត្រឹមតែស្រួលបង្រៀនស្រួលពន្យល់ស្រួលទេសនីប៉ុណ្ណោះ។ ដោយអាស្រ័យ គំនិតនិងសំនេរ ក្នុងខាងដើមរបស់ខ្ញុំក៏បានដាក់ថា បច្ចុប្បន្នទាបបរលោកថ្នាក់កណ្តាល នឹងនិញ្វនថ្នាក់ខ្ពស់អីចឹងដែរ។ រីឯសេចក្តីពិតក្នុងរឿងនេះវិញ គឺជីវិតបច្ចុប្បន្នក៏ជាធាតុមានថ្នាក់ ទាប កណ្តាល ខ្ពស់ បរលោកក៏មានថ្នាក់ទាប កណ្តាល ខ្ពស់ និញ្វនក៏មានថ្នាក់ទាប កណ្តាល ខ្ពស់ ដូច១គ្នាក្នុងបច្ចុប្បន្នសេដ្ឋកិច្ចទាបជីវភាពមនុស្សទាបសេដ្ឋកិច្ចមធ្យមជីវភាពមនុស្សកណ្តាលសេដ្ឋកិច្ចខ្ពស់ជីវភាពមនុស្សខ្ពស់ ។ ក្នុងបរលោកក៏មានសេដ្ឋកិច្ចទាប កណ្តាល ខ្ពស់ដូចបច្ចុប្បន្នដែរ។

ចំណែកសេដ្ឋកិច្ចនិព្វានសោតាបន្នបុគ្គល និងសកទាមិបុគ្គលថ្នាក់ទាប អនាគាមិបុគ្គលថ្នាក់កណ្ដាល អរហត្តបុគ្គលថ្នាក់ខ្ពស់។ បើយោងទៅតាមរឿងជាតកនៃព្រះពោធិសត្វគឺព្រះពុទ្ធបរមគ្រូរបស់យើងកាលមិនទាន់បានត្រាស់ ព្រះអង្គខំប្រឹងតស៊ូយ៉ាងប្អូរផ្ដាច់ប្រកបអាជីវកម្មគ្រប់យ៉ាងនៅក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចរបស់គ្រួសារនឹងសង្គមជាតិ គឺ ធ្វើឱ្យកម្រិតជីវភាពទាំងបច្ចុប្បន្នទាំងបរលោកស្ថិតនៅក្នុងថ្នាក់ខ្ពស់បំផុត ដើម្បីជាស្ពានចម្លងអាត្មានៃព្រះអង្គឱ្យបានដល់សេដ្ឋកិច្ចចុងក្រោយបង្អស់គឺនិព្វានហ្នឹងឯង ។ ដូច្នេះ ព្រោះអ្វី? ព្រោះប្រយោជន៍បច្ចុប្បន្ន (ឧដ្ឋាន អារក្ខៈកល្យាណមិត្តតា សមជីវិតា) ត្រូវបានជាស្ពាននៃប្រយោជន៍បរលោក *(សទ្ធា សីល ចាគ បញ្ញា) (បរមត្ថប្រយោជន៍ ទុក្ខ សមុទយ និរោធ មគ្គ)* កើតមានបានដោយអាស្រ័យស្ពានគឺប្រយោជន៍បរលោកជាបន្តបន្ទាប់គ្នា ។ដូចនេះជីវិតមួយៗត្រូវធ្វើសេដ្ឋកិច្ចគឺខំប្រកបអាជីវកម្មរាល់ប្រភេទ ដើម្បីរស់នៅខ្ពង់ខ្ពស់ក្នុងលោកនេះផង ខំធ្វើបុណ្យទានដើម្បីរស់នៅថ្លៃថ្នូរក្នុងលោកខាងមុខផងខំចម្រើនអរិយសច្ចធម៌ ដើម្បីសម្រេចមគ្គផលនិព្វានក្នុងជីវិតចុងក្រោយបង្អស់ផង ។

ដើម្បីឱ្យពុទ្ធសាសនិកបានស្គាល់សេដ្ឋកិច្ច មានគុណភាពខ្ពង់ខ្ពស់

បណ្តើរៗនៅក្នុងក្របខ័ណ្ឌមួយថ្មីទៀត ។ ព្រះពុទ្ធសាសនាបានស្នើអរិយទ្រព្យ៧ប្រការដែលគេធ្លាប់ស្គាល់គ្រប់គ្នាមកហើយថា ទ្រព្យនេះមានតម្លៃខ្ពស់ជាងទ្រព្យធម្មតា ដែលមនុស្សយើងធ្លាប់មាន ធ្លាប់បានប្រើប្រាស់មកហើយ មានដូចនេះ គឺៈ

១- សទ្ធា

២- សីល

៣- ហិរិ

៤- ឱត្តប្ប

៥- ពាហុសច្ច

៦- ចាគ

៧-បញ្ញា

ពុទ្ធសាសនាមានយោបល់ថា បើជនណាមានទ្រព្យខាងក្នុង ឬទ្រព្យប្រសើរដែលហៅថា "អរិយទ្រព្យ" នេះហើយទ្រព្យសម្បត្តិខាងក្រៅ នឹងកើតមានដល់គេ ដោយស្វ័យប្រវត្តិក្នុងពេលណាមួយមិនខានឡើយ ។ ផ្ទុយ ទៅវិញជនដែលមានទ្រព្យសម្បត្តិខាងក្រៅតែខ្លួនពុំបានរស់នៅក្នុងសីលធម៌ឬគ្មានអរិយទ្រព្យខាងក្នុង៧ប្រការជួយគាំទ្រផងទេ

។ លោកថាទ្រព្យសម្បត្តិខាងក្រៅនោះ មុខជាពុំអាចស្ថិតស្ថេរបានយូរ ឬបានរហូតតាមចំណង់របស់ខ្លួនឡើយ ។កំណែភាពអាក្រក់ដោយភាពល្អក្នុងចំណុចទី ២ ដែលថាពុទ្ធសាសនាបង្រៀនឱ្យធ្វើកំណែភាពអាក្រក់ដោយភាពល្អនោះ មានបញ្ហាសំខាន់ ដែលយើងត្រូវធ្វើការពិចារណាបកស្រាយ មិនតិចឡើយ ។តែមុននឹងពិចារណាឱ្យល្អិតល្អន់តាមរបាយការណ៍ដទៃៗ យើងគួរធ្វើសេចក្ដីសង្កេត ដល់គំនោលធំៗ នៃពាក្យបង្រៀនទាំងអស់នេះជាមុនសិន:

១-គប្បីយកឈ្នះកំហឹង ដោយគ្មានកំហឹង គប្បីឈ្នះមនុស្សមិនល្អដោយសេចក្ដីល្អ គប្បីយកឈ្នះមនុស្សកំណាញ់ដោយអំណោយគប្បីយកឈ្នះមនុស្សពោលពាក្យឡេះឡោះ ដោយពោលពាក្យសត្យទៀងត្រង់ ។

២-គ្រប់ទីគ្រប់កន្លែងពៀរគ្មានរម្ងាប់ដោយចំណង់ឡើយពៀររមែងរម្ងាប់ដោយគ្មានចំណង់ ធម៌នេះគឺជាធម៌ មានមកតាំងតែពីបរមបូរាណ ។ដូចមានរឿងនិទានជាកតសម្ដែងថា៎ ព្រះបរមសាស្ដា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះតេជពន ទ្រង់ប្រារព្ធពួកភិក្ខុក្រុងកោសម្ពី ដែលឈ្លោះទាស់ទែងគ្នាទើបព្រះអង្គត្រាស់សម្ដែងនូវព្រះធម៌ទេសនានេះ ដោយពាក្យថា ឯវំ ភូតស្ស តេ រាជ ដូច្នេះជាដើម ។

បានស្ដាប់មកថា ក្នុងកាលដែលភិក្ខុទាំងឡាយនោះ និមន្តមកកាន់វត្តជេតពនមហាវិហារដើម្បីសូមនូវការអត់ទោសពីព្រះបរមសាស្ដា ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុនោះមកហើយ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ជាឱរសរបស់តថាគតជាឱរសកើតពីមាត់ ។ធម្មតាដែលជាឱរស គឺមិនគួរទម្លាយនូវឱវាទដែលបិតាទុកឱ្យឡើយប៉ុន្តែអ្នកទាំងឡាយបែរទៅជាអ្នកមិនធ្វើតាមឱវាទរបស់តថាគត គឺជាអ្នកទម្លាយនូវឱវាទទៅវិញ។ បណ្ឌិតទាំងឡាយពីបុរាណសូម្បីចោរជាអ្នកសម្លាប់មាតាបិតារបស់ខ្លួន ហើយប្លន់យកនូវរាជសម្បត្តិបានធ្លាក់ចូលក្នុងកណ្ដាប់ដៃក្នុងព្រៃ ក៏នៅតែឱ្យអភ័យ មិនសងសឹក ដោយគិតថា យើងនឹងមិនទម្លាយឱវាទដែលមានមាតាបិតា ទុកឱ្យ ។ រួចហើយព្រះអង្គទ្រង់នាំយករឿង ក្នុងអតីតកាលសម្ដែង ។ រឿងដោយពិស្ដារមានក្នុងវិន័យបិដករឿងដោយសង្ខេបមានដូចតទៅ:

ក្នុងអតីតកាលស្ដេចក្រុងពាណសី ទ្រង់ព្រះនាមព្រហ្មទត្តជាស្ដេចស្ដុកស្ដម្ភមាំមួន បានលើកទ័ពចេញទៅច្បាំងនឹងស្ដេចទីឃីតិកោសល ។ ស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិជាស្ដេចកម្សត់ មានសម្បត្តិតិចមានកម្លាំងទ័ពតិចបាននាំមហេសីលបរត់ចេញពីក្រុងជាមុន ។ គ្រានោះ

ស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត បានដណ្តើមយកពួក ពល ពាហនៈ ជនបទ ឃ្លាំង ជង្រុករបស់ស្តេចក្នុងដែនកោសលព្រះបាទទីឃីតិ ហើយគ្រប់គ្រងរក្សា ។ចំណែកស្តេចទីឃីតិបាននាំមហេសី ទៅអាស្រ័យនៅក្នុងផ្ទះស្មូនឆ្នាំង ដែលឋិតនៅជាយក្រុងពារាណសី ដោយក្លែងភេទមិនឱ្យអ្នកដទៃស្គាល់បាន ទ្រង់ស្លៀកដណ្តប់ជាបរិព្វាជក ។ក្រោយមកមិនយូរប៉ុន្មានព្រះមហេសីនៃព្រះបាទទីឃីតិក៏ទ្រង់គភ៌ លុះដល់គភ៌ហើយក៏បានប្រសូតនូវព្រះបរមពោធិសត្វ ព្រះមាតាបិតាទ្រង់ប្រទាននាមថាទីឃាវុ ។ លុះដល់ទីឃាវុកុមារដឹងក្តី បិតាក៏បញ្ជូនបុត្រឱ្យទៅនៅក្រៅក្រុងក្រែងថ្ងៃមុខថ្ងៃក្រោយស្តេចដែនកាសីជ្រាប ដំណឹងនឹងសម្លាប់ទាំងអស់គ្នា ។ ទីឃាវុកុមារការដែលនៅក្រៅក្រុងមិនយូរប៉ុន្មានក៏បានសិក្សាចេះដឹងនូវសិល្បសាស្ត្រសព្វគ្រប់ ។

ពិតមែន ដោយមានអ្នកក្រាបទូល ដល់ព្រះបាទព្រហ្មទត្តជាស្តេចដែនកាសី ព្រះបាទទីឃីតិនិងព្រះអគ្គមហេសី ក៏ត្រូវចាប់ខ្លួនបានពេចងដើមដៃទ្រង់ទាំងពីរព្រះអង្គទៅខាងក្រោយដោយចំណងដ៏មាំកោរក្បាលឱ្យរលីង ទូងស្គរបណ្តើរសព្វច្រក សព្វផ្លូវត្រឡែងកែង ។ការនោះទីឃាវុកុមារមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញខានឃើញមាតា

បិតាយូរណាស់ហើយ បើដូច្នោះគួរតែអាត្មាអញទៅមើល មាតាបិតាបានម្តងសិន ។ ទីឃាវុកុមារចូលទៅដល់ក្រុងពារាណសីហើយ បានឃើញមាតាបិតា ដែលគេកំពុងចងស្លាបសេកបណ្តើរគ្រប់ច្រកនិងគ្រប់ផ្លូវ លុះឃើញហើយ ក៏ចូលទៅរកមាតាបិតា ។ ព្រះបាទទីឃីតិទ្រង់ទតឃើញបុត្រមក ពីចំងាយក៏ស្រែកផ្តាំបុត្រដូច្នេះថា នែទីឃាវុកូន! "ចូរកូនកុំឃើញកាលវែងកុំឃើញកាលខ្លីនែទីឃាវុកូន! ធម្មតាពៀរមិនដែលរម្ងាប់ដោយការចងពៀរទេគឺពៀរតែងរម្ងាប់ដោយការមិនចងពៀរ" ។ ពួកជនទាំងឡាយបានសម្គាល់ព្រះអង្គថាឆ្កួតវើរវាយនិយាយផ្តេសផ្តាស ហើយបាននាំព្រះអង្គចេញទៅតាមទ្វារខាងត្បូងកាត់ខ្លួនព្រះអង្គជាបួនកំណាត់ ។ លុះដល់ ពេលស្ងាត់ព្រះបរមពោធិសត្វទីឃាវុកុមារក៏បានចូលដល់ទីប្រហារជីវិតប្រមូលកំណាត់ឈើហើយលើកសិរ:មាតាបិតាដាក់លើជើងថ្ករ រួចក៏បូជាដោយភ្លើង ផ្ទងអញ្ជលីធ្វើ ប្រទក្សិណជើងថ្ករបីជុំ ។គ្រានោះ ទីឃាវុទៅឯព្រៃ ហើយខ្សឹកខ្សួល ទួញយំដោយសេចក្តីអាល័យអួលណែនក្នុងទ្រូង អស់ចិត្តយំហើយ ទើបជូតទឹកភ្នែកប្រឡប់ចូលក្រុងពារាណសីវិញ ទៅសុំរៀនសិល្ប:នឹង ហ្មដំរី នៅជិតព្រះរាជវាំង ។ ទីឃាវុកុមារ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីស្រែក

ជ្រៀងដោយសំលេងដ៏ពិរោះព្រមទាំងដេញពិណផង ក្នុងរោងដ៏រី ដែលធ្វើឱ្យព្រះរាជាពេញព្រះហឫទ័យឱ្យនៅបំរើព្រះអង្គ ។ ដោយទីឃាវុកុមារពូកែ ផ្គាប់ចិត្តព្រះរាជាមិនយូរប៉ុន្មានក៏បានតែងតាំងទីឃាវុកុមារក្នុងភាពជាអ្នកស្និទ្ធស្នាលខាងក្នុង ។

ថ្ងៃមួយព្រះរាជាបានត្រាស់បង្គាប់ឱ្យទីឃាវុកុមារទឹមរាជរថ នាំព្រះអង្គប្រពាតម្រឹគក្នុងព្រៃ ។ព្រះរាជានឿយហត់ព្រះកាយ ដោយផ្លូវឆ្ងាយបានត្រាស់ឱ្យទីឃាវុកុមារដាក់រាជរថសិន ហើយផ្ទុំកើយព្រះសិរសៈលើភ្លៅទីឃាវុកុមារក្រោមម្លប់ឈើ ក៏លង់លក់មួយរំពេចទៅ។ លំដាប់នោះ ទីឃាវុកុមារ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថាស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្តនេះ បានធ្វើសេចក្ដីវិនាសជាច្រើនដល់អាត្មាអញទាំងពលពាហនៈ ជនបទ ឃ្លាំង និងជង្រុក របស់អាត្មាអញ ស្ដេចនេះរឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតារបស់អាត្មាអញ ក៏ត្រូវស្ដេចនេះសម្លាប់ចោលអស់ទៅទៀត វេលានេះ គួរអាត្មាអញសងពៀរដល់ស្ដេចនេះវិញ ហើយក៏ហូត ព្រះខ័នចេញពីស្រោម ។វេលានោះទីឃាវុកុមារមានសេចក្ដីត្រិះរិះយ៉ាងនេះថា បិតាបានផ្ដាំអាត្មាអញក្នុងពេលដែលទៀបនឹងធ្វើមរណភាពថា "នែទីឃាវុកូន អ្នកឯងកុំឃើញ

កាលវែង កុំឃើញកាលខ្លីនៃទីឃាវុកូនធម្មតាពៀរមិនដែលរម្ងាប់ដោយការ ចងពៀរទេ គឺពៀរតែងរម្ងាប់ដោយការមិនចងពៀរ" បើអាត្មាអញកន្លងពាក្យបិតាហើយអំពើនេះឈ្មោះថាមិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខាន់ចូលទៅក្នុងស្រោមវិញ ។ទីឃាវុកុមារមានសេចក្តីត្រិះរិះឃើញការសងពៀរ ជាលើកទី២ និងជាលើកទី៣ ប៉ុន្តែរាល់លើកមិនបានសម្រេចឡើយ ដោយរឭកឃើញបណ្តាំព្រះបិតាមុននឹងគេធ្វើឃាតព្រះអង្គ ។ គ្រានោះស្តេចព្រហ្មទត្តទ្រង់ភិតភ័យភ្ញាក់ ផ្អើល ស្លើកស្លក់តក់ស្លុតហើយក៏តើនឡើងភ្លាម ។ទីឃាវុកុមារទូលសួរដូច្នេះថាសូមទ្រង់ព្រះមេត្តាប្រោសហេតុអ្វីបានជាព្រះអង្គទ្រង់ភិតភ័យតក់ស្លុតហើយតើនឡើងដូច្នេះ? ស្តេចក៏តបថា នែនាយមាណព! ព្រោះយើងយល់សប្តិឃើញដូចជាទីឃាវុកុមារជាកូនស្តេចក្នុងដែនកោសលឈ្មោះទីឃិតិលើកព្រះខាន់ឡើង គំរាមយើងក្នុងទីនេះព្រោះហេតុនោះ បានជាយើងភ័យភ្ញាក់ផ្អើល ស្លើកស្លក់តក់ស្លុតហើយក្រោកឡើងភ្លាម ។ ភ្លាមនោះទីឃាវុកុមារបានយកដៃខាងឆ្វេងចាប់សង្កត់ ព្រះសីសៈនៃស្តេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ហើយយកដៃខាង ស្តាំហូតព្រះខាន់ រួចនិយាយពាក្យនេះនឹងស្តេចថា នែព្រះអង្គ! ទូលព្រះបង្គំនេះហើយ ដែលឈ្មោះទីឃាវុ

កុមារជាកូនស្ដេចក្នុងដែនកោសលព្រះនាមទីឃីតិព្រះអង្គបានធ្វើសេចក្ដីវិនាសជាច្រើនដល់ទូលព្រះបង្គំទាំងព្រះមាតាបិតារបស់ព្រះទូលបង្គំព្រះអង្គក៏ឱ្យគេធ្វើឃាតចោលទាំងអស់ពេលនេះគួរតែទូលព្រះបង្គំសងពៀរដល់ព្រះអង្គវិញ ។ ទីឃាវុកុមារ គិតថា យើងនេះសូម្បីត្រូវលះបង់ជីវិតក៏មិនទំលាយនូវឱវាទព្រះបិតារបស់យើងឡើយគ្រាន់តែសម្លុតព្រះរាជាប៉ុណ្ណោះទើបពោលគាថាដែលមានសេចក្ដីថា: បពិត្រព្រះរាជាព្រះអង្គធ្លាក់មកក្នុងអំណាចរបស់ទូលព្រះបង្គំ យ៉ាងនេះហើយតើហេតុណាមួយដែលញ៉ាំងព្រះអង្គឱ្យរួចចាកទុក្ខ មានដែរឬ?

ព្រះរាជាត្រាស់នូវព្រះគាថាឆ្លើយតបដែលមានសេចក្ដីថា: ម្នាលអ្នកអើយ យើងធ្លាក់ក្នុងអំណាចរបស់អ្នកប្រាកដយ៉ាងនេះហើយ ហេតុណាមួយដែលញ៉ាំងយើងឱ្យរួចផុតចាកទុក្ខមិនមានឡើយ ។

វេលានេះ ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ក៏ឱនព្រះសិរក្រាបទៀបជើងទីឃាវុកុមារ ហើយមានព្រះរាជឱង្ការទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែទីឃាវុកូន! សូមអ្នកអាណិតឱ្យជីវិតដល់យើងផង នែទីឃាវុកូន! សូមអ្នកអាណិតឱ្យជីវិតដល់យើងផងនែទីឃាវុកូន! សូមអ្នកអាណិតឱ្យជីវិតដល់យើងផង ។ទីឃាវុកុមារតបវិញថា ទូលព្រះ

បង្គំនឹងថ្វាយជីវិតព្រះអង្គដូចម្ដេចទៅ គឺគួរតែព្រះអង្គប្រទានជីវិតទូលព្រះបង្គំទៅវិញទេ ។ ព្រះរាជាត្រាស់ថា នែទីឃាវុកូន! បើដូច្នេះអ្នកចូរ ឱ្យជីវិតយើងចុះឯយើងក៏ឱ្យជីវិតដល់អ្នកវិញដែរ ។

កាលដែលទីឃាវុកុមារ ថ្វាយជីវិតព្រះអង្គហើយលំដាប់នោះ ទីឃាវុកុមារបានពោលគាថា ដូច្នេះ ថា: ***នាញ្ញំ សុចរិតំ រាជ នាញ្ញំ រាជ សុភាសិតំ តាយតេ មរណកាលេ ឯវមេវិតរំ ធនំ*** ។ បពិត្រព្រះរាជា អ្វីដទៃក្រៅពីសុចរិតនិងវាចាដែលជាសុភាសិត គឺមិនអាចការពារព្រះជន្មរបស់ព្រះអង្គ កុំឱ្យដល់នូវមរណៈក្នុងពេលនេះបានឡើយទ្រព្យក្រៅពីនេះ ក៏យ៉ាងនោះដែរ ។ ក្នុងព្រះគាថារបស់ព្រះបរមពោធិសត្វនេះ អធិប្បាយថា បពិត្រព្រះរាជាវៀរចាកសុចរិត និងវាចាជាសុភាសិត ពោលគឺឱវាទ របស់ព្រះបិតាទូលបង្គំចេញហើយ អ្វីដទៃដែលអាចការពារក្នុងវេលាអស់ព្រះជន្ម រមែងមិនមានឡើយ ទ្រព្យក្រៅពីនេះ ក៏ដូចគ្នាដែរគឺមិនមានប្រយោជន៍ទេព្រោះថាពេលនេះ ទោះជាព្រះអង្គឱ្យទ្រព្យរាប់សែន កោដិដល់ទូលព្រះបង្គំ ក៏មិនអាចព្រះអង្គបាននូវជីវិតដែរ ។ ហេតុដូច្នេះ ក្នុងសេចក្ដីនេះ សូមព្រះអង្គទ្រង់ជ្រាបថា សុចរិតនិងពាក្យជាសុភាសិតប៉ុណ្ណោះ ក្រៃលែងជាងទ្រព្យ ។ ព្រះបរមពោធិសត្វ

បានសម្តែងព្រះគាថាជាបន្ទះ **អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។** បុគ្គលទាំងឡាយណា ចងនូវពៀរនោះ ដោយគិតថា អ្នកឯណោះ បានជេរអញបានវាយអញ បានផ្ចាញ់អញបានលួចយកទ្រព្យរបស់ដូច្នេះពៀររបស់បុគ្គលទាំងឡាយ នោះ រមែងមិនរម្ងាប់ឡើយ។ **អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ** ។បុគ្គលទាំងឡាយណា មិនចងនូវ ពៀរនោះថាអ្នកឯណោះបានជេរអញបានវាយអញបានផ្ចាញ់ អញបានលួចយកទ្រព្យរបស់អញដូច្នេះពៀររបស់បុគ្គលទាំងឡាយនោះ ទើបរម្ងាប់បាន។ **ន ហិ វេរេន វេរានិ សមន្តីធ កុទាចនំ អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោតិ** ។តាំងពីកាលណាមក ពៀរទាំងឡាយ ក្នុងលោកនេះ រមែងមិនរំងាប់បានដោយពៀរទេ ពៀរ ទាំងឡាយរមែងរំងាប់បានដោយការមិនមានពៀរនេះជាបុរាណធម៌។

គ្រានោះ ស្តេចក្នុងដែនកាសីនិងទីឃាវុកុមារ បានឱ្យជីវិតគ្នាទៅ វិញទៅមក បានចាប់ដៃគ្នាផង ។ ធ្វើសម្បថផងដើម្បីមិនឱ្យមានរឿង ប្រទូស្តគ្នាតទៅទៀត។ បន្ទាប់ពីត្រឡប់ចូលក្រុងវិញ ហើយព្រះរាជា បានប្រកាសឱ្យមនុស្សទាំងឡាយបានដឹងថា នេះជាកូនស្តេច ក្នុងដែន

កោសល ឈ្មោះទីឃាវុកុមារ អ្នកទាំងឡាយមិនត្រូវធ្វើទោសចំពោះទីឃាវុកុមារនេះឡើយព្រោះទីឃាវុកុមារបានឱ្យជីវិតយើង ទាំងយើងក៏បានឱ្យជីវិតដល់ទីឃាវុកុមារវិញដែរ ។ ប្រកាសហើយ ព្រះរាជាបានសួរទៅទីឃាវុកុមារយ៉ាងនេះថា នែទីឃាវុកូន! អ្នកជិតនឹងធ្វើមរណភាពបានផ្តាំបណ្តាំណាចំពោះអ្នកថា *ចូរកូនកុំឃើញកាលវែងកុំឃើញកាលខ្លី ធម្មតាពៀរមិនដែលរំងាប់ដោយការចងពៀរទេ តើបណ្តាំនេះព្រះបិតារបស់អ្នកសំដៅយកហេតុត្រង់ណាបានជាផ្តាំដូច្នេះ?*

ទីឃាវុកុមារបានក្រាបទូលថាសូមទ្រង់ព្រះមេត្តាប្រោស កាលដែលព្រះបិតារបស់ទូលព្រះបង្គំ ជិតនឹងធ្វើមរណកាលបានផ្តាំបណ្តាំណាចំពោះទូលបង្គំថា **ចូរកូនកុំឃើញកាលវែង** គឺកុំធ្វើពៀរឱ្យយូរអង្វែងឡើយ,ឯបណ្តាំដែលថា **កុំឃើញកាលខ្លី** គឺកុំប្រញាប់បែកចាកពួកមិត្តសំឡាញ់ឡើយ ។ សូមទ្រង់ព្រះមេត្តាប្រោសចំណែកបណ្តាំបន្តទៀតថា **ធម្មតាពៀរមិនដែលរំងាបដោយការចងពៀរទេ**គឺពៀរតែងរំងាប់ដោយការមិនចងពៀរ នោះសំដៅ ត្រង់មាតាបិតារបស់ទូលបង្គំដែលទ្រង់ឱ្យគេប្រហារជីវិតហើយ ព្រោះហេតុនោះប្រសិនបើទូលព្រះបង្គំនឹងបំផ្លាញព្រះអង្គឱ្យដាច់ចាកជីវិតវិញ គង់មានពួកជន ដែលប្រាថ្នាប្រយោជន៍

ចំពោះព្រះអង្គនឹងបំផ្លាញទូលព្រះបង្គំឱ្យដាច់ចាកជីវិត ដែរ ហើយតទៅទៀត ពួកជនដែលប្រាថ្នានូវប្រយោជន៍ដល់ទូលព្រះបង្គំ មុខតែបំផ្លាញពួកជនទាំងនោះឱ្យដាច់ចាកជីវិតមិនខានឡើយពៀរនោះមិនបានរំងាប់ដោយការចងពៀរយ៉ាងនេះឯង ។ ឥឡូវព្រះអង្គទ្រង់ ប្រទានជីវិតដល់ទូលព្រះបង្គំជាខ្ញុំហើយឯខ្ញុំព្រះអង្គក៏ថ្វាយជីវិតដល់ព្រះ អង្គវិញដែរដូច្នេះពៀរនោះនឹងរំងាប់ដោយការមិនចងពៀរយ៉ាងនេះឯង សូមទ្រង់ជ្រាប ។ គ្រានោះ ស្ដេចក្នុងដែនកាសីព្រះនាមព្រហ្មទត្ត ទ្រង់ស្ញើចថាអើហ្ន៎!ហេតុនេះហៅពេញជាអស្ចារ្យណាស់ទីឃាវុកុមារនេះជាអ្នកប្រាជ្ញមែនព្រោះដឹងសេចក្ដីដែលបិតាពោល ដោយសង្ខេបដោយពិស្ដារបាន។ ព្រះរាជបានប្រគល់ពល ពាហនៈ ជនបទឃ្លាំងនិងជង្រុកជាកេរ្ដិ៍ដំណែលបិតាទៅទីឃាវុកុមារវិញព្រមទាំងប្រទានធីតារបស់ព្រះអង្គទៀតផងឱ្យទីឃាវុកុមារ តាំងនៅក្នុងរាជសម្បត្តិគ្រប់គ្រងដែនកោសល ។ តាំងតែពីកាលនោះមក ព្រះរាជាទាំងពីរព្រះអង្គស្ម័គ្រស្មោគមន៍ រីករាយព្រះហឫទ័យគ្រងរាជសម្បត្តិ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់សម្ដែងនូវរឿងនេះហើយព្រះភគវាព្រះអង្គទ្រង់ប្រទាននូវឱវាទដូច្នេះថាម្នាលភិក្ខុទាំងឡាយគួរកោតដែរយ៉ាងពួកក្សត្រទាំងនោះធ្លាប់តែកាន់ដំបងកាន់គ្រឿង

សស្ត្រាវុធហើយមកចេះមានអំណត់ព្រមទាំងប្រព្រឹត្តល្អបែបនេះបាន។ ព្រោះហេតុដូច្នេះ ម្នាលភិក្ខុទាំងឡាយអ្នករាល់គ្នាបានមកបួស ក្នុងធម្មវិន័យនេះ ដែលតថាគតបានសម្តែងដោយល្អយ៉ាងនេះហើយគួរតែអត់ធន់ គួរតែខំប្រព្រឹត្តល្អ ឱ្យល្អឡើង។

ព្រះបរមសាស្តាទ្រង់ប្រជុំជាកតថា មាតាបិតាក្នុងគ្រានោះបានមកជាត្រកូលមហារាជ ចំណែកទីឃាវុកុមារ បានមកជា**តថាគត**ដូច្នេះឯង។

៣- ភាពអាក្រក់ដែលបានធ្វើមកហើយ អ្នកណាខំប្រឹងបិទចោលទង្វើល្អរបស់ខ្លួន ( គឺឈប់ធ្វើទង្វើអាក្រក់តទៅទៀតធ្វើទង្វើល្អជំនួញវិញ) អ្នកនោះឈ្មោះថា បានធ្វើលោកនេះអោយមានពន្លឺភ្លឺស្វាងដូចគ្នានិងដួងចន្ទ ដែលចាកផុតដុំពពកដូច្នោះដែរ ។ ដែលអោយធ្វើកំណែភាពអាក្រក់ដោយភាពល្អព្រោះពុទ្ធសាសនាមានគំនិតថា បើយកធាតុអាក្រក់មកកែធាតុអាក្រក់លទ្ធផលគឺវារឹតតែអាក្រក់ឡើង។

សេចក្តីប្រៀបដូចគេយកទឹកសំអុយទៅលាងរបស់ក្រខ្វក់ ឬដូចគេយកទឹកលាងកន្តោរទៅបោកគក់ ខោ អាវលទ្ធផលគឺវារិតតែប្រឡាក់ប្រើលែងកើត ។

កំណែរបៀបនេះ នៃពុទ្ធសាសនារបស់យើង កាលយើងគិតត្រឹម

តែផ្លូវពិតជាចោលពឹងរបស់ជនពាលដែលដឹងច្បាស់ថា ចំណាញ់បានមកពុទ្ធសាសនិកជនបានទៅជនពាល ។ ឬបើយើងឈ្នះទង្វើអាក្រក់របស់ជនពាល ដោយទង្វើល្អរបស់យើងពិតៗវិញ ក៏គង់តែជំនះរបស់យើងមិនមែនជាខ្លាំងក្លារឹងពឹងទេគឺជាជំនិះមានភាពទន់ខ្សោយជិតតែ និងដល់លេខសូន្យហ្នឹងតែម្តង ប្រសិនបើយើងគិតតូចខ្លីៗ ។តែបើយើងសើរើគន់គិតអោយវែងចាប់តាំងពីបិណ្ឌមួយនៃពុទ្ធភាសិតក្នុងគំនោលធំៗឬមេៗដូចជាកុំធ្វើទង្វើអាក្រក់ធ្វើតែទង្វើល្អនឹងខិតខំដុសខាត់ជំរះចិត្តអោយបរិសុទ្ធ ។យើងអាចបកប្រែបានថាទង្វើអាក្រក់ដើម្បីអាក្រក់ទង្វើល្អដើម្បីល្អសំអាតដើម្បីសំអាតឬមួយទង្វើអាក្រក់ដើម្បីល្អ ទង្វើល្អដើម្បីអាក្រក់ សំអាតដើម្បីសំអុយ ។ អាក្រក់ដើម្បីអាក្រក់ ដូចវាយគេអោយស្លាប់ដើម្បីយកទ្រព្យសម្បត្តិប្រពន្ធកូនគេ ។ល។ ល្អដើម្បីល្អ ដូចធ្វើបុណ្យដើម្បីបុណ្យមិនមែនដើម្បីកេរ្តិ៍ឈ្មោះយសស័ក្តិទ្រព្យសម្បត្តិ ។ល។ស្អាតដើម្បីស្អាតដូចបម្រើនធម៌ដើម្បីមគ្គផលនិព្វានមិនមែន ដើម្បីអំនួតឬបំភាន់ គំនិតអ្នកដទៃដើម្បីលោភសក្ការៈ អាក្រក់ដើម្បីល្អដូចវាយកូនដើម្បីវឌ្ឍនភាពមិនមែន ដើម្បីពន្លិច ។ល ។ល្អដើម្បីអាក្រក់ដូចចិញ្ចឹមមនុស្សមានគំនិតដើម្បីបម្រើ មិនមែននៅក្នុងគំនិតព្រហ្មវិហារដើម្បីស្រង់គ្នាអោយអស់សេចក្តីទុក្ខលំបាក

។ល។ សំអាតដើម្បីសំអុយ, គឺចម្រើនកម្មដ្ឋានដើម្បីអំនួតមិនមែនដើម្បីពន្លឺឬភាពបរិសុទ្ធភាពស្ងប់នឹងត្រជាក់ត្រជុំនៃចិត្តវិញ្ញាណ ។ដូចនេះ .ឃើញថាគំនិតពុទ្ធសាសនាក្នុងរឿងនេះជាគំនិតដាច់ខាតគំនិតមានភាពប្រាកដនិយម គំនិតព្រហ្មវិហារ ។ល។ ក្នុងន័យថាមិនធ្វើទង្វើអាក្រក់លើមនុស្សសត្វណា ដើម្បីឆ្លើយតបនឹងទង្វើអាក្រក់របស់គេ. តែបើទង្វើអាក្រក់នោះអាចកែមនុស្សអាក្រក់អោយល្អបាន ក៏ត្រូវតែធ្វើខ្លះបើមិនធ្វើក៏គ្មានផ្លូវប្រោសសត្វបាន។ ព្រោះអ្វី? មនុស្សខ្លះមាននិស្ស័យត្រូវនឹងគ្រូកាច. មនុស្សខ្លះមាននិស្ស័យត្រូវនឹងគ្រូស្លូត ។ល ។អ្នកអានគប្បីដឹងថាពុទ្ធសាសនារបស់យើងគ្មានចំណុចរឹងលុះត្រាគ្មានមនុស្សទៅជិតហើយក៏គ្មានចំណុចខ្សោយលុះត្រាគេដើរជាន់ឡើយ ។ ទង្វើទាំងឡាយ ដែលពុទ្ធសាសនាអនុវត្តប្រាកដជានៅក្នុងក្របខ័ណ្ឌ នៃមជ្ឈិមាបដិបទាដដែល គឺថាបើកាចក៏ដើម្បីយុត្តិធម៌ នៃសង្គមមនុស្សបើស្លូតដើម្បីវឌ្ឍភាពនៃអរិយធម៌របស់មនុស្សដូចគេបានដឹងគ្រប់គ្នាមកហើយ ។ ពុទ្ធសាសនាមានគំនិតល្អិតបង្រៀនអោយធ្វើកំណែបញ្ហាមុនកំណើតនៃបញ្ហាមួយៗត្រូវមានឡើង ដូចជាបង្រៀន មិនអោយសាងសត្រូវបង្រៀនអោយចងមិត្រ បង្រៀនអោយបំពេញសង្គហវត្ថុ គឺស្គាល់

ចំណេងមិត្តភាព នៃចិត្តរបស់មនុស្សដោយធ្វើអំណោយ ដោយពាំនោល ពិរោះដោយបំពេញប្រយោជន៍.នឹងដោយទុកដាក់ខ្លួនប្រាណក្នុងភាពស្មើ ៗជាមួយនឹងមនុស្សក្នុងសង្គម ។បង្រៀនអោយស្អប់ខ្ពើមជំលោះបង្រៀន អោយមានចិត្តមេត្តាករុណា ដល់មនុស្សទូទៅនៅក្របខ័ណ្ឌចងមិត្រ បំបាត់សត្រូវ ។ ការធ្វើអោយជីវិតរស់នៅក្នុងធម៌ល្អក្នុងចរិយាថ្លៃថ្នូរ ក្នុងនិស្ស័យឧត្តុង្គឧត្តមដូចនេះលោកថាគ្មានការចាំបាច់ ត្រូវធ្វើកំណៃ បញ្ហាអាក្រក់ៗដែលអាចកើតមានក្នុងពេលខាងមុខឡើយ ។ ប្រសិនបើ មានបញ្ហាចោទថាបើយើងចេះតែខំប្រឹងធ្វើទង្វើល្អដល់គេហើយ គេចេះ តែធ្វើទង្វើអាក្រក់ដល់យើងជានិច្ចតើយើងត្រូវធ្វើយ៉ាងណា? ចម្លើយ: បើកុំអោយខូចប្រយោជន៍ច្រើន យើងត្រូវខំប្រឹងធ្វើសេចក្តីល្អប្រកប ដោយសំនួរយ៉ាងខ្ពស់តទៅទៀត. តែបើនៅតែមិនកើតយើងត្រូវប្រើ កំណាចមួយទល់នឹង កំហូចរបស់គេ នៅក្នុងក្របខ័ណ្ឌនៃកំណៃគឺធ្វើ មនុស្សអាក្រក់អោយកើតបានជាមនុស្សល្អដោយគ្មានគំនិតបំផ្លាញ ដូច ដែលព្រះសម្មាសម្ពុទ្ធរបស់យើងធ្លាប់បានអនុវត្តមកហើយ ។ដើម្បីប្រកប ការពិចារណារបស់អ្នកអានខ្ញុំសូមអោយគំនិតតាមសំនេររបស់ខ្ញុំ ដូចត ទៅ ។

# សេចក្តីព្យាបាទ

ប្រសិនបើគេតាំងសំនួរថា: ពាក្យថាពៀររមែងរំងាប់ដោយគ្មានចំណងនោះ តើមតិនេះមានអ្វីជាមូលដ្ឋានជាផ្លូវវិនិច្ឆ័យ?ព្រោះបើយើងមិនឆ្លើយតបទុកដូចជាយើងបើដៃអោយសត្រូវរបស់យើង កាន់តែបានចិត្ត,កាន់តែឈ្លានពានឡើង គឺកាន់តែធ្វើបាបយើងធ្ងន់ឡើងៗ ព្រោះវាគ្មានឃើញយើងតដៃនឹងវា ។ប្រសិនបើយើងឆ្លើយតបតាមមធ្យោបាយណាមួយដែលយើងមាន វាក៏គិតមុខគិតក្រោយមិនហ៊ានធ្វើបាបយើងតទៅទៀត ។

បញ្ហាពៀររំងាប់ដោយគ្មានចំណង ខ្ញុំយល់ថាមានផ្លូវសម្រាប់គិតពីរយ៉ាង :

១- គិតតាមអត្ថរបស់ពាក្យ ។ ២-គិតតាមន័យរបស់ពាក្យ ។

ប្រការ១: ពៀររំងាប់ដោយគ្មានចំណង ឬគ្មានចម្លើយបើយើងមើលតាមវិស័យ នៃសីលធម៌តែម្យ៉ាងវាមុខជាទៅមិនរួចទេគឺយ៉ាងម៉េច ក៏រំងាប់មិនបានជាដាច់ខាត ។យើងនឹងធ្លាក់ខ្លួនជាមនុស្សត្រូវគេជេរប្រទេចជានិច្ច ។ល។ តែបើយើងពូកែអត់ធន់យើងខំទប់ខ្លួន មិនអោយធ្លាក់ទៅជាទាសភាពនៃតំរោធនៅក្នុងក្របខ័ណ្ឌធ្វើមិនដឹងមិនឮយូរទៅ វាក៏

អាចបាត់ឯង១ទៅដែរ គឺយើងសុខចិត្តប្រើខន្តីជាអាវុធ( អាវុធស្បៀម) ដូចព្រះសម្មាសម្ពុទ្ធក្នុងពេលដែលត្រូវពួកនាងសមាវត្តីជេរ ។ ព្រះអានន្ទចង់បានប្រតិកម្មអំពីព្រះអង្គចំពោះជំនេរនេះ. តែព្រះអង្គមិនយល់ព្រម ។ជាមួយគ្នានេះព្រះអង្គបានមានព្រះពុទ្ធដីកាថាជំនេរទាំងឡាយនេះ វាមិនអាចប្រព្រឹត្តទៅហួសថ្ងៃទី៧ទេ ។ យ៉ាងណាក៏ដោយចុះ.ការគិតតាមអត្ថរបស់ ពាក្យក្នុងចំណុចថាពៀររំងាប់បានដោយគ្មានចំណង ។ទង្វើនេះកម្រអ្នកណាធ្វើកើតណាស់ តែបើគេធ្វើបានវាគាប់ប្រសើរជាងធ្វើមិនបាន ។ ព្រោះអ្វី? ព្រោះបើយើងឆ្លើយតបឬអោយតំណប ជំលោះខាងផ្លូវកាយវានឹងត្រូវកើតតាម ។ ឯលទ្ធផលនៃជំលោះនេះ គឺស្លាប់ឬជិតតែនឹងស្លាប់ បើមិនគេក៏យើងដែរ ។

ខាងគតិលោកច្បាប់សម្រាប់ប្រទេស ពុំបានគាំទ្រសេចក្តីព្យាបាទចងអាឃាតរករឿងនឹងគ្នាទេ ជនដែលលុះអំណាចនៃកំហឹងរបស់ខ្លួនហើយបានប្រព្រឹត្តនូវបទល្មើសទាំងឡាយមានដាល់តប់កាប់ចាក់ជាដើមត្រូវទទួលកំហុសនឹងទណ្ឌកម្មទាំងពីរនាក់ធ្ងន់ស្រាលច្រើនតិច ស្រេចហើយ តែអ្នកច្បាប់វិនិច្ឆ័យតាមផ្លូវយុត្តិធម៌ ។ កាលបើច្បាប់សម្រាប់ជាតិឬអន្តរជាតិមិនគាំទ្រទង្វើព្យាបាទ ឬ ជំលោះគ្រប់បែបយ៉ាងដូចនេះ

ទៅហើយតើតិចមិនឹងគាំទ្រយ៉ាងម៉េចបាន? ហេតុដូច្នេះ អ្នកត្រូវតែបញ្ឈប់នូវទង្វើឈ្លោះប្រកែកឬខំប្រឹងបំបាត់នូវទង្វើអាក្រក់នេះអោយបាន បើមិនច្រើនក៏តិចនោះ ទើបត្រូវបានអ្នកប្រាជ្ញអ្នកជួញចំណេញច្រើនជាងជួញខាត ។នេះគឺជាការត្រិះរិះពិចារណាតាមអត្ថរបស់ពាក្យថាពៀររម្ងាប់បានដោយគ្មានចំណង ។ ប្រការ២ការពិចារណាតាមន័យរបស់ពាក្យដូចបានថ្លែងមកហើយនោះ បញ្ហានេះពុទ្ធសាសនារបស់យើងបានណែនាំអោយសត្វលោកចេះពិចារណា ពីខាងក្នុងទៅខាងក្រៅគឺពុទ្ធសាសនា ត្រូវការរកមធ្យោបាយធ្វើយ៉ាងណា កុំអោយភ្លើងឆេះច្រើនជាងបណ្តោយ អោយភ្លើងឆេះហើយទើបរកមធ្យោបាយដើម្បីពន្លត់ភ្លើង ។ ដើម្បីសម្រេចតាមគោលគំនិត នេះទើបពុទ្ធសាសនាពុំបានបង្រៀន អោយមនុស្សឈរអោបដៃចាំកំចាត់បង់ពៀរ ក្នុងពេលពៀរកើតឡើងហើយ ដល់ម្តងណាឡើយ ។បង្រៀនអោយយើងចេះទប់ចេះរម្ងាប់ពៀរ តាំងពីពៀរមិនទាន់កើតឬរឿងដែលជាឈ្នាន់របស់ពៀរមិនទាន់មាននៅឡើយ ។ គឺបង្រៀនឱ្យចេះទុកដាក់រៀបចំខ្លួនឱ្យបានល្អធ្វើឱ្យអ្នកនៅជិតខាងមានទំនុកទុកចិត្ត ផ្លាស់គំនិតបៀតបៀនមកជាគំនិតស្រឡាញ់រាប់អាន ព្រោះអាស្រ័យគុណសម្បត្តិល្អប្រសើរ

របស់យើង ។ ទន្ទឹមគ្នានេះលោក បង្រៀនឱ្យចេះខ្វល់ខ្វាយអើពើ និងទុក្ខធុរៈអ្នកដទៃ ចេះប្រើពាក្យ សម្ដីទន់ភ្លន់ផ្អែមល្ហែម ចេះជួយខ្នះខ្នែងក្នុងផលប្រយោជន៍មួយអន្លើដោយកិច្ចការងារនៃអ្នកផងមិនឃើញ តែប្រយោជន៍ផ្ទាល់ខ្លួន ចេះតម្កល់ខ្លួននៅក្នុងភាពស្មោះស្ម័គ្រគ្មានឆ្មើងឆ្មៃប្រកាន់ខ្លួនប្រាណ ។ល។ បើយើងចេះរៀនចំខ្លួនឱ្យជាមនុស្សរស់នៅក្នុងភាពល្អភាពត្រឹមត្រូវដូចបាន ពោលមកនេះហើយ ខ្លួនយើងមិនត្រឹមតែគ្មានករណីក្នុងការរម្ងាប់ពៀរទេគឺវាគ្មានពៀរគ្មានជម្លោះស្រេចតែម្ដងជាមួយនិងមនុស្សដែលមានគំនិតជាមនុស្សដូចគ្នា ។ចំណែកមនុស្សដែលមានគំនិតដូចសត្វតិរច្ឆាន ឬ លើសសត្វទៅទៀតនោះ បញ្ហានេះយើងពុំអាចឱ្យចម្លើយបានទេព្រោះវាលើសវិស័យនៃចំណេះវិជ្ជារបស់យើងទៅហើយ ។ តែយើងក៏គ្មានគំនិតថា មនុស្សបែបនេះនឹងចេះតែរស់នៅបែបនេះរហូតទេ ថ្ងៃណាមួយគំនិតរបស់គេអាចនឹងមានពន្លឺមានគំនិតហើយត្រូវតែអាស្រ័យថ្វីបញ្ញានៃអ្នកប្រាជ្ញណាមួយ ។ ជាពិសេសព្រះសម្មាសម្ពុទ្ធដែលនឹងមានក្នុងអនាគតកាល ។ដោយអាស្រ័យហេតុនេះ បើយើងធ្វើសេចក្ដីសម្រេចចិត្ត ប្រព្រឹត្ត ប្រតិបត្តិ ឬអនុវត្តន៍ខ្លួនឱ្យសមរម្យ ល្មាក់ល្មមដល់ហេតុការណ៍ ដែលអាចនឹងកើតមានឡើង

ក្នុងថ្ងៃណាមួយ ក្នុងពេលខាងមុខនោះហើយ ខ្ញុំយល់ថាពុទ្ធភាសិត ក្នុងចំណុចថាពៀររមែងរម្ងាប់ដោយការមិនចងពៀរ នៅក្នុងក្របខ័ណ្ឌរបស់ន័យថាដើម្បីបំបាត់ពៀរត្រូវលះបង់ធម៌បង្កើតពៀរទាំងឡាយមានជាអាទិគំនិតស្អប់គំនិតព្យាបាទនិងគំនិតចងអាឃាតហើយ ខំប្រឹងធ្វើខ្លួនឱ្យជាទីស្រឡាញ់រាប់អានរបស់មនុស្ស ។ បើទង្វើនេះមានប្រសិទ្ធិភាពពិតៗនោះមនុស្សយើង មិនត្រឹមតែគ្មានពៀរវេរានឹងគ្នាប៉ុណ្ណឹងទេ។ គេមានជីវិតប្រកបដោយសេចក្ដីត្រជាក់ត្រជុំសុខដុមរមនា ជាមួយគ្នាគ្រប់កាលគ្រប់សម័យមិនខានឡើយ ។មិនចំពោះតែរឿងព្យាបាទប៉ុណ្ណឹងទេដែលពុទ្ធសាសនាបង្រៀន ឱ្យយកឈ្នះដោយទង្វើល្អ សូម្បីសេចក្ដីមិនល្អដទៃៗ ទោះជារឿងអ្វីក៏ដោយ ក៏លោកបង្រៀនឱ្យយកឈ្នះដោយទង្វើល្អទាំងអស់ ។ ដូចនេះព្រោះអ្វី? ព្រោះគោលគំនិត នៃពុទ្ធសាសនាត្រូវការឱ្យសកលមនុស្ស មានកម្ពស់ខាងផ្លូវចិត្តមានជីវិតរស់នៅប្រកបដោយសសក្តិភាពជាន់ខ្ពស់គឺមិនបណ្ដោយខ្លួនឱ្យធ្លាក់ចុះជាទាសភាពនៃតណ្ហានៃគំនិតថោកទាបដែលជាមូលហេតុ នៃទុក្ខគ្រប់ប្រភេទ។ មិនមើលឃើញសខ្លួនឯង ក្នុងតំណែងនៃបញ្ញាសីលធម៌តាមធម្មតាមនុស្សតែងទាមទាររកសីលធម៌ កាលបើខ្លួនបានជួបប្រទះនូវទង្វើជិះជាន់ពីអ្នក

ដទៃ ដូចជាត្រូវគេបៀតបៀន លួចប្លន់បោកប្រាស់គេបន្លំ ។ល។ ហេតុការណ៍ដូចនេះ កើតឡើងក្នុងពេលណា ការអំពាវនាវស្រែកហៅរកយុត្តិធម៌សីលធម៌មនុស្សធម៌ ។ល។ ក៏គេធ្វើឡើងព្រមគ្នាក្នុងពេលនោះដែរទោះជាខ្លួនគេមិនធ្លាប់ឃើញតម្លៃឬការចាំបាច់នៃសីលធម៌នៃយុត្តិធម៌នៃមនុស្សធម៌ក្នុងកាលមុនៗមកក៏ដោយ ។

ក្នុងសម័យមានសង្គ្រាម គេធ្លាប់បានឮសម្លេងរអ៊ូរទាំទូទៅគ្រប់ទិសគ្រប់ទី ថា សីលធម៌ សាបសូន្យបាត់អស់ហើយ។ សម្លេងប៉ាច់ប៉ោចនេះ វាបានរសាត់អណ្តែតទៅកាន់ទីដែលមានមនុស្ស ដូចជារានលក់កាហ្វេគុយទាវបបរបាយផ្លូវថ្នល់ ។ល។ បញ្ហាវិបត្តិសីលធម៌ទើបត្រូវគេលើកមកដោះស្រាយរួមគ្នាទៅតាមសមត្ថកិច្ចដែលគេរកឃើញ ។ បើយើងពិនិត្យមើលដល់គោលគំនោលមួយអន្លើនឹងគំនោលការ នៃពុទ្ធសាសនារបស់យើងនឹងឃើញថា ពុទ្ធសាសនាបង្រៀនមិនឱ្យយើងមើលហួសខ្លួនឯងដល់ម្តងណាឡើយ ។ ការណ៍ពិតពុទ្ធសាសនាបង្រៀនឱ្យយើងមានស្មារតីចងចាំជានិច្ចឱ្យយើងចាត់ការខ្លួនឯងមុន ឱ្យយើងរៀបចំក្រុមខ័ណ្ឌល្អសម្រាប់ខ្លួនយ៉ាងឆាប់រហ័ស កុំឱ្យពេលវេលាដើរចោលយើងគឺកុំបង្អង់ចាំនោះ លុះត្រាមនុស្សទូទាំងពិភពលោកគេចាត់ការឱ្យ

ខ្លួនគេធ្វើនូវទង្វើល្អអស់ហើយទើបយើងចាប់ការល្អដល់ខ្លួនយើងជាចុងក្រោយបង្អស់ ។

អ្នកអានគប្បីរលឹកដល់ពុទ្ធភាសិតថា" អជ្ជេវ កិច្ចមាតប្បំ កោជញ្ញា មរណំ សុវេ..អត្តានមេវ បឋមំ បតិរូបេ និវេសយេ.....។ បំណងពុទ្ធភាសិតនេះចង់ឱ្យយើងធ្វើអ្វី១ដែលអ្នកប្រាជ្ញហៅថាសេចក្ដីល្អឱ្យ ហើយស្រេចភ្លាម១ទៅ ព្រោះសេចក្ដីស្លាប់មិនដឹងជាមានដល់ជីវិតយើងក្នុងថ្ងៃណា....ព្រោះបើយើងមិនធ្វើខ្លួនយើងឱ្យបានល្អជាមុនយើងក៏ពុំអាចដឹកនាំអ្នកដទៃឱ្យធ្វើសេចក្ដីល្អបានឡើយ ។ដូចនេះយើងត្រូវជាមនុស្សទី១ ក្នុងកិច្ចការល្អហើយ យើងក៏ជាមនុស្សក្រោយគេបំផុតក្នុងកិច្ចការអាក្រក់ ប្រសិនណាហើយបើគ្មានផ្លូវគេចឱ្យផុត" ។

ដូចខ្ញុំបានឱ្យយោបល់មកហើយថា ការបណ្ដុះឬគាំទ្រសីលធមិ ឬកំណែបញ្ហាសីលធមិសាបសូន្យនោះ ខ្ញុំបានចាត់ ជាពីរគឺ :

១- ចាត់ការគ្រប់បែបយ៉ាង ដែលមានរចនាសម្ពន្ធជាមួយនឹងបញ្ហាសេដ្ឋកិច្ច ឱ្យនៅក្នុងក្របខ័ណ្ឌនៃរបៀបរៀបរយត្រឹមត្រូវដូចមានក្នុងសំណេរខាងដើម ។

២- ចាត់ការជាមួយនឹងខ្លួនឯង ឱ្យជាមនុស្សរស់នៅក្នុងសីលធមិ

បំបាត់សេចក្តីសង្ស័យ កំចាត់ឱ្យអស់នូវសេចក្តី ខ្ជិលច្រអូស ។ជាមួយគ្នា នេះជួយរិះរកមធ្យោបាយធ្វើយ៉ាងណាឱ្យមនុស្សជាប់ចិត្តស្រឡាញ់យុត្តិធម៌នៃសង្គមនិយម គុណធម៌ល្អ ទាំងក្នុងទីស្ងាត់កំបាំងទាំងក្នុងទីប្រជុំជន ។ដើម្បីសន្តិសុខនៃជីវិត មនុស្សក្នុងសង្គមនឹងសន្តិភាពសកលពិភព ពុទ្ធសាសនាមិនត្រឹមតែបង្រៀនឱ្យមនុស្សម្នាក់ៗជួយខ្លួនឯង ប៉ុណ្ណឹងទេ ។ គឺបង្រៀនឱ្យជួយអ្នកដទៃផង ព្រោះអ្វី ? ព្រោះមនុស្ស មិនអាចនឹងរស់នៅម្នាក់ឯងកើតទេមនុស្សត្រូវតែរស់នៅដោយអាស្រ័យ សង្គមឬមានសង្គមទើបរស់នៅបាន ។ ដូចនេះបញ្ហាជួយខ្លួនឯងនឹងបញ្ហា ជួយអ្នកដទៃទើបជាធាតុចាំបាច់សម្រាប់មនុស្សដល់កម្រិតមួយរយភាគ រយតែម្តង ។

ព្រោះហេតុនេះហើយ បានជាពុទ្ធសាសនាបង្រៀនមនុស្សឱ្យចេះ ហ្វឹកហាត់អប់រំចិត្តឱ្យប្រកបដោយមេត្តាករុណា.ដែលគេស្គាល់ជាទូទៅ ថាផ្សាយព្រហ្មវិហារធម៌ឱ្យប្រព្រឹត្តទៅតាមលំដាប់លំដោយមាន៤យ៉ាង គឺ :

១-ផ្សាយមេត្តាដល់ខ្លួនឯងមុនដើម្បីដឹងថាខ្លួនឯងមានចិត្តស្រឡាញ់ សុខស្អប់ទុក្ខយ៉ាងណាអ្នកដទៃគេស្រឡាញ់សុខស្អប់ទុក្ខយ៉ាងនោះដែរ ។

២-លុះហាត់ផ្សាយមេត្តា ដល់ខ្លួនឯង បានដល់ភាពថ្មីកស្ទាត់ មែនទែនហើយ ត្រូវហាត់ផ្សាយមេត្តាដល់បុគ្គលជាទីស្រឡាញ់ទាំងឡាយ មានមាតាបិតាបុត្រភរិយាស្វាមីឬបុគ្គលជាញាតិមិត្តជាបន្តបន្ទាប់ទៅ ។

៣-ក្រោយពីបានផ្សាយមេត្តាដល់បុគ្គល ជាទីស្រឡាញ់ជាទីគោរពរាប់អានបាន ហើយត្រូវផ្សាយមេត្តាដល់បុគ្គលពួកកណ្តាល គឺមនុស្សដែលខ្លួនមិនទាន់ស្រឡាញ់ មិនទាន់ស្អប់ ឬមិនសូវយកចិត្តទុកដាក់ មិនសូវគិតគូរដល់ ។

៤-ក្នុងទីបំផុតត្រូវហាត់ផ្សាយមេត្តាដល់មនុស្ស ដែលធ្លាប់មានពំនៀវ ឬធ្លាប់ជាសត្រូវនឹងខ្លួន ។ ក្នុងសង្គមមនុស្សលោកគេគិតធ្វើយ៉ាងណាឱ្យមនុស្សឬសត្វដែលជាសត្រូវរបស់គេ ដល់នូវសេចក្តីវិនាស ។ដូច្នេះការហាត់ផ្សាយមេត្តាដល់ខ្លួន ដល់មនុស្សជាទីស្រឡាញ់ របស់ខ្លួននឹងមនុស្សកណ្តាល ដែលខ្លួនមិនទាន់ស្អប់ ទាំងប្រភេទនេះគ្មានលំបាកទេ ។ គឺមានតែបុគ្គលប្រភេទទី៤ប៉ុណ្ណោះ ដែលមានសេចក្តីលំបាកយ៉ាងខ្លាំងដល់បុគ្គលអ្នកហាត់ផ្សាយមេត្តាប្រហាក់ប្រហែលគ្នា នឹងបុគ្គលអ្នកស្វែងរកជីកមាស ក្នុងកន្លែងដែលមិនទានមានអណ្តូងជីកមាសនៅឡើយ ។ ទោះជាដូចនេះក្តី ក៏ពុទ្ធសាសនាខំប្រឹងបង្រៀនឱ្យមនុស្សយើងមាន

ចិត្តខ្ពស់ មានសេចក្តីត្រាប្រណី ចេះមានចិត្តក្លាហានអត់អោន មិនចាប់កំហុស មិនប្រកាន់ទោសមនុស្សជាសត្រូវ រហូតដល់ថ្នាក់ដូរចិត្ត ដូរគំនិតយកពុទ្ធសាសនានៃយើងដែលបានបង្ហាញមនុស្សធម៌ សន្តិសុខនៃជីវិតនឹងសន្តិភាពរបស់ពិភពលោកនៅក្នុងក្របខ័ណ្ឌនៃព្រហ្មវិហារធម៌ ប្រកបដោយប្រាកដនិយមយ៉ាងមានប្រសិទ្ធិភាព ប្រសិនបើមនុស្សលោកចាប់អារម្មណ៍ហើយអនុវត្តន៍តាម ។

សេចក្តីសរុបៈ ដើម្បីវឌ្ឍនភាពនៃជីវិតមនុស្សត្រូវតែខំប្រឹងស្ថាបនាសេដ្ឋកិច្ចសម្រាប់លោកនេះ ត្រូវបង្កើតផលគ្រប់យ៉ាងសម្រាប់លោកខាងមុខ ត្រូវខំបង្កើតបុណ្យគ្រប់ប្រភេទសម្រាប់ទីបំផុតនៃលោកបង្កើតគំនិតអរិយសច្ចៈ ។ ជាមួយគ្នានេះមនុស្សត្រូវមានគំនិតថាពៀរក្តីជម្លោះក្តី គំរោធក្តី កំណាញ់ក្តីសម្អប់ក្តី ។ល។ ត្រូវបានចប់ដោយគ្មានចំណងគ្មានចម្លើយគ្មានតំណប ។ល ។ មតិថាសង្គ្រាមចប់ដោយសង្គ្រាម ។ល។ មតិនេះពុទ្ធសាសនា ពុំបានយល់ស្របផងទេ ។ព្រោះពុទ្ធពំនោលក្នុងអរិយសច្ចៈថា ទុក្ខទាំងឡាយជាផលរបស់ហេតុគឺតណ្ហា តណ្ហាជាធាតុច្រានមនុស្សឱ្យធ្វើសង្គ្រាមឬសង្គ្រាមជាចំហេះរបស់តណ្ហា ។ បើមនុស្សលោកនៅតែមានគំនិតចចេសប្រកាន់សង្គ្រាមបំបាត់សង្គ្រាមនោះខ្ញុំយល់

ថាគំនិតនេះពុំបានត្រឹមត្រូវតាមសេចក្តីពិតទេ ។ អ្នកអានប្រសិនណា បើចង់ពិសោធរកសេចក្តីពិត ក្នុងរឿងនេះសូមមេត្តានឹកថយទៅក្រោយវិញ តាមផ្លូវប្រវត្តិសាស្ត្រក្តី តាមផ្លូវស្រាវជ្រាវផ្នែកមនុស្សជាតិខាងសាសនាក្តីធាតុទាំងអស់នេះនឹងបង្ហាញឱ្យឃើញថាគតិដែលយកសង្គ្រាមបញ្ចប់សង្គ្រាម វាមិនមែនបានចប់រហូតទេ គឺវាបានចប់មួយសំនើ១ដែលភាសាអ្នកប្រាជ្ញប្រវត្តិសាស្ត្រ ថាលោកចប់ដើម្បីកើត. កើតដើម្បីចប់ ។ ហើយកំណើតនៃសង្គ្រាមថ្មី ១ ទៀតវាកាន់តែរីកធំឡើង ១ តាមទំហំនៃតណ្ហារបស់មនុស្សដែលចេះតែកើនឡើង១ គ្រប់ពេលវេលា ។ ព្រឹត្តិការណ៍នៃពិភពលោក រហូតដល់សព្វថ្ងៃនេះសង្គ្រាម ទាំងតូច ទាំងធំមានចំនួនច្រើនស្ទើរតែគ្មានលេខដាក់ទៅហើយ ។ សង្គ្រាមឧប្បត្តិម្តង១មនុស្សត្រូវរងគ្រោះបាត់បង់ជីវិតពិការរូបកាយហិនហោចសម្ភារៈទ្រព្យសម្បត្តិកាន់ តែធ្ងន់ឡើង១រកកលធ្វើលេខលែងត្រូវចុះបញ្ជីលែងកើត គឺវាកាន់តែរងគ្រោះធំតាមលំដាប់ ។ឧបមាថាបើមានសង្គ្រាមលោកលើកទី ៣កើតឡើងក្នុងពេលឆាប់១នេះក្តី យូរបន្តិចទៀតក្តីខ្ញុំមានគំហើញថាអរិយធម៌របស់មនុស្សនឹងត្រូវបានចប់ហ្នឹងហើយ ។រីឯជម្លោះនឹងចំណាញ់

នៃសង្គ្រាមនេះទៀតសោតក៏វាទៅជាធាតុគ្មានន័យអ្នកឈ្នះក៏ដូចជាអ្នកចាញ់អ្នកចាញ់ក៏ដូចជាអ្នកឈ្នះព្រោះវាត្រូវរង គ្រោះវិនាសហិនហោចខ្លោច ផ្សាដូចគ្នា ។ ឬវាអាចទៅដល់ថ្នាកគ្មាននរណារស់នៅ ចាំទទួលយកឈ្នះយកចាញ់ដូចសង្គ្រាមមុន១ផង ក៏មិនដឹង!ប្រសិនបើសង្គ្រាមនេះ គេលេងគ្នាដោយគ្រាប់ បែកបរមាណូដែលបាញ់ចេញដោយកាំជ្រួចអវន្តទ្វីប។ សព្វថ្ងៃនេះគំនិតបញ្ចប់ សង្គ្រាមហាក់ដូចមានល្បឿនថយចុះខ្លះហើយ ព្រោះគេបានបើកសន្និសីទបន្ថយសញ្ញុធដែលមានគ្រាប់បែកបរមាណូនៅក្នុងនោះផងដែរ ។ ចំណែកគំនិតពុទ្ធសាសនាក្នុងចំណុចថាពៀរត្រូវចប់ដោយគ្មានចំណង ឬសង្គ្រាមត្រូវចប់ដោយគ្មានសង្គ្រាមឆ្លើយតប ក៏ត្រូវបានប្រទេសជប៉ុននឹងសហរដ្ឋអាមេរិក អនុវត្តន៍ហើយដែរ ។ ព្រោះអ្វី? ព្រោះប្រទេសទាំងពីរនេះ ក្នុងពេលចប់សង្គ្រាមពិភពលោកលើកទី២ បានដាក់ផ្លែផ្កាដល់គ្នាទៅវិញទៅមកតាមផ្លូវពាក្យសម្ដីគ្រប់ពេលវេលា ។ ជប៉ុនថាគ្រាប់បែកបរមាណូរបស់អាមេរិកកាំងនៅកោះអ្នូគីណាវាជាអនុស្សាវរីយ៍ សេចក្ដីឈឺចាប់មួយ ដែលពុំអាចឱ្យប្រជាជនជាតិជប៉ុនបំភ្លេចចោលបានទេ ។ អាមេរិកកាំងថា គ្រាប់បែករបស់ជប៉ុននៅកំពង់ផែចម្បាំងហ្វូទ្ធលូលូកោះហាវៃ ជាអនុស្សាវរីយ៍

យ៉ាងជូរចត់ខ្លោចផ្សាមួយ ដែលពុំអាចឱ្យអាមេរិកកាំង បំភ្លេចចោលបានឡើយ ។ក្រោយពេលលេងពាក្យ សម្ដីដល់គ្នានឹងគ្នាទៅវិញ មកមិនយូរប៉ុន្មានស្រាប់តែសន្ធិសញ្ញាការពារសន្តិសុខរួម ។ ជាមួយគ្នានេះបានព្រមព្រៀងគ្នាលើកធ្វើសង្គ្រាមរវាងគ្នានឹងគ្នាដោយដូរយកការសេដ្ឋកិច្ចមកធ្វើជាមួយគ្នាវិញ ។នេះបញ្ជាក់ឱ្យឃើញថាគំនិតពុទ្ធសាសនាត្រង់ថាសង្គ្រាមគេមិនអាចបញ្ចប់ដោយសង្គ្រាម ឬពៀរមិនរម្ងាប់បានដោយចំណង់ គឺជាធាតុសច្ចៈដល់កម្រិតមួយរយភាគរយ គ្មាននរណាអាចបដិសេធបានឡើយ ។

## គាមលោកិយ៍

-ព្យុះកាមសត្វលោករោគកិលេស មោហៈគេចវេសខ្លាចខ្លួនអន់
មាយាទច្រអូសប្រឹងបែរបន់ ពេលមានអាសន្នមិនឃើញសោះ ។
-ឈ្លក់នឹងលាភយសសរសើរសុខ ដេកស្រួលស្រណុកឥតស្រណោះ
ស្រណោកលើទុក្ខអ្នកក្រៀមក្រោះ អួតណាស់ថាស្មោះតែពីមុខ ។
-លុយមានតម្លៃនឹងអ្នកមាន ដរាបអ្នកឃ្លានមានគ្រោះទុក្ខ
សង្គមថ្កានថ្កើងឡើងទាន់យុគ ដរាបណាគុកគ្មានអ្នកកួច ។
-កើតមកមួយជាតិធាតុមួយក្ដាប់ កើតចាស់ឈឺស្លាប់គេចមិនរួច

ត្រឹមចែកគ្នារស់ចាំលាក់លួច ទោះកិច្ចតិចតួចរួមគ្នាគិត ។
ធ្វើខ្លួនហាត់ចិត្តប្រិតផ្លូវល្អ សប្បាយត្រេកអរនឹងរឿងពិត
ខ្ជាក់ចោលតណ្ហាកុំឱ្យរិត ទាញខ្លួនឱ្យជិតធម៌សច្ចៈ ។

និពន្ធដោយ ទឹម សុខហួយ (ទេហា)
និស្សិតសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ
អក្សរសាស្ត្រខ្មែរ ឆ្នាំទី២

## ជំពូកទី៣

## ចូឡទុក្ខក្ខន្ធសូត្រ[១]

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាមទៀបក្រុងកបិលព័ស្តុក្នុងសក្កជនបទ ។ លំដាប់នោះឯងសក្យរាជទ្រង់ព្រះនាមមហានាមក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។លុះមហានាមសក្យរាជគង់ក្នុងទីដ៏សមគួរ ហើយទើបក្រាបទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គបានដឹងច្បាស់ នូវធមិដែលព្រះមានព្រះភាគទ្រង់សំដែង អស់កាលដ៏យូរហើយគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គខ្លះ បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គនោះទើបមានសេចក្តីត្រិះរិះយ៉ាងនេះថាចុះធមិអ្វីហ្ន៎! នៅខាង ក្នុងសន្តានដែលអាត្មាអញមិនទាន់លះបង់អស់បាន ជួនកាលធមិគឺលោភៈទោសៈនិងមោហៈគ្របសង្កត់របស់អាត្មាអញ ។

---

១-ពុទ្ធវចនៈសម្តែងអំពីកងនៃសេចក្តីទុក្ខតិចតួចក្នុងសូត្រនេះ

## ការកំណត់នូវវេទនា[២]

ព្រះពុទ្ធទ្រង់ត្រាស់ថា ថ្វាយព្រះពរមហានាមធម៌គឺលោភ[៣]ៈ ទោស[៤]ៈនិងមោហៈក្នុងសន្ដានចិត្តនោះឯងដែលមហាបពិត្រមិនទាន់លះបង់អស់បានជួនកាលធម៌គឺលោភៈទោសៈនិងមោហ[៥]ៈ គ្រប់សង្កត់ចិត្តរបស់មហាបពិត្រខ្លះ ។ បពិត្រមហានាមបើធម៌ក្នុងសន្ដាននោះមហាបពិត្រ បានលះបង់អស់ហើយ ។ មហាបពិត្រ នឹងលែងនៅគ្រប់គ្រងផ្ទះនឹងគប្បីលែងបរិភោគកាមទាំងឡាយ ។ បពិត្រមហានាមធម៌ខាងក្នុងសន្ដាននោះឯង មហាបពិត្រលះបង់មិនទាន់បានព្រោះហេតុនោះបានជាមហាបពិត្រនៅគ្រប់គ្រងផ្ទះបរិភោគកាមទាំងឡាយ ។

ថ្វាយព្រះពរមហានាម បើអរិយសាវ័កបានឃើញច្បាស់ តាមសេចក្ដីពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថាកាមទាំងឡាយ មានសេចក្ដីសុខតិចមានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះមានច្រើនពេក ។ អរិយសាវ័កនោះឯង បានវៀរចាកកាម

---

២-វេទនា ជានាម មានន័យថា សោយនូវរសនៃអារម្មណ៍មានរូបជាដើម ។

៣-លោភៈសេចក្ដីជំពាក់ចិត្តក្នុងអារម្មណ៍មានរូបជាដើម ។

៤-ទោសៈ កំហឹង

៥-មោហៈ អវិជ្ជា សេចក្ដីវង្វេង ភ័ន្តស្មារតីមិនយល់ការណ៍

ទាំងឡាយវៀរចាកអកុល-សធម៌ទាំងឡាយហើយ តែមិនទាន់បានបីតិ និងសុខ ឬគុណជាតិដទៃដែលល្អិត លើសជាងបីតិ និងសុខនោះ កាលបើដូច្នេះអរិយសាវ័ក[៦] នោះនឹងឈ្មោះថាមិនត្រឡប់មករកកាមទាំងឡាយវិញនោះ មិនមែនឡើយ ។ បពិត្រមហានាម កាលបើអរិយសាវ័កបានឃើញច្បាស់តាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថាកាមទាំងឡាយមានសេចក្តីសុខតិចមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើនទោសក្នុងទាំងឡាយនុ៎ះមានច្រើនក្រៃពេក ។ អរិយសាវ័កនោះឯងបានវៀរចាកកាមទាំងឡាយ វៀរចាលអកុសលធម៌ទាំងឡាយហើយបាននូវបីតិ និងសុខឬគុណជាតិដទៃដែលល្អិតលើសជាងបីតិ និងសុខនោះ កាលបើដូច្នេះអរិយសាវ័កនោះ ទើបឈ្មោះថាមិនវិលត្រឡប់មករកកាមទាំងឡាយទៀតឡើយ ។ ម្នាលមហានាមប៉ុនអប្បាលតថាគ កាលនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងក្នុងកាលមុនអំពីកាល ត្រាស់ដឹងនៅឡើយ បានឃើញច្បាស់តាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថាកាមទាំងឡាយមានសុខតិច សេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនុ៎ះ មានច្រើនក្រៃពេក ។ តថាគតនោះវៀរចាកកាមទាំងឡាយ

---

៦-អរិយសាវ័ក អរិយបុគ្គលអ្នកបានស្តាប់ពុទ្ធវាទ( បើជាស្ត្រី អរិយសាវិកា) ។

វៀរចាក អកុសលធម៌ទាំងឡាយហើយតែមិនទាន់បានបីតិនិងសុខ ឬគុណជាតិដទៃ ដែលល្អិតលើសជាងបីតិ នឹងសុខនោះកាលបើដូច្នេះ តថាគតនោះក៏ដឹងប្រាកដថា អាត្មាអញត្រឡប់មករកកាមទាំងឡាយវិញ ដោយពិត ។បពិត្រមហានាមលុះកាលណាតថាគត បានឃើញតាមពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា កាមទាំងឡាយមានសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ ច្រើនទោសក្នុងកាមទាំងឡាយនុ៎ះមានច្រើនក្រៃពេក ។ តថាគតនោះឯងបានវៀរចាកកាមទាំងឡាយហើយបានទូវបីតិនឹងសុខផងកាលបើដូច្នេះ.តថាគតដឹងច្បាស់ថាមិនវិលត្រឡប់មករកកាមទាំងឡាយវិញឡើយ ។

## តម្រេករបស់កាម

ថ្វាយព្រះពរមហានាមចុះអ្វីជាតម្រេករបស់កាមទាំង ឡាយ ។ បពិត្រមហានាមកាមគុណទាំងនេះមាន៥ប្រការចុះ កាមគុណ៥ប្រការអ្វីខ្លះ?

កាមគុណ៥ប្រការគឺ:

១-រូបទាំងឡាយដែលគប្បីដឹងច្បាស់បានដោយភ្នែកជាទីប្រាថ្នា ជាទីត្រេកអរជាទីគាប់ចិត្ត ជាទីស្រឡាញ់ ត្រូវតាមចំណង់ ជាទីត្រេក

ត្រអាល ។

២-សំឡេងទាំងឡាយដែលគប្បីដឹងដោយត្រចៀក... ។

៣-ក្លិនទាំងឡាយដែលគប្បីដឹងដោយច្រមុះ.... ។

៤-រសទាំងឡាយដែលគប្បីដឹងដោយអណ្តាត.... ។

៥-ផ្សព្វទាំងឡាយដែលគប្បីដឹងដោយកាយ..... ។

បពិត្រមហានាម ត្រង់ដែលសេចក្តីសោមនស្សកើតឡើងព្រោះអាស្រ័យកាមគុណទាំង៥នេះឯង ជាតម្រេករបស់កាមទាំងឡាយ ។

## ទោសនៃកាមទាំងឡាយ

ថ្វាយព្រះពរមហានាម ចុះអ្វីជាទោសរបស់កាមទាំងឡាយ ។ បពិត្រមហានាមកុលបុត្រក្នុងលោកនេះចិញ្ចឹមជីវិត ដោយសេចក្តីប្រឹងប្រែងដោយសិល្បសាស្ត្រណានីមួយ ទោះបីជាដោយការរាប់ម្រាមដៃក្តីដោយការរាប់លេខនព្វនក្តី ដោយការរាប់ប្រមូលក្តី ដោយកសិកម្មក្តី ដោយពាណិជ្ជកម្មក្តី ដោយគោរក្ខកម្មក្តី ដោយភាវៈនៃខ្លួនជាខ្មាន់ធ្នូក្តី ដោយភាវៈនៃខ្លួនជារាជបុរសក្តីសិល្បសាស្ត្រឯណាមួយក្តីកុលបុត្រដែលអាស្រ័យនូវការចិញ្ចឹមជីវិត ដោយការរាប់ម្រាមដៃទទេជាដើម នោះ (សម័យបច្ចុប្បន្ននេះបច្ចេកវិទ្យាច្រើនណាស់ដែលជាវិជ្ជាសម្រាប់ចិញ្ចឹម

ជីវិត មានមុខវិជ្ជាអាយធីជាដើម) តែងមាន ត្រជាក់បៀតបៀន មានក្តៅបៀតបៀនប៉ះពាល់ដោយសម្ផស្សនៃរបោម មូសខ្យល់កម្តៅថ្ងៃ នឹងពល់តូចពស់ធំស្លាប់ខ្លួនដោយសេចក្តីស្រេកឃ្លាន បពិត្រមហានាមនេះឯង ជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បី ឃើញទាន់ភ្នែកជាគំនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើមជាបច្ច័យនៃកាមទាំងឡាយមែនពិត ។បពិត្រមហានាមកាលកុលបុត្រប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាតយ៉ាងនេះហើយភោគៈទាំងនេះ ក៏មិនបានសម្រេចកុលបុត្រនោះ តែងក្រៀមក្រំចិត្តលំបាកខ្សឹកខ្សួល គក់ទ្រូងទ្រហោយំ ដល់នូវ សេចក្តីវង្វេងថា ឱ សេចក្តីប្រឹងប្រែងរបស់អាត្មាអញឥតសារឥតការសោះ ឱ សេចក្តីព្យាយាមរបស់អាត្មាអញ ឥតផលប្រយោជន៍សោះ ។ បពិត្រ មហានាម នេះឯងជាទោសរបស់កាមទាំងឡាយដែលបុគ្គលឃើញទាន់ភ្នែកជាគំនរនៃទុក្ខមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើមជាបច្ច័យនៃកាមទាំងឡាយមែនពិត ។កាលបើកុលបុត្រនោះ ខំប្រឹងប្រែងខ្នះខ្នែងព្យាយាម យ៉ាងនេះហើយភោគៈទាំងនោះក៏បានសម្រេច កុលបុត្រនោះតែងរងទុក្ខទោមនស្ស ព្រោះហេតុនៃរក្សា

ភោគៈទាំងឡាយនោះថាធ្វើម្ដេចហ្ន៎ កុំឱ្យព្រះរាជាទាំងឡាយនាំយកភោគៈ របស់អាត្មាអញទៅបាន កុំឱ្យចោរទាំងឡាយលួចយកទៅបាន កុំឱ្យភ្លើងឆេះបាន កុំឱ្យទឹកនាំយកទៅបាន កុំឱ្យអ្នកទទួលមត៌កទាំងឡាយមិនជាទីស្រឡាញ់ ទាមយកចំណែកទៅក្ដី កុលបុត្រនោះតែងក្រៀមក្រំចិត្ត លំបាកខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំដល់នូវសេចក្ដីវង្វេងថាទ្រព្យណាបានកើតមានហើយ ដល់អាត្មាអញ ឥឡូវនេះទ្រព្យនោះឯង ត្រឡប់ជាមិនមានដល់អាត្មាអញវិញឡើយ ។បពិត្រមហានាមនេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែកជាគំនរនៃទុក្ខមានកាមជាហេតុមានកាមជាគ្រឿងប្រគល់នូវផលមានកាមជាគ្រឿងផ្ដួចផ្ដើម ជាបច្ច័យនៃកាមទាំង ឡាយមែនពិត ។

ថ្វាយព្រះពរមហានាម មួយទៀត ព្រោះតែមានកាមជាហេតុមានកាមជាគ្រឿងប្រគល់នូវផល មានកាមជាគ្រឿងផ្ដួចផ្ដើមជាបច្ច័យនៃកាមទាំងឡាយ មែនពិត បានជាព្រះរាជាទាំងឡាយ ទាស់ទែងគ្នានឹង ព្រះរាជាខ្លះ ក្សត្រទាំងឡាយទាស់ទែងគ្នា នឹងក្សត្រទាំងឡាយខ្លះព្រាហ្មណ៍ទាំងឡាយទាស់ទែងគ្នានឹងព្រាហ្មណ៍ទាំងឡាយខ្លះ គហបតីទាំងឡាយ ទាស់ទែងគ្នានឹងគហបតីទាំងឡាយ រដ្ឋមន្ត្រីទាស់ទែង

នឹងរដ្ឋមន្ត្រីខ្លះមាតាទាស់ទែងគ្នានឹងបុត្រខ្លះបុត្រទាស់ទែងគ្នានឹងមាតាខ្លះបិតាទាស់ទែងគ្នានឹងកូនខ្លះ បុត្រទាស់ទែងគ្នានឹងបិតាខ្លះ បងប្អូនប្រុសទាស់ទែងគ្នា នឹងបងប្អូនប្រុសខ្លះ បងប្អូនប្រុសទាស់ទែងគ្នា នឹងបងប្អូនស្រីខ្លះបងប្អូនស្រីទាស់ទែងគ្នានឹងបងប្អូនប្រុសខ្លះ សំឡាញ់ទាស់ទែង គ្នានឹងសំឡាញ់ខ្លះ គ្រូទាស់ទែងគ្នានឹងគ្រូខ្លះ កសិករទាស់ទែងគ្នានឹងកសិករខ្លះ អ្នកជំនួញទាស់ទែងគ្នានឹងអ្នកជំនួញខ្លះ បុគ្គលិកក្រុមហ៊ុនទាស់ទែងគ្នានឹងបុគ្គលិកក្រុមហ៊ុនខ្លះ អ្នកបើកឡានទាស់ទែងនឹងអ្នកបើកឡានខ្លះ សិស្សទាស់ទែងគ្នានឹងសិស្សខ្លះអ្នកបួសទាស់ទែងគ្នានឹកអ្នកបួសខ្លះ ស្តេចសង្ឃទាស់ទែងគ្នានឹងស្តេចសង្ឃខ្លះជាដើម ។ពួកមនុស្សទាំងអស់នោះ ក៏ដល់នូវសេចក្តីឈ្លោះប្រកែកប្រកាន់ខុសទាស់ទែងគ្នា ក្នុងទីនោះហើយប្រហារគ្នានឹងគ្នាដោយដៃខ្លះ ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយសស្ត្រាវុធខ្លះ បាញ់គ្នាដោយ កាំភ្លើងខ្លះចាក់គ្នាដោយកាំបិតខ្លះវាយគ្នាដោយច្រវាក់ខ្លះជាដើម ពួកមនុស្សទាំងនោះ ក៏ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខខ្លះ ត្រូវប៉ូលិសចាប់ដាក់គុកខ្លះ ស្ទើរតែនឹងស្លាប់ខ្លះ ក្នុងទីនោះ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គល

គប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខមានកាមជាហេតុមានកាមជាគ្រឿងប្រគល់ឱ្យ នូវផល មានកាមជាគ្រឿងផ្តួចផ្តើមជាបច្ច័យនៃកាមទាំងឡាយ ។

ថ្វាយព្រះពរមហានាម មួយទៀតព្រោះតែមានកាម ជាហេតុមានកាមជាគ្រឿងប្រគល់ឱ្យនូវផលមានកាមជាគ្រឿងផ្តួចផ្តើមជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាមនុស្សទាំងឡាយ កាន់យកនូវដាវនឹងខែលកាន់យកនូវធ្នូ សៀតបំពង់ព្រួញ កាន់យកនូវកាំភ្លើងធំកាន់យកនូវកាំភ្លើងអាកា កាំភ្លើងខ្លី និងកាំភ្លើងគ្រប់ប្រភេទទៀតចូលទៅកាន់សង្គ្រាមដែលលើកជាក្បួនទ័ពមកទាំងសងខាង កាលដែលគេ បាញ់ព្រួញមកក្តីកាលដែលគេពួយលំពែងមកក្តីកាលដែលគេងាដាវឡើងក្តី ពួកមនុស្សទាំងនោះ ក៏បាញ់គ្នា ដោយព្រួញខ្លះ ដោយគ្រាប់កាំភ្លើងខ្លះចាក់គ្នាដោយលំពែងខ្លះកាប់ក្បាលដោយដាវខ្លះក្នុងសង្គ្រាមនោះពួកមនុស្សទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខ ស្ទើរតែនឹងស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ។ បពិត្រមហានាម នេះឯងជាទោសរបស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក មានកាមជាហេតុមានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួច ផ្តើម

ជាបច្ច័យនៃកាមទាំងឡាយមែនពិត។

ម្នាលមហានាម មួយទៀត ព្រោះតែមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត បានជាពួកមនុស្សទាំងនោះ កាន់យកនូវដាវនឹងខែល កាន់ធ្នូ សៀតបំពង់ព្រួញ ចូលទៅកាន់បន្ទាយដែលលាបបូកដោយបាយអរកាលដែលគេបាញ់ព្រួញមកក្តីកាលដែលគេ ពួយលំពែងមកក្តី កាលដែលគេងាដាវឡើងក្តី ពួកមនុស្សទាំងនោះក៏បាញ់គ្នាដោយលំពែងខ្លះ កាប់ក្បាលគ្នាដោយដាវខ្លះ ក្នុងបន្ទាយនោះ ពួកមនុស្សទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវសេចក្តីទុក្ខស្ទើរតែ នឹងស្លាប់ខ្លះ ក្នុងបន្ទាយនោះ។ មហានាម នេះឯងជាទោស របស់កាមទាំងឡាយ ដែលបុគ្គលគប្បីឃើញទាន់ភ្នែក ជាគំនរនៃទុក្ខមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួច ផ្តើមជាបច្ច័យនៃកាមទាំងឡាយមែនពិត។

ម្នាលមហានាម មួយទៀត ព្រោះតែគេមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផលមានកាមជាគ្រឿងផ្តួចផ្តើមជាបច្ច័យនៃកាមទាំងឡាយមែនពិត មនុស្សទាំងឡាយក៏កាត់នូវជញ្ជាំង

ផ្ទះខ្លះ ប្លន់ខ្លះ កំហែងយកទ្រព្យក្នុងផ្ទះមួយៗខ្លះ ឈរស្កាត់ច្រកផ្លូវខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះ ព្រះរាជទាំងឡាយចាប់មនុស្សទាំងនោះ ហើយត្រាស់បង្គាប់ឱ្យធ្វើកម្មករទាំងឡាយ មានប្រការផ្សេងៗគឺឱ្យវាយដោយរពាត់ខ្លះឱ្យវាយដោយផ្តៅខ្លះឱ្យវាយដោយដំបងខ្លីខ្លះ ។ល ។ធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេដុតដៃខ្លះធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើឱ្យដូចជាពន្លាត់ ស្បែកពពែខ្លះ ធ្វើនូវចីរវាសិកកម្មគឺអំពើដែលគេធ្វើឱ្យដូចជាគេស្លៀកសំពត់សម្បកឈើខ្លះធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលធ្វើ ឱ្យដូចជាជើងសត្វទ្រាយខ្លះពលិសមំសិកកម្មគឺអំពើដែលគេថ្ពក់មាត់ដោយកាងឬសន្ទូចខ្លះធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើ ឱ្យខូចសរីរៈប្រមាណប៉ុនកហាបណៈខ្លះធ្វើនូវខារាបជិច្ឆកកម្មគឺដែលគេយកទឹកផ្សារស្រោចខ្លះ ធ្វើបលិឃបរិវត្តិកម្ម គឺអំពើដែលគេធ្វើឱ្យដូចជាគេបង្វិលជើងគុល ឬសសរគោលខ្លះ ធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឱ្យដូចជាកណ្តាបចំបើងខ្លះ ស្រោចនូវប្រេងដែលក្តៅខ្លះឱ្យឆ្កែខាំខ្លះ ឱ្យដេកផ្ងារលើអណ្តោតភ្លើងទ្រាំរស់ខ្លះកាត់ក្បាលដោយដាវខ្លះ មនុស្សទាំងនោះក៏ដល់នូវសេចក្តីស្លាប់ខ្លះដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ខ្លះក្នុងទីនោះ ។ បពិត្រមហានាមនេះឯងជាទោស របស់កាម

ទាំងឡាយ ដែលបុគ្គល គប្បីឃើញទាន់ភ្នែកជាគំនរនៃទុក្ខមានកាមជាហេតុ មានជាគ្រឿង ប្រគល់នូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំយឡាយ មែនពិត ។

បពិត្រមហានាមមួយទៀតព្រោះតែមានកាម ជាហេតុ មានកាមជាគ្រឿងប្រគល់នូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិតបានជាជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយដោយវាចាដោយចិត្តហើយលុះដល់បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ( ស្លាប់ )ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ បពិត្រមហានាម នេះឯងជាទោស របស់កាមទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងសម្បាយិកភព ជាគនរនៃទុក្ខ មានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឱ្យនូវផល មានកាមជាគ្រឿងផ្តួចផ្តើម ជាបច្ច័យនៃកាមទាំងឡាយមែនពិត ។

## ការឈរទើយនៃពួកនិគ្រន្ថ[៧]

បពិត្រមហានាមមានកាលសម័យថ្ងៃមួយ តថាគតនៅព្លដ៏ភ្នំ

៧. និគ្រន្ថ( និគ្រន់ ) អ្នកដែលប្រាសចាកកិលេសជាគ្រឿងជោតក្រង ឬកិលេសជាគ្រឿងចាក់ស្រែះហើយ...។ បព្វជិតពួកមួយបួសក្រៅ ព្រះពុទ្ធសាសនាប្រកាន់លទ្ធិថា ខ្លួនជាមនុស្សកម្ចាត់កិលេសដែល ចាក់ស្រែះនៅក្នុងសន្តានឱ្យជ្រះស្រអស់ហើយ ( អចេលកៈ ឬ អាជីវកៈ ) ។

តិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកនិគ្រន្ថ ជាច្រើន ជាអ្នកឈរងើយ លើផ្ទៃកាឡសិលា ទៀបភ្នំឥសិគិល ជាអ្នកឃាត់អាសនៈជាទុក្ខដ៏ខ្លាំងក្លា ក្រហល់ដែលកើតអំពីសេចក្ដីព្យាយាម ។បពិត្រមហានាម គ្រានោះឯង តថាគតក្រោកអំពីទីសម្ងំក្នុងវេលាល្ងាចហើយ ចូលទៅឯកាឡសិលាខាងភ្នំឥសិគិលិសំដៅទៅត្រង់ទីដែលពួកនិគ្រន្ថនៅ លុះចូលទៅដល់ហើយ បានសួរពួកនិគ្រន្ថទាំងនោះ ដូច្នេះថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះព្រោះហេតុអ្វី បានជាអ្នកទាំងឡាយនាំគ្នាឈរងើយ ឃាត់អាសនៈ ទទួលនូវវេទនាជាទុក្ខ ដ៏ខ្លាំងក្លាក្រហល់ក្រហាយ ដែលកើតអំពីសេចក្ដីព្យាយាមដូច្នេះ។ បពិត្រមហានាម កាលតថាគតសួរ យ៉ាងនេះហើយ និគ្រន្ថទាំងនោះបាននិយាយតបពាក្យនេះនឹងតថាគតថាម្នាលអាវុសោនិគ្រន្ថនាដបុត្រ( គ្រូយើង ) ជាអ្នកដឹងសព្វ ឃើញសព្វប្ដេជ្ញាដឹងនូវញាណទស្សនៈ[៨] គឺការដឹង និងការឃើញមិនមាន សេសសល់ថា អាត្មាអញ កាលដើរក្ដី ឈរក្ដីដកលក់ភ្ញាក់ឡើងក្ដី ក៏មានញាណទស្សនៈ តាំងស៊ប់ជានិច្ចមិនដែលដាច់ និគ្រន្ថនាដបុត្រនោះ ពោលយ៉ាងនេះថា ម្នាលនិគ្រន្ថទាំងឡាយដ៏ចម្រើន បាបកម្ម ដែល

---

៨.ញាណទស្សនៈ ប្រាជ្ញដែលដឹង ដែលឃើញនូវសេចក្ដីពិត ដូចឃើញច្បាស់នូវ សេចក្ដីមិនទៀងនៃរូបកាយជាដើម គឺប្រាជ្ញាសម្រាប់ពិចារណានូវសង្ខារ....។

អ្នកទាំងឡាយបានធ្វើហើយក្នុងកាលមុន ក៏មានដែរអ្នកទាំងឡាយ ចូរញ៉ាំងបាបកម្មនោះអោយសាបសូន្យ ទៅដោយអំពើកម្រដ៏ជាទុក្ខនេះ ក៏ការដែលអ្នកទាំងឡាយ សង្រួមដោយកាយសង្រួម ដោយវាចាសង្រួមដោយចិត្ត ក្នុងអំពើដ៏កម្រនុ៎ះ ក្នុងកាលឥឡូវនេះ នោះឈ្មោះថាមិនធ្វើនូវបាបកម្មតទៅព្រោះហេតុនោះកម្មចាស់ទាំងឡាយដែលវិនាសទៅដោយសារសេចក្តីព្យាយាមទាំងកម្មថ្មីទាំងឡាយ ដែលមិនបានធ្វើឈ្មោះថា នឹងមិនមានការជាប់តាមតទៅ ឈ្មោះថានឹងអស់ទៅនៃកម្មព្រោះអស់ទៅនៃកម្មឈ្មោះថានឹងអស់ទៅនៃទុក្ខ ព្រោះអស់ទៅនៃទុក្ខឈ្មោះថាអស់ទៅនៃវេទនា ព្រោះអស់ ទៅនៃវេទនា ឈ្មោះថាទុក្ខទាំងពូងនឹងសាបសូន្យ ទៅក៏ពាក្យនេះឯងតែងគាប់ចិត្តផង គួរផងដល់យើងទាំងឡាយ យើងទាំងឡាយ ជាអ្នកមានចិត្តរីករាយ ដោយពាក្យនោះ ។

## ការឆ្លើយសាគសួរពួកនិគ្រន្ថ

បពិត្រមហានាម កាលនិគ្រន្ថទាំងឡាយ ពោលយ៉ាងនេះហើយតថាគតក៏បានសួរពួកនិគ្រន្ថទាំងនោះដូច្នេះថាម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថាយើងទាំងឡាយធ្លាប់កើតក្នុងកាលមុន ឬមិនដឹងថា មិនធ្លាប់កើត ក្នុងកាលមុនទេ ។

និគ្រន្ថទាំងឡាយ ឆ្លើយតបថា ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថាយើងទាំងឡាយ បានធ្វើនូវបាបកម្មក្នុងកាមុន ឬមិនដឹងថាមិនបានធ្វើនូវបាបកម្មក្នុងកាលមុនទេ ។ ម្នាលអាវុសោ ដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយដឹងថាយើងទាំងឡាយបានធ្វើនូវបាបកម្មមានសភាពយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ ដូច្នេះដែរឬទេ ។ម្នាលអាវុសោដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយ ចុះអ្នកទាំងឡាយ ដឹងថាទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយឬទុក្ខមានប្រមាណប៉ុណ្ណេះ គប្បីសាបសូន្យហើយឬកាលបើទុក្ខមានប្រមាណប៉ុណ្ណេះសាបសូន្យហើយទុក្ខទាំងអស់ នឹងសាបសូន្យទៅ ដូច្នេះដែរឬ ។ ម្នាលអាវុសោដំណើរនេះ យើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោនិគ្រន្ថទាំងឡាយចុះអ្នកទាំងឡាយដឹងថាក្នុងសាសនា របស់ពួកអ្នកមានការលះបង់ នូវធម៌ទាំងឡាយជាអកុសលញ៉ាំងធម៌ទាំងឡាយជាកុសលអោយកើតឡើងក្នុងបច្ចុប្បន្ននេះដែរ ឬទេ ។ ម្នាលអាវុសោដំណើរនេះយើងខ្ញុំមិនបានដឹងទេ ។ ម្នាលអាវុសោ និគ្រន្ថទាំងឡាយ បានឮថា អ្នកទាំងឡាយ មិនដឹងថាយើង

ទាំងឡាយធ្លាប់កើតក្នុងកាលមុន មិនមែនថា មិនធ្លាប់កើតដូច្នេះទេ មិនដឹងថា យើងទាំងឡាយបានធ្វើនូវបាបកម្ម ក្នុងកាលមុន មិនមែនថាមិនបានធ្វើដូច្នេះទេមិនដឹងថាយើងទាំងឡាយ បានធ្វើបាបកម្ម មានសភាពយ៉ាងនេះខ្លះយ៉ាងនោះខ្លះដូច្នេះទេមិនបានដឹងថាទុក្ខមានប្រមាណប៉ុណ្ណោះសាបសូន្យហើយ ឬ ទុក្ខមានប្រមាណប៉ុណ្ណោះគប្បីសាបសូន្យទៅឬក៏កាល បើទុក្ខមានប្រមាណប៉ុណ្ណោះ សាបសូន្យទៅហើយទុក្ខទាំងអស់ និងសាបសូន្យ ទៅដូច្នេះទេមិនបានដឹងថា ក្នុងសាសនារបស់ពួកអ្នកមានការលះបង់នូវធម៌ទាំឡាយជាអកុសលញ៉ាំងធម៌ទាំងឡាយជាកុសលអោយកើតឡើង ក្នុងបច្ចុប្បន្ន នេះដូច្នេះទេ ម្នាលអាវុសោនិគ្រន្ថទាំងឡាយកាលបើយ៉ាងនេះមានតែជនទាំងឡាយណា ក្នុងលោកដែលជាអ្នកមានមារយាទអាក្រក់ មានដៃប្រលាក់ដោយឈាមមានការងារអាក្រក់ជនទាំងនោះ លុះបានកើតមកជាមនុស្សក្នុងលោកក្នុងកាលជាខាងក្រោយក៏បួសក្នុងពួក និគ្រន្ថទៀតឬអ្វី ។

### ពោលអំពីការនៅជាសុខដ៏លើសលុប

